ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Nov-2012, 15:21
CMS/CFO: Sann Rada

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង</u>
## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី១៣៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

លោកស្រី សេ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វេង ហ៊ាត់

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក រេយ៍ន័រ ឃីត

*(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទ្រី ស្រ៊ីនណា

លោក វ៉ែន ពៅ

លោក គង់ ផល្លះ

លោក ម៉ះដេវ ម៉ូហាន *(Mr. Madhev MOHAN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្វី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ទី ស្រ៊ុនណា | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក គង់ ផល្លៈ | ខ្មែរ |
| លោក ម៉ះដេវ ម៉ូហាន | អង់គ្លេស |
| លោកស្រី អោ រី (TCCP-105) | ខ្មែរ |
| លោក ចៅ នី (TCCP-187) | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី អោ រី** (TCCP-105)

សួរបន្តដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី៖ ........ ទំព័រ ៣

សួរដោយលោក សុន អរុណ ផ្តើមពី៖ ........ ទំព័រ ១៩

សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី ផ្តើមពី៖ ........ ទំព័រ ២៥

សួរដោយលោក អាង ឧត្តម ផ្តើមពី៖ ........ ទំព័រ ២៨

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ចៅ នី** (TCCP-187)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ........ ទំព័រ ៣៣

សួរដោយលោក គង់ ផល្លះ ផ្តើមពី៖ ........ ទំព័រ ៣៥

សួរដោយលោក ម៉ះដេរ ម៉ូហាន ផ្តើមពី៖ ........ ទំព័រ ៤២

សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖ ........ ទំព័រ ៦៦

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖ ........ ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី អោ វី ហើយនិងបន្តស្ដាប់ អ៊ំ នឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សី អ៊ំ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-187។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួម នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី អវត្តមាន ដោយមូលហេតុសុខភាព។ ប៉ុន្តែយោងតាមលិខិតលះបង់សិទ្ធិមានវត្តមានដែនកំណត់របស់ជនជាប់ចោទ ឯកសារលេខ E237/1 ជនជាប់ចោទបានលះបង់សិទ្ធិមានវត្តមាននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការ នៃការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ក្នុងនោះមានដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP ដែលអង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មនៅក្នុងថ្ងៃនេះ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-187 ដែលនឹងស្ដាប់សក្ខីកម្មបន្ទាប់ពីបញ្ចប់ការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី TCCP-105។ លោក ម៉ៃខល កាណាវាស មេធាវីអន្តរជាតិការពារក្ដីឲ្យលោក អៀង សារី អវត្តមានដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-105 មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ រីឯដើមបណ្ដឹងរដ្ឋប្បវេណី TCCP-187 មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ កត់សម្គាល់ផងដែរពីវត្តមានលោក ម៉ះដេវ ម៉ូហាន ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារួចហើយ ប៉ុន្តែមិនទាន់ត្រូវបានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលកន្លងមកនៅឡើយ។ សូមអរគុណ។

[០៩:០៧:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដោយអង្គជំនុំជម្រះកត់សម្គាល់ឃើញថា មានវត្តមានមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិ ដែលមិនទាន់ត្រូវបានទទួលស្គាល់ចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះមុននឹងដំណើរការបន្តស្ដាប់សក្ខីកម្ម ដើមបណ្ដឹងរដ្ឋប្បវេណី អោ រី អង្គជំនុំជម្រះធ្វើនីតិវិធីស្នើសុំនិងទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាមុនសិន ដោយអនុវត្តតាមវិធាន២២(២)(ក) អង្គជំនុំជម្រះសូមអញ្ជើញលោកមេធាវីជាតិតំណាង នាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបម្រុង ដែលជំនួសឡើងធ្វើសេចក្ដីស្នើសុំទទួលស្គាល់ មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះ។

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សូមគោរពតំណាងសហព្រះរាជអាជ្ញា និងអង្គសវនាការទាំងមូល!

ក្នុងនាមសហមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបាទ សូមជម្រាបជូនលោកប្រធាន និងអង្គជំនុំជម្រះថា នាព្រឹកនេះ យើងមានមេធាវីតំណាងដើមបណ្ដឹងជាតិថ្មីមួយរូប ដែលលោកមានឈ្មោះថា គឺលោក គង់ ផល្លះ មានអត្តលេខ៥៨៣ លោកបានដាក់លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរួចហើយ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលមានលេខឯកសារ E2/15/1 បាទ និងយើងមានសហមេធាវីអន្តរជាតិមួយរូបទៀត ដែលគាត់ពុំទាន់បានទទួលស្គាល់ជាលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះនៅឡើយគឺលោក ម៉ះដេវ ម៉ូហាន គាត់ជាជនជាតិសិង្ហបូរី ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុមមេធាវីអាសេសធូចាស្មិកអាស៊ា។

[០៩:០៩:៥៥]

សូមជម្រាបអង្គជំនុំជម្រះផងដែរថា លោក ម៉ះដេវ ម៉ូហាន បច្ចុប្បន្ននេះជាសមាជិកគណៈមេធាវីសិង្ហបូរី ហើយលោកក៏ជាមេធាវីនៅក្នុងតុលាការកំពូលសិង្ហបូរី។ លោកត្រូវបានគណៈមេធាវីនៃព្រះរាជណាចក្រកម្ពុជាទទួលឲ្យធ្វើជាមេធាវីនៅក្នុងក្របខ័ណ្ឌ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ និងបានធ្វើសច្ចាប្រណិធានរួចហើយនៅចំពោះមុខសាលាឧទ្ធរណ៍ នៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី២៨ ខែ១១ ឆ្នាំ២០០៨។ ហេតុដូច្នេះក្នុងនាមសហមេធាវីជាតិនាំមុខ ខ្ញុំសូមស្នើសុំលោកប្រធានមេត្តាទទួលស្គាល់ សហមេធាវីអន្តរជាតិតំណាងដើម

បណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីឲ្យលោកមានសិទ្ធិក្នុងការបំពេញកិច្ចការតំណាងផ្លូវច្បាប់ ជូនកូនក្តីរបស់ខ្លួននៅចំពោះមុខ អ.វ.ត.ក។ សូមអរគុណលោកប្រធាន។

[០៩:១០:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក ម៉ះដេវ ម៉ូហាន! សូមអញ្ជើញក្រោកឈរ!

លោក ម៉ះដេវ ម៉ូហាន ឥឡូវនេះអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់គោលបំណង នៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តីនេះ។ អនុលោមតាមការទទួលស្គាល់នេះ លោកមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។

សូមលោកអង្គុយចុះ!

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកា ជូនទៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសាជាថ្មីម្តងទៀត។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** សួស្តីលោកស្រី អោ រី។ ខ្ញុំសូមធ្វើការបន្តសំណួររបស់ខ្ញុំតទៅទៀត។ មុននឹងធ្វើការបន្តសំណួរ ខ្ញុំធ្វើការបញ្ជាក់ជាមួយនឹងលោកស្រី ដែលកាលពីម្សិលមិញលោកស្រីបានឆ្លើយនូវចំណុចមួយចំនួនដែលក្នុងនោះ ខ្ញុំនៅមានចម្ងល់មួយចំនួនពាក់ព័ន្ធជាមួយនឹងស្ថានភាពនៅមន្ទីរពេទ្យធំ។

[០៩:១២:២០]

កាលពីម្សិលមិញលោកស្រីបានជម្រាបអង្គសវនាការថា នៅមន្ទីរពេទ្យធំហ្នឹង លោកស្រីបានកត់សម្គាល់ឃើញថាមានអ្នកជំងឺ មានអ្នករបួសដាច់ដៃដាច់ជើងជាច្រើននាក់ ដែលនៅក្នុងមន្ទីរពេទ្យនោះ។ អ៊ីចឹងខ្ញុំចង់សួរថា អ្នកដែលដាច់ដៃដាច់ជើង និងអ្នករបួសជាច្រើនហ្នឹង តើជាប្រភេទមនុស្សប្រភេទណាដែរ ជាជនស៊ីវិល ឬក៏ជាទាហាន លន់ នល់ ឬក៏ជាទាហានខ្មែរក្រហម?

**លោកស្រី អោ រី៖**

**ឆ៖** ចាស ជនស៊ីវិលទេ អត់មានឃើញខ្មែរក្រហម ក៏គ្មានពួកទាហានអីដែរ។

**ស៖** សូមអរគុណ។ ហើយកាលពីម្សិលមិញលោកស្រីក៏បានលើកឡើង អំពីការជម្លៀសចេញពីផ្ទះរបស់លោកស្រី។ លោកស្រីបានរៀបរាប់ថា ពេលនោះ -- អំឡុងពេលនុំងម្តាយលោកស្រីហ្នឹង គឺជាស្ត្រីសរសៃខ្ចី មានន័យថាគាត់ទើបតែឆ្លងទន្លេហើយ ហើយនិងមានបងស្រីម្នាក់មានរបួស -- ទទួលរងរបួសទៀត។ អ៊ីចឹងខ្ញុំចង់សួរថា ពេលដែលកងទ័ពខ្មែរក្រហមប្រកាសឲ្យក្រុមគ្រួសារលោកស្រីចេញពីផ្ទះហ្នឹង តើពេលហ្នឹងឪពុកម្តាយលោកស្រីហ្នឹងមានបានស្នើសុំគេថា សុំសម្រាកឲ្យព្យាបាលជំងឺឲ្យបានជាសះស្បើយសិន ចាំចេញដែរឬទេ? ហើយបើសិនជាមាននេះ -- មានការស្នើសុំដូច្នោះ តើគេអាច -- គេមានអនុញ្ញាតឲ្យក្រុមគ្រួសាររបស់លោកស្រីហ្នឹង ម្តាយ ក៏ដូចជាបងស្រីហ្នឹងស្នាក់នៅក្នុងផ្ទះហ្នឹងដើម្បីព្យាបាលជំងឺជាមុនសិនដែរ ឬយ៉ាងណាដែរ? សូមលោកស្រីជម្រាបជូនអង្គសវនាការ។

[០៩:១៩:១៩]

**ឆ៖** ចាស ម៉ែខ្ញុំគាត់ថា "គាត់កូនខ្ចី ណាមួយបងរបួសមិនអាចចេញទៅបានទេ"។ ហើយពួកវាឆ្លើយថា "អត់ទេ ចេញតែ ៣ថ្ងៃទេ ឲ្យនឹងវិលត្រឡប់មកវិញហើយ"។

**ស៖** អ៊ីចឹងមានន័យថា គេអត់អនុញ្ញាតឲ្យស្នាក់នៅផ្ទះទេដើម្បីព្យាបាលជំងឺទេ អ៊ីចឹងលោកស្រី?

**ឆ៖** ចាស គេអត់ឲ្យនៅផ្ទះទេ ព្រោះគេបោសសម្អាតទីក្រុងភ្នំពេញ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោកស្រីពាក់ព័ន្ធជាមួយនឹងទិដ្ឋភាពនៅកន្លែង ដែលលោកស្រីត្រូវឡើងរថយន្តបន្តទៅទៀត។ អ៊ីចឹងខ្ញុំចង់សួរថា អំឡុងពេលនុំងតើមានរថយន្តដែលរង់ចាំទទួលមនុស្សដែលចុះពីលើកប៉ាល់ហ្នឹងមានច្រើនដែរឬទេ? មានចំនួនប៉ុន្មានដែរ លោកស្រីអាចចាំបានឬទេ?

**ឆ៖** ចាស ខ្ញុំឃើញឡាននុំង ខ្ញុំឃើញតែឡានមែន ប៉ុន្តែមិនដឹងឡានប៉ុន្មាន ខ្ញុំមិនដឹងទេ ព្រោះឡានមួយ ពេញមួយចេញមួយៗ។

**ស៖** តើអំឡុងពេលហ្នឹងឡានដែលពេញមួយចេញមួយហ្នឹង នៅក្នុងឡានមួយគេអាចផ្ទុកមនុស្សបានចំនួនប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បានច្រើនដែរ។ ខ្ញុំឃើញពេញៗឡាន បានច្រើនដែរ ខ្ញុំមិនអាចដឹងថាប៉ុន្មាននាក់ៗ ខ្ញុំអត់ដឹងដែរ ប៉ុន្តែឃើញឡានហ្នឹងវាធំៗដែរ។ ឃើញឲ្យតែពេញឡាន គេចេញ។

[០៩:១៦:២៤]

**ស៖** អ៊ីចឹងខ្ញុំចង់បន្តសំណួរទៀតថា ពេលនុ៎ងអ្នកដែលខាងទាហានខ្មែរ -- អ្នកដែលបើកឡានហ្នឹងមានគ្នាប៉ុន្មាននាក់? អ្នកដែលខាងកងទ័ព ឬក៏មេកងខាងខ្មែរក្រហមមានគ្នាប៉ុន្មាននាក់ដែរនៅលើឡាននុ៎ងនីមួយៗហ្នឹង?

**ឆ៖** មានគ្នាបួននាក់។ មានតែកុងឡាននៅអង្គុយ អាព្រូឡាននៅជាប់មួយ ពីរ ពីរនាក់ទៀតនៅក្នុងឡាននៅជាមួយពួកខ្ញុំ។

**ស៖** តើៗអ្នកដែលនៅលើឡានជាមួយនឹងខាងក្រុមរបស់មនុស្ស ដែលនៅលើឡានហ្នឹង តើមានកាន់ឧបករណ៍អ្វី ឬក៏មានប្រដាប់អាវុធអីដើម្បីនៅលើឡាននោះដែរឬទេ?

**ឆ៖** មានកាន់កាំភ្លើងពីរដើម ក្នុងម្នាក់កាន់មួយដើម ម្នាក់កាន់មួយដើម។

**ស៖** តើលោកស្រីមានដឹងទេថា តើឡាននោះគេដឹករបស់ -- ដឹកក្រុមលោកស្រីហ្នឹង ដឹកគ្រួសារលោកស្រី ក៏ដូចជាមនុស្សដទៃទៀតហ្នឹងទៅណាដែរ?

[០៩:១៨:០០]

**ឆ៖** ម៉ែខ្ញុំគាត់ឆ្លើយ -- គាត់ថា គាត់សួរដែរ គាត់សួរថា "យកខ្ញុំទៅទីក្រុងភ្នំពេញ ឬមិនមែនទេ?" គាត់ថា "មិនបាច់ចង់ដឹងអីទេ ឡើងតែឡានទៅ គេដាក់ត្រឹមណា ត្រឹមនុ៎ងហើយ!"។

**ស៖** តើលោកស្រីធ្វើដំណើរតាមឡានរយៈពេលប៉ុន្មានថ្ងៃ ទើបបានទៅដល់កន្លែងដែលគេតម្រូវឱ្យទៅនោះ?

**ឆ៖** ទៅ១ថ្ងៃទេ ខ្ញុំទៅដល់ពោធិ៍សាត់ហ្នឹងតែ១ថ្ងៃទេ។ ទៅដល់ល្ងាចហើយ មានរទេះគោគេមកទទួល។

**ស៖** តើលោកស្រីមានដឹងឬទេ ថាតើរទេះគោហ្នឹងគេចាំទទួលយកទៅណាដែរ?

**ឆ៖** គេយកទៅដាក់តាមភូមិ។ តាមភូមិ រទេះគោណាគេនៅភូមិណា គេទៅភូមិនុ៎ងទៅ ហើយខ្ញុំហ្នឹង គ្រួសារខ្ញុំគេយកទៅភូមិ គេហៅថា ភូមិចម្ការតាប៉ូ។

**ស៖** តើពេលហ្នឹងគេធ្វើការបែងចែកប្រជាជនយ៉ាងម៉េចដែរ ពេលទៅដល់ក្នុងស្រុកភូមិហ្នឹង? តើក្រុមគ្រួសាររបស់លោកស្រីតែមួយគត់ដែលទៅភូមិហ្នឹង ឬក៏មានក្រុមគ្រួសារដទៃគេទៅដែរ? ហើយគេមានការបែងចែកយ៉ាងម៉េចចំពោះប្រជាជនដែលទើបមកដល់ថ្មីអ៊ីចឹង?

[០៩:១៩:៥៦]

**ឆ៖** ចាស ទៅច្រើនគ្នាណាស់ មិនមែនតែគ្រួសារខ្ញុំហ្នឹងទេ គ្រួសារគេដទៃទៀតក៏ទៅដែរ។ ទៅ

បាន៤, ៥ថ្ងៃ គេបែងចែកអស់ហើយ បងដោយបង ប្អូនដោយប្អូន ឪពុកដោយឪពុក ម្ដាយដោយម្ដាយ។ បែកគ្នាអស់ហើយ ទៅធ្វើការរៀងៗខ្លួន។

**ស៖** អ៊ីចឹងគេរៀបចំឲ្យក្រុមគ្រួសារលោកស្រីស្នាក់នៅឯណា -- យ៉ាងម៉េចដែរពេលនុ៎ង?

**ឆ៖** មានគេធ្វើផ្ទះទុកឲ្យរួចស្រេច ផ្ទះល្វែង គេកាន់ -- ខណ្ឌមួយបន្ទប់ៗ។

**ស៖** ផ្ទះល្វែងធ្វើពីថ្ម ឬក៏ធ្វើពីអ្វីដែរ?

**ឆ៖** ធ្វើជាឫស្សី សរសរឫស្សី រនាបក៏ឫស្សី ប្រក់ស្បូវ។

[០៩:២១:១២]

**ស៖** តើពេលហ្នឹងគេមានការបែងចែករវាងមូលដ្ឋានចាស់ និងមូលដ្ឋានថ្មីទេនៅទីនោះ?

**ឆ៖** ចាស គេបែងចែក។ មូលដ្ឋានចាស់គេនៅផ្ទះធម្មតាទៅ ចំណែកឯមូលដ្ឋានថ្មីចេញមកនៅផ្ទះល្វែងហ្នឹងទាំងអស់គ្នា។

**ស៖** ទាក់ទងទៅនឹងរបបនៃការហូបចុក តើពេលនុ៎ងគេផ្ដល់ឲ្យដល់ក្រុមគ្រួសារលោកស្រីយ៉ាងម៉េចដែរ?

**ឆ៖** ទៅដល់ដំបូងបានហូបបាយមួយពេលក្នុង១ថ្ងៃ ល្ងាចឡើងបបរ។ បាន៣ថ្ងៃហ្នឹង ហូបបាយបានបីពេលដែរ ល្ងាចៗឡើងបបរ។

**ស៖** តើលោកស្រីបន្តការហូបអ៊ីចឹងរហូតដល់បែករបប ប៉ុល ពត តែម្ដង ឬក៏យ៉ាងម៉េច?

**ឆ៖** អត់ទេ។ ពេលទៅដំបូងហូបបានតែប៉ុណ្ណឹងទេ ដល់តែពេលយូរៗហូបបបររាវចែកគ្នា ក្នុងម្នាក់បានមួយវែកត្រឡោក។

**ស៖** តើការហូបចុកហ្នឹងគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! លោកស្រីឆ្លើយ!

**លោកស្រី អោ រី៖**

**ឆ៖** ហូបអត់គ្រប់គ្រាន់ទេ។ ក្នុងមួយនាក់មួយវែកត្រឡោក ចំណែកឯម្ដាយខ្ញុំ គាត់ហូប កូនគាត់កូននៅខ្ចី ហូបមិនដែលឆ្អែតទេ មានតែខ្ញុំរំលែករបបរបស់ខ្ញុំយកទៅឲ្យគាត់ពិសា។

[០៩:២៣:៤០]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ករណីម្ដាយរបស់លោកស្រីដែលសរសៃខ្ចីអ៊ីចឹង អ៊ីចឹងខ្ញុំចង់សួរថា ពេលនុ៎ងមានការយកចិត្តទុកដាក់ពីអ្នកស្រុកអ្នកភូមិ ដែលគេចាំទទួលដែរឬទេ? គេមានយកចិត្តទុកដាក់ក្នុងការជួយគាត់ទេ ពីព្រោះអី បើគិតទៅគាត់ជាមនុស្សសរសៃខ្ចី ស្ថានភាពរបស់គាត់វាមានការ លក្ខណៈខុសពីមនុស្សធម្មតា។ អ៊ីចឹងនៅពេលនុ៎ងមានការយកចិត្តទុកដាក់ពីអ្នកភូមិ ឬក៏ពីខាងមេកង មេ -- អ្នកគ្រប់គ្រងនៅទីនោះដែរឬទេ?

**ឆ៖** គេចាត់តាំងគាត់ឲ្យគាត់ទៅនៅកន្លែងវែងអង្ករ ១ គេថាទៅទីនុ៎ងហើយធូរកម្លាំងបន្តិច។ តាមការពិត វែងយូរៗទាស់។ វែងមួយថ្ងៃៗទាល់ល្ងាច ហូបមិនដែលឆ្អែត នៅដល់កន្លែងអង្ករហើយក៏នៅតែហូបមិនឆ្អែតទៀត។

**ស៖** សូមអរគុណ និងសូមបន្តសំណួរទៀត។ ខ្ញុំចង់សួរថា តើក្រុមគ្រួសាររបស់លោកស្រីហ្នឹងមានជួបប្រទះនឹង -- ឬក៏ទទួលរងទុក្ខវេទនាដែរឬទេ នៅអំឡុងពេលដែលរស់នៅទីនោះ? សូមលោកស្រីជួយរៀបរាប់ បើសិនជាមានការទទួលរងទុក្ខវេទនា តើទុក្ខវេទនាហ្នឹងយ៉ាងម៉េចដែរ? សូមជួយរៀបរាប់ជូនអង្គសវនាការ?

**ឆ៖** ចំណែករូប--

[០៩:២៥:១៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបជូនហើយ ការទុក្ខវេទនាដើមបណ្ដឹងរដ្ឋប្បវេណីមានឱកាសនៅក្នុងការធ្វើសេចក្ដីថ្លែងចុងក្រោយបង្អស់របស់ខ្លួន ហើយអង្គជំនុំជម្រះសូមរំឭកថា កិច្ចដំណើរការសវនាការនេះ គឺអង្គហេតុដែលពាក់ព័ន្ធ ដែលត្រូវធ្វើសវនាការគឺជម្លៀសទី១ និងជម្លៀសទី២។ ការជម្លៀសនេះ គឺការសម្រេចនៃការជម្លៀសចេញ ហើយនិងទៅដល់គោលដៅក្នុងរយៈពេលខ្លី ពាក់ព័ន្ធទៅនឹងការទៅដល់ ហើយរយៈពេលខ្លីជុំវិញនៃការទៅដល់តាំងទីលំនៅចុងក្រោយនៃការអនុវត្តគោលការណ៍ គោលនយោបាយជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២។ នេះសូមឲ្យចាំច្បាស់។

សាក្សីមិនបាច់ឆ្លើយទេសំណួរអម្បាញ់មិញនេះ! ចាំពេលវេលាចុងក្រោយ អង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅលោកស្រី ដើម្បីធ្វើសេចក្ដីថ្លែងរាប់អំពីទុក្ខសោកវេទនា និងផលប៉ះពាល់ អន្តរាយចំពោះលោកស្រីជាក់ស្ដែង។ ហើយអង្គជំនុំជម្រះបានជម្រាបតាំងពីដើមទីរួចហើយអំពីសិទ្ធិនៅក្នុងការធ្វើ

សេចក្ដីថ្លែងដូចនេះ។

[០៩:២៦:៣៦]

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធានដែលបានជួយរំឭក ទាក់ទងទៅនឹងសំណួរដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលបានកំណត់នៅក្នុងវិសាលភាពដែលត្រូវសាកសួរ។ ទាក់ទងទៅនឹងចំណុចនេះដែរ គ្រាន់តែនាងខ្ញុំសូមទាញសំណួរខ្លះៗ ពាក់ព័ន្ធជាមួយនឹងការដែលលោកស្រីទៅដល់មូលដ្ឋានដំណាក់កាលដំបូងថាតើលោកស្រីមានជួបប្រទះនូវបញ្ហាអ្វីខ្លះ។ ហើយខ្ញុំនឹងរៀបចំកែប្រែនូវសំណួររបស់ខ្ញុំ ដើម្បីទាញឲ្យពាក់ព័ន្ធជាមួយនឹងស្ថានភាពនៅក្នុងការរស់នៅនៅទីនោះ នៅពេលដែលលោកស្រីទៅដល់ដំបូង។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកស្រីទាក់ទងទៅនឹងរបបអាហារម្ដងទៀត ថាតើនៅពេលនោះគេមានការបែងចែករបបអាហាររវាងពួកមូលដ្ឋានចាស់ និងប្រជាជនថ្មីដូចគ្នា ឬក៏ខុសគ្នា?

**លោកស្រី អោ រី៖**

**ឆ៖** របបមូលដ្ឋានចាស់ហ្នឹងហូបជាមួយតែគ្នាទេ ព្រោះធ្វើដែលរោងបាយតែមួយមកពីធ្វើការទាំងអស់គ្នា ហូបជាមួយគ្នាទេ គ្រាន់តែថាគេបានទីលំនៅនៅស្រួល។ ពួកខ្ញុំនៅដោយសារទាំងលំបាក។

[០៩:២៨:១៤]

**ស៖** ចុះទាក់ទងទៅនឹងការបែងចែកការងារវិញ តើរវាងមូលដ្ឋានចាស់ និងមូលដ្ឋានថ្មីគេធ្វើការបែងចែកយ៉ាងដូចម្ដេចដែរ?

**ឆ៖** ចេញធ្វើការដូចតែគ្នាដែរ ចេញធ្វើការដូចគ្នា។

**ស៖** តើនៅពេលទៅដល់ទីនោះដំបូង តើមានការធ្វើការចុះជំរឿន ឬក៏ចុះស្ថិតិសម្រាប់ក្រុមគ្រួសាររបស់លោកស្រីដែលស្នាក់នៅទីនោះដែរឬទេ?

**ឆ៖** ទៅដល់ ម្ដាយខ្ញុំគេឲ្យរែងអង្ករ ម្ដាយស្រីខ្ញុំរបួសប៉ុណ្ណឹងហើយ គេឲ្យទៅជួយដុតភ្លើងដាំបាយ ដាំបបរហ្នឹងគេ។ ចំណែកឯរូបខ្ញុំទៅកាប់ទន្រ្ទានខែត្រធ្វើជី។ ចំណែកបងប្រុសខ្ញុំ គាត់ទៅលើកភ្លឺ។

**ស៖** ទាក់ទងទៅនឹងការរស់នៅទីនោះ តើក្រុមគ្រួសារលោកស្រីហ្នឹងមានជួបនូវហេតុការណ៍អ្វីដែលគួរឲ្យកត់សម្គាល់ដែរឬទេ?

[០៩:៣០:០៣]

**ឆ៖** ទៅធ្វើការបើមិនទាន់គេ គេទិតៀនៗ ចំណែកម្ដាយខ្ញុំគាត់ទៅធ្វើការមួយថ្ងៃៗទាល់ល្ងាច។ ពេលគាត់នឹកឃើញកូនតូចៗនៅផ្ទះ គាត់ត្រឡប់មកផ្ទះអើតមើលកូនបន្តិច។ គេយកគាត់ដាក់គុកស៊ីរ៉ូ បង្អត់បាយគាត់១អាទិត្យ។

**ស៖** តើលោកស្រីមានដឹងថាមូលហេតុអីបានជាគេយកម្ដាយរបស់លោកស្រីហ្នឹងទៅដាក់គុក?

**ប្រធានអង្គជំនុំ៖**

មានបញ្ហាបកប្រែភាសា។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងផ្នែកបកប្រែភាសា!

[០៩:៣១:១៨]

*(មានបញ្ហាបច្ចេកទេស)*

[០៩:៣៣:១៩]

បាទ សូមអញ្ជើញបន្ត! ហើយមេធាវីតាំងសំណួរគាត់ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីសាជាថ្មីម្ដងទៀត ទំនងជាគាត់ភ្លេចហើយ។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** សំណួររបស់ខ្ញុំចង់សួរថា តើលោកស្រីមានដឹងអំពីមូលហេតុអ្វីបានជាគេចាប់ឪពុកម្ដាយរបស់លោកស្រីដាក់គុកដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សួស្ដីតំណាងអយ្យការ សួស្ដីសហព្រះរាជអាជ្ញា សួស្ដីលោកអ្នកទាំងឡាយចូលរួមសាលសវនាការនេះ នៅក្នុងបន្ទប់ឬនៅក្រៅបន្ទប់ក្ដី។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ ដោយថាសំណួរនេះវាចូលជ្រៅ ហើយប្រាសចាកចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១ ទៅហើយ។ បើសិនជាអ្នកស្រីមេធាវីបញ្ជាក់ពេលវេលាខ្លះក្រែងលោវាជាប់ វានៅកិត

កៀកនឹងពេលវេលានៃការជម្លៀសលើកទី១ លើកទី២ ហ្នឹងជាមិនបញ្ហាទេ។ ប៉ុន្តែ អានេះហាក់ដូចជាចូលជ្រៅ ទៅដល់ក្នុងប្រតិបត្តិការនៃមន្ទីរសន្តិសុខទៅហើយ ដែលក្នុងបញ្ញត្តិដីកា E124 របស់យើងមិនអនុញ្ញាតទេ។ សូមអរគុណ។

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសូមធ្វើការឆ្លើយតបជាមួយនឹងអំណះអំណាងដែលលើកឡើងដោយមេធាវីការពារក្តី។ ខ្ញុំយល់ឃើញថា ពាក់ព័ន្ធជាមួយនឹងសំណួរអម្បាញ់មិញនេះ គឺជាសំណួរដែលមានការពាក់ព័ន្ធគ្នា ពីព្រោះដោយសារតែអង្គហេតុ នៃការជម្លៀសហ្នឹង វាមានទំនាក់ទំនងគ្នាតាំងពីដំណាក់កាលទី១ ទី២ រហូតទៅដល់លោកស្រីត្រូវបានគេបញ្ជូនទៅដល់លំនៅដ្ឋានមួយ នៅខេត្តពោធិ៍សាត់។ អ៊ីចឹងបើសិនជាគ្មានការជម្លៀសពីដំណាក់កាលទី១ ទី២ បើគ្មានការជម្លៀសចេញពីផ្ទះរបស់លោកស្រីទេ សួរថាតើមានអ្វីកើតឡើងចំពោះក្រុមគ្រួសារលោកស្រីដែរឬយ៉ាងណា? នេះជាហេតុផលមួយដែលខ្ញុំស្នើសុំឲ្យមានការបំភ្លឺដល់អង្គជំនុំជម្រះអំពីទុក្ខលំបាក ដែលនៅពេលដែលក្រុមគ្រួសាររបស់លោកស្រីហ្នឹងត្រូវបានគេជម្លៀសចេញ ទៅដល់គោលដៅហើយ ថាតើគាត់ជួបនូវហេតុការណ៍អ្វីខ្លះ? បើសិនជាមិន -- គាត់មិនចេញពីផ្ទះទេ ខាង -- គេមិនត្រូវ គាត់មិនត្រូវបានជម្លៀសចេញទេ សួរថាតើគាត់អាចជួបនឹងហេតុការណ៍ហ្នឹងកើតឡើង ឬអត់ ចំពោះក្រុមគ្រួសាររបស់លោកស្រី។ ហេតុដូច្នេះហើយគ្រាន់តែខ្ញុំស្នើថា ឲ្យលោកស្រីហ្នឹងធ្វើការឆ្លើយទៅនឹងសំណួរនេះ ពីព្រោះវាមានទំនាក់ទំនងគ្នារវាងហេតុ និងផល។ សូមអរគុណ។

[០៩:៣៦:១៣]

**ប្រធានអង្គជំនុំ៖**

លោកស្រីអាចពិនិត្យមើលឡើងវិញ នូវសេចក្តីណែនាំក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការជម្លៀសដំណាក់កាលទី១ និងទី២។ មិនមែនផលទាំងអស់បច្ច័យទាំងអស់កើតឡើងដោយសារជម្លៀសមួយចប់ នៃរបបកម្ពុជាប្រជាធិបតេយ្យសុទ្ធតែជាកម្មវត្ថុ នៃការសួរដេញដោលនៅទីនេះទេ។ ពីព្រោះអង្គជំនុំជម្រះបានកំណត់រួចហើយ អំពីការបំបែកកិច្ចដំណើរការនីតិវិធីពីសំណុំរឿង០០២ កំណត់យកតែសំណុំរឿង០០២/០១ យកមកធ្វើសវនាការពិភាក្សាដេញដោល។ នៅក្នុងសំណុំរឿង០០២/០១ គឺយកដំណាក់កាលជម្លៀសលើកទី១ហើយនិងជម្លៀសលើកទី២។ នៅក្នុងការជម្លៀស -- ពាក់ព័ន្ធនឹងការជម្លៀសនេះ គឺការអនុវត្តគោលនយោបាយ នៃការជម្លៀសតាំងពីដើមដំណាក់កាលធ្វើដំណើរការវិវត្ត នៃការជម្លៀស និងទៅដល់ភ្លាម ទៅដល់គោលដៅភ្លាម។

យើងមិនបកស្រាយអំពីពាក្យថា ភ្លាមហ្នឹង រយៈពេលប៉ុន្មានទេ ប៉ុន្តែយើងប្រើពាក្យ ភ្លាម មានន័យថា មិនឲ្យវិសាលភាព នៃការសួរដេញដោលរហូតដល់២, ៣ឆ្នាំទេ។ បើសិនជាទៅដល់ភ្លាម ហើយ ២ ឬ៣ឆ្នាំនោះ មានន័យថា ការសួរដេញដោលនោះ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យហើយ។ វាផ្ទុយជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានបំបែកកិច្ចដំណើរការនីតិវិធី ពីសំណុំរឿង ០០២ មកធ្វើតែដំណាក់កាលដំបូងនេះ សំណុំរឿង០០២/០១។

មេធាវីៗការពារក្តីគេបានលើកឡើងត្រឹមត្រូវ សុំឲ្យស្រីបញ្ជាក់អំពីកាលបរិច្ឆេទ នៃការទៅដល់របស់គាត់ និងគ្រួសាររបស់គាត់ ទៅដល់ខេត្តពោធិ៍សាត់ ទៅដល់គោលដៅ ហើយនិងកាលបរិច្ឆេទនៃការដែលម្តាយរបស់គាត់ត្រូវគេចាប់យកទៅឃុំខ្លួននៅមន្ទីរសន្តិសុខ។ នេះដើម្បីច្បាស់លាស់ថា បើកាលបរិច្ឆេទនេះវាឃ្លាតឆ្ងាយគ្នាកម្រិតណា។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[០៩:៣៨:២៧]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ តើវាជាការត្រឹមត្រូវដែរឬទេ ខ្ញុំស្តាប់ទៅវាដូចជាការបន្ទោស ឬក៏ការ ដូចជាការពន្លៀស--

**ប្រធានអង្គជំនុំ៖**

លោកមានបញ្ហាអីទេ? យើងមានបញ្ហា យើងដោះស្រាយលើបញ្ហានេះ ដូចមិនពាក់ព័ន្ធអីជាមួយលោកទេ។ យើងដោះស្រាយលើសេចក្តីជំទាស់ កត់សម្គាល់របស់មេធាវីការពារក្តីលោក អៀង សារី ទៅនឹងការតាំងសំណួរ ហើយមេធាវីការពារក្តីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរឲ្យយើងបកស្រាយបញ្ជាក់ឡើងវិញ អំពីវិសាលភាពនៃការខ្លួនដែលមានសិទ្ធិក្នុងការពិភាក្សាដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណី លើវិសាលភាពអង្គហេតុណាខ្លះក្នុងកម្រិតណា។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

យើងមិនដឹងថា លោកមានហេតុផលម៉េចបានជាលោកមកធ្វើអន្តរាគមន៍ អំពីការបកស្រាយរបស់យើង ហើយចំពោះគោលដៅផ្សេងរបស់ភាគីផ្សេង។ ភាគីដែលមានការពាក់ព័ន្ធនៅបញ្ហានេះ ដូច

ជាគេអត់មានប្រតិកម្មអីទេ។ ទាំងពីរ ទាំងអ្នកជំទាស់ ទាំងអ្នកដែលស្នើសុំឱ្យយើងបញ្ជាក់បញ្ហានេះ ដូចគេអត់មានបញ្ហាប្រតិកម្មអីទេ បែរជាលោកអង្គុយស្តាប់នេះ អត់មានពាក់ព័ន្ធនឹងបញ្ហាប្រឈមជំទាស់នេះផង បែរជាលោកមានប្រតិកម្មឡើងវិញ -- ទៅវិញ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

យើងគិតថាលោកមេធាវីមិនមានគុណភាពវិនិច្ឆ័យយើងថា យើងខុស ឬក៏យើងត្រូវនោះទេ។ អង្គុយចុះ!

សូមអញ្ជើញលោកស្រីមេធាវី!

[០៩:៤០:២៨]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធានដែលបានរំឭក។ ខ្ញុំនឹងធ្វើការសម្រួលនូវសំណួររបស់ខ្ញុំឡើងវិញម្តងទៀត។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** លោកស្រីបានលើកឡើងថា ម្តាយរបស់លោកស្រីហ្នឹងត្រូវបានគេចាប់ដាក់គុក។ តើពេលដែលគេចាប់ដាក់គុកហ្នឹង គេ -- ពេលដែលម្តាយលោកស្រីហ្នឹងទៅដល់ខេត្តពោធិ៍សាត់ហ្នឹងភ្លាមៗ ឬក៏យ៉ាង -- ឬក៏នៅពេលណាដែរ?

**លោកស្រី អោ រី៖**

**ឆ៖** គាត់គេចាត់តាំងឱ្យគាត់ទៅធ្វើការមួយរយៈហើយ មិនមែនទៅដល់ភ្លាមៗទេ។ ទៅធ្វើការហ្នឹងមួយរយៈធំដែរហើយ។

**ស៖** ខ្ញុំសូមសួរលោកស្រីបកបន្តិចទាក់ទងទៅនឹងការធ្វើដំណើរ ពេលដែលលោកស្រី និងក្រុមគ្រួសារហ្នឹងធ្វើដំណើរចេញពីស្រុកកំណើត ចេញពីផ្ទះនៅទីក្រុងភ្នំពេញ ក៏ដូចជាចេញពីស្រុកកំណើតបន្តមកដល់ខេត្តពោធិ៍សាត់។ តើក្រុមគ្រួសាររបស់លោកស្រីហ្នឹង មានជួបប្រទះនឹងស្ថានភាពលំបាក ឬក៏មានភាពងាយស្រួលនៅក្នុងការធ្វើដំណើរនោះ?

[០៩:៤២:០៦]

**ឆ៖** ខ្ញុំចេញពីស្រុកមកមានការលំបាកណាស់ ព្រោះវាអត់មានអីហូប មានតែនំប័ុងមួយ ចេញពីផ្ទះមកមានចែកតែនំប័ុងមួយរហូតមកដល់ខេត្តពោធិ៍សាត់។

**ស៖** ពេលដែលគេជម្លៀសក្រុមគ្រួសារលោកស្រីពីទីក្រុងភ្នំពេញ រហូតដល់មានការជម្លៀសពីស្រុកកំណើតទៅទៀត តើពេលហ្នឹងគេមានប្រាប់អំពីហេតុផល ឬក៏មូលហេតុនៃការជម្លៀសក្រុមគ្រួសារលោកស្រី ក៏ដូចជាអ្នកដទៃពីលំនៅ -- ពីមួយកន្លែងទៅមួយកន្លែង គេមានប្រាប់ហេតុផលដែរ ឬទេថា មូលហេតុអីបានជាគេធ្វើការជម្លៀសដូច្នេះ?

**ឆ៖** គេថាទាល់តែពួកថ្មីបានគេឲ្យចេញពីស្រុកកំណើតមក ពួកថ្មីគេឲ្យចេញហើយ គេមិនអាចឲ្យនៅបានទេ។ សូម្បីតែបងខ្ញុំឈឺ សុំគេនៅឲ្យនៅជាមួយជីដូនមួយក៏គេមិនឲ្យនៅដែរ គេឲ្យចេញទាំងអស់គ្នា គ្មានឲ្យពីណានៅក្នុងស្រុកទេ។

**ស៖** តើតាមផ្លូវនៅក្នុងការធ្វើដំណើរនុ៎ងមានប្រជាជន ឬក៏មាន -- លោកស្រីមានកត់សម្គាល់ឃើញថាមានប្រជាជន ឬក៏មានក្រុម -- សមាជិកក្រុមគ្រួសារលោកស្រីហ្នឹងស្លាប់ ឬក៏មានការស្លាប់ ឬក៏ឈឺតាមផ្លូវអីដែរឬទេ?

[០៩:៤៤:៣២]

**ឆ៖** មានអ្នកឈឺ ព្រោះត្រង់ស្លាប់ ខ្ញុំអត់បានឃើញទេ បើអ្នកឈឺមាន។ មកទាំងបង្ខំអ្នកឈឺក៏ដោយ ក៏គេមកដែរ សូម្បីតែបងខ្ញុំគ្រាមករហូត។

**ស៖** តើនៅពេលដែលមានអ្នកឈឺដូច្នេះ តើមានការយកចិត្តទុកដាក់នៅក្នុងការមើលថែពីខាងមេកង ឬក៏កងឈ្លបនៅ -- ដែលជូនដំណើរមកហ្នឹងដែរឬទេ?

**ឆ៖** គ្មានអ្នកណាមើលទេ ឈឺយ៉ាងម៉េចក៏ដោយក៏គ្មានអ្នកណាមើលដែរ មានតែគេបង្ខំឲ្យទៅឲ្យស្រួតៗ ឲ្យឆាប់ដល់គោលដៅ។

**ស៖** នៅពេលដែលទៅដល់ខេត្តពោធិ៍សាត់ លោកស្រីបានលើកឡើងអម្បាញ់មិញថា ការហូបចុកមិនគ្រប់គ្រាន់។ តើនៅពេលដែលលោកស្រីហូបចុកមិនគ្រប់គ្រាន់ហ្នឹង លោកស្រីមានបានប្រើ រកវិធីសាស្ត្រដើម្បីបង្គ្រប់ការហូបចុករបស់លោកស្រីនៅពេលនោះទេ? តើលោកស្រីអាចស្នើសុំរបបអាហារគេបន្ថែម ដើម្បីឲ្យមានការហូបចុកគ្រប់គ្រាន់ដែរឬទេនៅពេលនោះ?

[០៩:៤៦:០៧]

**ឆ៖** អត់មានទេ គឺគេចែកឲ្យ កំណត់ឲ្យ ប៉ុនណាប៉ុននុ៎ងហើយ ទោះបីឆ្អែតមិនឆ្អែតក៏គេមិនដឹង

ដែរ។ បើយើងមិនឆ្អែត ខ្ញុំដើររើសនេះរើសនោះ ឲ្យតែបានចម្អែតក្រពះ។ ថ្នាក់ខ្ញុំស៊ីកំពឹសឆៅ ត្រីឆៅ ឲ្យតែបានឆ្អែត។

**ស៖** លោកស្រីបានលើកឡើងថា ម្ដាយលោកស្រីហ្នឹងត្រូវបានអត់ឃ្លាននៅពេលនោះដែរ ហើយលោកស្រីបានយករបបរបស់លោកស្រីហ្នឹងទៅឲ្យគាត់។ តើពេលដែលលោកស្រីយករបបអាហាររបស់លោកស្រីឲ្យទៅគាត់ហ្នឹង តើគេអនុញ្ញាតឲ្យធ្វើដូច្នេះដែរ ឬក៏ម៉េច?

**ឆ៖** អត់ទេ គេមិនអនុញ្ញាតឲ្យខ្ញុំមកទេ ប៉ុន្តែខ្ញុំអាណិតម្ដាយពេក ខ្ញុំលួចរត់មក ព្រោះខ្ញុំថាបើគេទាន់ត្រង់ណា គេសម្លាប់ចោលត្រង់នុ៎ង ក៏ខ្ញុំអស់ចិត្តដែរ។ ខ្ញុំមក លួចមកទាំងយប់ មកដល់ម្ដាយ ម្ដាយយំស្រែក ថាកូនអើយ! បើគេទាន់គេវ៉ៃកូនឯងងាប់ហើយ។ ប៉ុន្តែម៉ាក់ឯងកុំមាត់! បើគេវ៉ៃខ្ញុំក៏វ៉ៃទៅចុះ។ ប៉ុន្តែខ្ញុំរត់មក គ្រាន់តែមកជួបតែម្ដាយមួយភ្លែត ខ្ញុំរត់ទៅវិញ រត់ទាំងយប់ មួយយប់គ្មានបានដេកទេ ដើរតាមផ្លូវខ្មោច ខ្លាចគេឃើញ ចេះតែទៅៗ ក្នុងព្រៃក្នុងផ្សៃហ្នឹង។ សុខចិត្តយករបបខ្ញុំមកឲ្យគាត់ សុខចិត្តចំណែកខ្ញុំ ទៅលួចអូសកំពិស បានមកអកៗ គ្មានស្គាល់ថាឆ្អិន មិនឆ្អិន ឆៅមិនឆៅទេ ព្រោះខ្ញុំអាណិតម្ដាយខ្ញុំពេក។

[០៩:៤៨:១៧]

**ស៖** លោកស្រីបានលើកឡើងថា លោកស្រីតែងរត់លួចយកអាហារទៅផ្គត់ផ្គង់ដល់ម្ដាយ។ ចុះលោកស្រីអត់ខ្លាចថា បើសិនជាករណីដែលគេទាន់ តើគេនឹងធ្វើទារុណកម្មទៅលើលោកស្រីដែរឬទេពេលនុ៎ង?

**ឆ៖** បើសិនជាគេទាន់វិញ គេវ៉ៃខ្ញុំទាល់តែងាប់។ ប៉ុន្តែសំណាងខ្ញុំ គេជាល្អ វាៗមិនទាន់។

**ស៖** អំឡុងពេលដែលលោកស្រីរស់នៅទីនោះ តើមានការធ្វើទារុណកម្មទៅលើលោកស្រី ឬក៏ក្រុមគ្រួសារលោកស្រីដែរឬទេ?

**ឆ៖** អង្គការចាត់តាំងឲ្យខ្ញុំទៅដាំដំឡូង ខ្ញុំទៅដាំដំឡូង ប៉ុន្តែខ្ញុំអត់ចេះដាំ ខ្ញុំដាំបញ្ច្រាស។ ខ្ញុំឱនដាំទៅ វ៉ៃក្បាលខ្ញុំមួយភ្លូកចប ឡើងប្រកាច់ពេញកន្លែងទាំងអស់។ ប៉ុន្តែសំណាងខ្ញុំវាមិនងាប់ មួយស្របក់ខ្ញុំដឹងខ្លួនវិញទៅ។

[០៩:៤៩:៤៦]

**ស៖** ក្រៅពីការធ្វើទារុណកម្មមកលើរូបលោកស្រីផ្ទាល់ តើមានការធ្វើទារុណកម្មទៅលើសមាជិកក្រុមគ្រួសារលោកស្រីដែរឬទេ នៅអំឡុងពេលរស់នៅទីនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមអធ្យាស្រ័យបាទ ដោយសារមើលទៅហាក់ដូចជាខ្ញុំឡើងជំទាស់ច្រើន ប៉ុន្តែអំមិញខ្ញុំឃើញថា រឿងនៅដែលៗទេ ហើយដោយសារតែអង្គហេតុនេះវាទាក់ទងតែរឿងប្រហែលជាទាក់ទងតែរឿងករណីធ្វើទុក្ខបុកម្នេញ បើនិយាយពីការធ្វើទារុណកម្ម ដូចអត់មានឃើញនៅក្នុងដីការបស់យើងនេះទេ។ អ៊ីចឹងវាប្រាសចាកពីដីការបស់យើងហើយ នូវអង្គហេតុដែលកំពុងសួរដេញដោលនេះ។ ខ្ញុំសូមជំទាស់នឹងសំណួរបែបនេះ ហើយនិងសូមលោកស្រីមេធាវី -- លោកប្រធានមេត្តាណែនាំបន្តទៀត។

សូមអរគុណ។

[០៩:៥០:៥១]

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំនឹងធ្វើការរៀបចំសំណួររបស់ខ្ញុំសាឡើងវិញ។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** នៅពេលដែលលោកស្រីទៅរស់នៅខេត្តពោធិ៍សាត់នោះ តើលោកស្រីមានកត់សម្គាល់ដែរឬទេ ថាតើនៅទីនោះមានមនុស្សស្លាប់ ឬក៏ មានមនុស្សស្លាប់ច្រើន -- មានមនុស្សស្លាប់ដែរឬទេ?

**លោកស្រី អោ រី៖**

**ឆ៖** ចាស ខ្ញុំទៅដល់ដំបូងអត់ទាន់មានមនុស្សស្លាប់ទេ។ ទាល់តែបានយូរបន្តិចបានមានមនុស្សស្លាប់បន្តបន្ទាប់ៗគ្នា។ ព្រោះវាអត់អាហារ។

**ស៖** ហេតុអ្វីបានជាលោកស្រីអះអាងថា នៅទី -- ការស្លាប់របស់ប្រជាជននៅទីនោះគឺជាការអត់អាហារទៅវិញ -- ដោយសារមូលហេតុនៃការអត់អាហារ? លោកស្រីមានប្រទះឃើញនូវហេតុការណ៍អ្វី បានជាលោកស្រីប៊ានកំណត់អះអាងដូច្នេះ?

**ឆ៖** ព្រោះចែករបបក្នុងមួយថ្ងៃមួយវែក មានតែបបរាវហូប ហើយទៅធ្វើការរាល់ថ្ងៃ។ ដល់តែពេលឈឺអត់មានអីឲ្យហូប ទៅសុំថ្នាំពេទ្យ មានតែគ្រាប់អាចម៍ទន្សាយយកមកឲ្យលេប ហើយមាននឹងជា -- រោគហ្នឹងវាជាអី វាមានតែស្លាប់។

[០៩:៥២:៤៨]

**ស៖** ក្រៅពីការស្លាប់ដោយសារការអត់អាហារ តើលោកស្រីមានបានកត់សម្គាល់ដែរឬទេ ថា មានការស្លាប់ដោយមូលហេតុអីផ្សេងទៀតដែរឬទេ?

**ឆ៖** ចាស ចំណែកបងប្រុសខ្ញុំផ្ទាល់ គាត់ ប្រពន្ធគាត់ចាញ់កូន គាត់ស្រេកទឹកត្នោត បងខ្ញុំហ្នឹង ទៅឡើងលួចទឹកត្នោតបានមួយក្រេបយកមកឲ្យប្រពន្ធ មកដល់គេចងស្លាបសេកគាត់ ចងៗគាត់យក ទៅសម្លាប់ភ្លាម។

**ស៖** តើលោកស្រីឃើញហេតុការណ៍ហ្នឹងដោយផ្ទាល់ភ្នែក ឬក៏យ៉ាងណាដែរ?

**ឆ៖** ខ្ញុំឃើញនឹងផ្ទាល់ភ្នែក ព្រោះខ្ញុំដើរទៅធ្វើការ ដើរទៅឃើញបងខ្ញុំនៅលើភ្លឺ គេយកភ្លូកចប ទៅសំពងគាត់ មិនដឹងជាប៉ុន្មានភ្លូកចបទេ។ គាត់ស្លាប់។ ខ្ញុំមានចិត្តប្រុងទៅជួយគាត់ ប៉ុន្តែគេទាញខ្ញុំថា កុំទៅ បើឯងទៅ ឯងដឹងតែងាប់ទៀតហើយ។ ដើរចេញពីបងបន្តិច ឆ្លៀតរត់មកប្រាប់ម្តាយ “ម៉ែអើយ បងៗគេសម្លាប់បាត់ទៅហើយ”។ ម្តាយថាមិនជឿទេ។ ខ្ញុំថា ម៉ាក់ឯងមិនជឿម៉េច គេសម្លាប់ហើយ គាត់អស់បានមកផ្ទះទៀតហើយ នៅកណ្តាលវាលស្រែឯណោះ។ ម្តាយខ្ញុំមិនដឹងជាធ្វើយ៉ាងម៉េចមានតែ សម្រក់ទឹកភ្នែក អត់ហ៊ានថា ទៅជួយកូនថាម៉េចទេ មានតែការឈឺចាប់នៅក្នុងខ្លួនគាត់។

**ស៖** អ៊ីចឹងនៅពេលនោះ លោកស្រីមានបានកត់សម្គាល់ដែរឬទេថានរណាជាអ្នកសម្លាប់បង ប្រុសរបស់លោកស្រី?

[០៩:៥៤:៥៨]

**ឆ៖** គេថាមេកង។ ខ្ញុំក៏មិនដឹង ខ្ញុំក៏មិនស្គាល់គេដែរ គេថា គេមេកង ថាបងខ្ញុំហ្នឹងចក្រពត្តិ។

**ស៖** ក្រៅពីការសម្លាប់បងប្រុសរបស់លោកស្រី តើមានការសម្លាប់ប្រជាជននៅក្នុងតំបន់នោះ ដែរឬទេ?

**ឆ៖** ចុងក្រោយមកទៀត បានបានមានឃើញសម្លាប់ប្រជាជន។ មិនត្រឹមសម្លាប់ប្រជាជនទេ ក្រុមគ្រួសារខ្ញុំទាំងអស់ មួយពូជសម្លាប់នៅក្នុងថ្លុក មួយពូជស្លាប់មួយថ្លុក នៅសល់តែខ្ញុំមួយ និងប្អូន ប្រុសមួយ លើកដៃសំពះអង្វរគេ ពូអើយកុំសម្លាប់ម្តាយខ្ញុំអី។ គេមិនអនុគ្រោះទេ ថា “ឯង! ថយចេញ ឯងគង់តែងាប់តាមក្រោយទៀតទេ”។ គេដេញខ្ញុំថយចេញពីថ្លុកឈាមម្តាយខ្ញុំ ក៏ខ្ញុំចេញមកបានម្ភៃ ប្រហែលជា២០ម៉ែត្រ ខ្ញុំឮប្អូនខ្ញុំស្រែកយំ អាតូចនៅបៅដោះឮស្រែកយំ ខ្ញុំស្ទុះត្រឡប់ទៅវិញៗ ខ្ញុំថា “ពូ អើយ ខ្ញុំសុំប្អូនខ្ញុំវិញមក ឲ្យប្អូនខ្ញុំមកខ្ញុំមក”។ គាត់មិនបោះមក ក៏មិនបោះឲ្យខ្ញុំទេ គាត់បោះឡើងទៅលើ

ចាក់នឹងជំពុះទង់នៅនឹងមុខខ្ញុំ។ ខ្ញុំលុតជង្គង់គ្រឹប។ គាត់ថា “ង៉ែងងើបឲ្យស្រួតទៅ ព្រោះង៉ែងគង់តែស្អែក ង៉ែងងាប់ទៀតទេ។ អញសម្លាប់ង៉ែងឲ្យអស់ពូជ ទុកង៉ែងនាំតែសងសឹកទេ”។ ហើយសម្លាប់ខ្ញុំតាមសម្លាប់ខ្ញុំ។ មួយយប់ហ្នឹងហើយ ព្រលឹមឡើង ខ្ញុំទៅនៅជិតគេ គេអត់ឲ្យខ្ញុំនៅជិតទេ។ គេដេញខ្ញុំ “ង៉ែងកុំទៅជិតអញ ប្រយ័ត្នគេមកបាញ់ខ្ទាតគ្រាប់លើគេ”។

[០៩:៥៧:៥២]

ខ្ញុំក៏នាំប្អូនប្រុសម្នាក់ដើរចេញពីគេហ្នឹង។ រូបខ្ញុំក៏ត្រូវដែរ អំបែងនៅកំប៉េះក្លិត ទើបតែយកចេញប៉ុន្មានឆ្នាំហ្នឹងទេ។ ខ្ញុំគ្របម្តាយខ្ញុំ វាបាញ់ទៅ វាសើកំប៉េះក្លិតខ្ញុំ ខ្ញុំគ្រប ខ្ញុំស្មានតែម៉ែខ្ញុំមិនទាន់ស្លាប់។ ខ្ញុំងើបឡើងគ្របម្តាយខ្ញុំ។ ដល់តែពេល មីងខ្ញុំគាត់ត្រូវជើង ដាច់កជើង គាត់ស្រែក គាត់ថា “អស់លោកអើយ ម៉េចបានមកសម្លាប់ក្រុមគ្រួសារខ្ញុំ។ គ្រួសារខ្ញុំហ្នឹងមានរឿងអី ខំតស៊ូប៉ុន្មានឆ្នាំហើយ ហេតុអីបានមកសម្លាប់ក្រុមគ្រួសារខ្ញុំអស់រលីងអ៊ីចឹង?”។ វាថា “អ៊ឺ បើសម្លាប់ហើយៗ កុំបាច់តវ៉ា” ហើយវាក៏ដេញខ្ញុំចេញទៅទៀតទៅ។ ដេញខ្ញុំចេញ ក៏ខ្ញុំហ្នឹងចេញទៅនៅវាលស្រែ បានពេលព្រលឹមឡើង ប្អូនខ្ញុំវាឃ្លានខ្លាំងពេក ខ្ញុំក៏ទៅរកសុំអង្ករគេបានពីរបីក្តាប់ យកមកឲ្យប្អូន ដាំឲ្យប្អូន។ អត់មានម្ហូបទេ មានតែអំបិលក្តាប់ឲ្យប្អូនហូប។

[០៩:៥៩:១៨]

ចុងក្រោយមកទៀត វាថា វាដើរមក វាថា “នោះវាបងប្អូនវាពីរនាក់នោះ ទៅសម្លាប់វាឲ្យហើយទៅ។ កុំទុកវានៅយូរ នាំវាសងសឹក”។ ខ្ញុំក៏ឃើញពួកវាដើរមក ខ្ញុំយកក្រម៉ាគ្របមុខពីរនាក់បងប្អូនឱបគ្នាជាប់លើកដៃ ថា “ពូអើយ បើសម្លាប់ខ្ញុំ ក៏សម្លាប់ទៅចុះ បើខ្ញុំនៅក៏គ្មានន័យអីទៀតដែរ គ្មានគោលដៅអីទេ ខ្ញុំក្លាយជាកូនកំព្រាហើយ ហើយក៏ខ្ញុំអត់មានគោលដៅ គ្មានម៉ែ គ្មានឪណាជួយទំនុកបម្រុងខ្ញុំទេ។ ពូអើយសម្លាប់ខ្ញុំចុះ”។ វាយកកាំភ្លើងមកភ្ជុងគុម្ពត្រចៀកខ្ញុំ ពីរនាក់បងប្អូនឱបគ្នាឡើងញ័រអស់ហើយ នឹកថាស្លាប់ៗទាំងពីរនាក់។ ឲ្យវាដាច់ពូជទៅ។ ម្តងហើយម្តងទៀតៗ ប៉ុន្តែជីវិតខ្ញុំវាមិនត្រូវស្លាប់នៅជំនាន់ពួកខ្មែរក្រហមហ្នឹង។ ខ្ញុំប្រឹងតស៊ូដើម្បីចិញ្ចឹមប្អូន ពិបាកវេទនា អត់អាហារ ស្រែកយំតាមផ្លូវ--

**ស៖** ខ្ញុំសូម -- ខ្ញុំពេលលោកស្រីឆ្លើយអម្បាញ់មិញ ខ្ញុំមានចម្ងល់មួយពាក់ព័ន្ធជាមួយនឹងចំណុចមួយដែលលោកស្រីបានលើកឡើងថា ក្រុមគ្រួសាររបស់លោស្រីហ្នឹងត្រូវបានគេសម្លាប់មួយពូជ។ អ៊ីចឹងនៅពេលនុ៎ងក្រុមគ្រួសាររបស់លោកស្រីហ្នឹងមានសមាជិកប៉ុន្មាននាក់ដែរ ដែលលោកស្រីលើកឡើងថាមានការសម្លាប់ដល់មួយពូជដូច្នេះ?

**ឆ៖** មានមួយដណ្តប់នាក់។

[១០:០១:០៨]

**ស៖** ហើយហេតុការណ៍ហ្នឹងកើតឡើងយ៉ាងដូចម្តេចដែរ សូមលោកស្រីរៀបរាប់ឲ្យបានលម្អិតសាឡើងវិញ?

**ប្រធានអង្គជំនុំ៖**

មេធាវីសួរកាលៈទេសៈផង! ពេលវេលាផងថ្ងៃណា? ពេលវេលាណានៃការសម្លាប់នេះ ព្រោះយើងបានបញ្ជាក់ហើយអំពីកាលបរិច្ឆេទទាំងឡាយដែលនាំឲ្យធ្វើសវនាការ។ លោកស្រីអាចសួរដេញដោលបាន ហើយនិងលោកស្រី និងដើមបណ្តឹងរដ្ឋប្បវេណីអាចថ្លែងការណ៍ដោយផ្ទាល់ខ្លួនគាត់ យើងអត់កំណត់ទេ។ ដោយសារការថ្លែងទុក្ខសោកវេទនារបស់គាត់ យើងបានជម្រាបហើយថា ឲ្យគាត់មានសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងទុក្ខសោកវេទនារបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែភាគីពាក់ព័ន្ធនៃរឿងក្តីកំហិតឲ្យសួរដេញដោលត្រឹមវង្វង់វិសាលភាពនៃអង្គហេតុពាក់ព័ន្ធនឹងកាលបរិ -- ពេលវេលានៃដំណាក់កាលជំនុំ -- ជម្លៀសលើកទី១ ហើយនិងជម្លៀសលើកទី២។ បើពុំដូច្នោះទេ សក្ខីកម្មមិនអាចយកមកពិចារណានៅក្នុងរឿងហេតុនេះបានទេ។ វាទៅជាធ្វើសវនាការឥតប្រយោជន៍។

[១០:០២:២០]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនៅមានសំណួរប្រហែលជាពីរសំណួរទៀត ដើម្បីសួរ សាកសួរទៅលោកស្រីពាក់ព័ន្ធទៅនឹងហេតុការណ៍អម្បាញ់មិញ។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមសួរលោកស្រីថា ពេលដែលគេសម្លាប់ក្រុមគ្រួសារលោកស្រីហ្នឹងលោកស្រីចាំបានទេ តើអ្នកជាអ្នកសម្លាប់ក្រុមគ្រួសាររបស់លោកស្រី?

**លោកស្រី អោ រី៖**

**ឆ៖** ពួកខ្មែរក្រហម។ ខ្ញុំឃើញច្បាស់ណាស់ផ្ទាល់នឹងភ្នែកខ្ញុំ ខែភ្លឺថែស សុទ្ធតែមានកាំភ្លើងបាញ់ផ្អកចូលបណ្តោយ។

**ស៖** តើលោកស្រីមានដឹងឬទេ តើមូលហេតុអ្វីបានជាគេសម្លាប់ក្រុមគ្រួសាររបស់លោកស្រី?

[១០:០៣:១៤]

**ឆ៖** អានេះគេជម្លៀសពីផ្ទះហ្នឹង ទៅនៅដេកវាលស្រែ មិនដឹងជាមូលហេតុអីទេ ខ្ញុំក៏មិនដឹងដែរ។ ស្រាប់តែពេលយប់ឡើងមកសម្លាប់ម្តាយខ្ញុំ ឪពុកខ្ញុំ មីងខ្ញុំ ប្អូនខ្ញុំ ទាំងអស់មួយពូជ។

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសូមអស់សំណួរ ហើយនិងអរគុណលោកស្រីដែលបានឆ្លើយបំភ្លឺ ហើយនិងសូមអរគុណលោកប្រធានដែលអនុញ្ញាតឲ្យនាងខ្ញុំបានសួរ តាំងសំណួរទៅលើដើមបណ្តឹងរូបនេះ។ ហើយនិងសូមផ្ទេរវេទិកានេះជូនទៅខាងសហព្រះរាជអាជ្ញា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:០៥:១៣]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន យើងមិនមានសំណួរអ្វីត្រូវចោទទៅដើមបណ្តឹងរដ្ឋប្បវេណីនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ! សូមគោរពលោកប្រធាន!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមានសំណួរតែមួយ សួរទៅសាក្សីថ្ងៃនេះ។ នៅក្នុងឯកសារ D22/3455 នៅក្នុងនោះមាន ERN ខ្មែរ 00565899, ជាអង់គ្លេស 00660730, ជាបារាំង 00861206។ នៅក្នុងអត្ថបទមួយខាងក្រោមសរសេរថា "នៅឆ្នាំ១៩៧៨ គេបានបញ្ជូនខ្ញុំៗទៅធ្វើការងារដកស្ទូងវិញ គឺដកសំណាបជញ្ជូនសំណាប បោះសំណាបឲ្យគេស្ទូង គឺធ្វើការងារនេះរហូតដល់ចុងឆ្នាំ១៩៧៨។ នៅពេលនោះ កងទ័ពវៀតណាមបានវាយចូលមកជិតដល់ស្រុកកណ្តៀង ពួកខ្មែរក្រហមបានជម្លៀសអ្នកភូមិ មានពួកមកពីស្វាយរៀង មកពីភ្នំពេញ និងគ្រួសារខ្ញុំឲ្យឡើងភ្នំ។ នៅយប់មួយគ្រួសារខ្ញុំធ្វើដំណើរឡើងភ្នំជាមួយពួកស្វាយរៀង ហើយដេកជាមួយគ្នា។ ដល់ពេលយប់ស្ងាត់ស្រាប់តែពួកយោធាខ្មែរក្រហមវាបាញ់រះមកលើ

គ្រួសារខ្ញុំ។ ពេលនោះម្ដាយឪពុក និងប្អូនប្រាំនាក់ ត្រូវគ្រាប់ស្លាប់គរលើគ្នា ដោយឡែកប្អូនប្រុសពៅរបស់ -- ប្អូនប្រុសពៅអាយុ២ឆ្នាំ ខ្ញុំឃើញពួកវាចាប់បោះឡើងលើ ហើយយកចុងកាំភ្លើងចុចចំទ្រូងប្រកាច់ស្លាប់ ចំណែកខ្ញុំពួកវាបាញ់ដែរ តែបាញ់មិនចេញម្ដងជាពីរដង ទើបបានរត់រួចខ្លួនមកដល់សព្វថ្ងៃ”។

[១០:០៧:១៨]

ខ្ញុំមានសំណួរដូចតទៅនេះ ប៉ុន្តែមុននឹងខ្ញុំសួរ តើលោកស្រីនៅចាំចម្លើយរបស់លោកស្រី ជាមួយនឹងខាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានសួរលោកស្រី ដែលមានឯកសារ លោកស្រីបានចាំអត្ថបទដែលខ្ញុំបានអានជូនស្ដាប់អំមិញទេ? នៅចាំអត្ថបទហ្នឹងទេ?

**លោកស្រី អោ រី៖**

**ឆ៖** ខ្ញុំបានចាំ ប៉ុន្តែខ្ញុំនិយាយពីដើមហេតុនុ៎ង រៀងលើសបន្តិចហើយ ព្រោះមិនអាច -- វាមិនបានបន្តពីក្រោមទៅឲ្យជាលម្អិត។ ខ្ញុំបាននិយាយពីរឿងលើសទៅបន្តិចហើយ។

**ស៖** ខ្ញុំគ្រាន់តែចង់សួរថា លោកស្រីនៅចាំទេ អត្ថបទប៉ុន្មានដែលខ្ញុំអានជូនលោកស្រីស្ដាប់អំមិញនេះ?

**ឆ៖** ខ្ញុំបានចាំ។

**ស៖** ខ្ញុំមានសំណួរដូចតទៅនេះ។ នៅចុងឆ្នាំ១៩៧៨ នៅពេលនោះកងទ័ពវៀតណាមបានវាយចូលមកជិតដល់ស្រុកកណ្ដៀង។ ស្រុកកណ្ដៀងនៅភូមិសាស្ត្រនៅកន្លែងណា?

**ឆ៖** ខ្ញុំក៏មិនស្គាល់ដែរ ព្រោះខ្ញុំនៅក្មេង ខ្ញុំចាំតែកន្លែងខ្ញុំនៅទេ។ ខ្ញុំឮតែគេថា ដែរទេ។

[១០:០៨:៥៩]

**ស៖** ស្រុកកណ្ដៀងនេះ នៅខេត្តណា អ្នកស្រីដឹងទេ? ព្រៃវែង ឬនៅណា?

**ឆ៖** មិនមែននៅព្រៃវែងនៅអីទេ នៅខាងពោធិ៍សាត់នុ៎ងហើយ។ ខេត្តកណ្ដៀងនុ៎ង។

**ស៖** សូមអរគុណ។ អំមិញខាងដើមបណ្ដឹងរដ្ឋប្បវេណីបានសួរអ្នកស្រីថា “ហេតុអីបានជាគេបាញ់គ្រួសារអ្នកនាង អ៎ លោកស្រីអស់មួយពូជអ៊ីចឹង?” លោកស្រីថា “អត់ដឹងហេតុផលអ្វីទេ”។ ខ្ញុំមានសំណួរតទៅទៀត ពេលនោះអ្នកស្រីឆ្លើយថា ខែភ្លឺ អ្នកស្រីឃើញអ្នកបាញ់ គឺខ្មែរក្រហម។ សូមអ្នកស្រីបញ្ជាក់សាថ្មីម្ដងទៀតជូនតុលាការមើល៍ ថាប្រាកដជាខ្មែរក្រហម ឬមិនមែន? ពីព្រោះអីលោកស្រីបានបញ្ជាក់ពីលើមកបន្តិចថា “ចុងឆ្នាំ១៩៧៨ នៅពេលនោះកងទ័ពវៀតណាម បានវាយចូលដល់ស្រុក

កណ្ដៀងហើយ"។ តើពេលនោះខ្មែរក្រហម ឬក៏មិនមែន?

[១០:១០:២៨]

**ឆ៖** ខ្មែរក្រហម ព្រោះវាស្គាល់ឈ្មោះម៉ែខ្ញុំច្បាស់ណាស់។ ព្រោះតែវាចូល -- ពួកដែលកងទ័ពកម្ពុជាហ្នឹងចូលមកដល់ភូមិកណ្ដៀងមែន ប៉ុន្តែវាកៀរប្រជាជនចូលក្នុងព្រៃ។

**ស៖** អរគុណ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា អ្នកបាញ់គ្រួសារអ្នកស្រី ពេលហ្នឹងមានគ្រួសារផ្សេងទៀតត្រូវបានគេបាញ់ដែរឬទេ ឬតែមានគ្រួសារអ្នកស្រីតែមួយ?

**ឆ៖** មានតែគ្រួសារខ្ញុំ ក្រៅពីហ្នឹងសុទ្ធតែពួកស្វាយរៀងគេទើបបញ្ជូនទៅ ដែលខ្ញុំគេហៅទៅមុននុ៎ងមានតែក្រុមគ្រួសារខ្ញុំ ម្ដាយមីងខ្ញុំ ក្មួយខ្ញុំ ដេកជុំគ្នានុ៎ង។

**ស៖** ចុះហេតុអីបានជាពេលនុ៎ងអ្នកស្រីអាចឆ្លើយបានទេ ហេតុអីបានជាពេលហ្នឹងខ្មែរក្រហមដេញពួកអ្នកស្រីហ្នឹង គ្រួសារអ្នកស្រីហ្នឹងចុះមកវាលស្រែ តែគ្រួសារអ្នកស្រី ចុះអ្នកដទៃផ្សេងទៀតដែលអ្នកស្រីបាននិយាយរួចមកហើយ ថាមានពួកស្វាយរៀងទៅដេកជាមួយគ្នាជិតគ្នាបានស្គាល់គ្នានុ៎ង។ ហេតុអីបានគេមិនដេញពួកនុ៎ងចុះមកក្រោមដែរ? ហើយដេញតែពួកគ្រួសារអ្នកស្រី? ហើយសម្លាប់តែគ្រួសារអ្នកស្រី?

**ឆ៖** ដេញមកទាំងអស់ ទាំងមូលដ្ឋានចាស់ ទាំងមូលដ្ឋានថ្មី ព្រាតព្រោងពេញវាលស្រែទាំងអស់ អត់មាននរណានៅក្នុងភូមិមួយទេ ចេញមកទាំងអស់គ្នា។

**ស៖** ប៉ុន្តែគេសម្លាប់តែគ្រួសារអ្នកស្រីមួយគ្រួហ្នឹងទេ ឬក៏មាន -- អំមិញខ្ញុំសួរម្ដងរួចហើយ អ្នកស្រីឆ្លើយថាអត់មានទេសម្លាប់តែគ្រួសារអ្នកស្រីទេ។ អ្នកស្រីគួរឲ្យឆ្ងល់ទេថា ហេតុអីបានជាសម្លាប់គ្រួសារអ្នកស្រីតែមួយគ្រួ?

**ឆ៖** គេថាម៉ែខ្ញុំហ្នឹង នៅដេកជាមួយពួកស្វាយរៀង បានវាសម្លាប់។ ព្រោះពួកស្វាយរៀងវាដេកជិតម៉ែខ្ញុំ វាសម្លាប់មកក្រុមគ្រួសារខ្ញុំហ្នឹងទៅ។ ស្វាយរៀងវាយកទៅសម្លាប់អស់ហើយ។

[១០:១៣:០៩]

**ស៖** ខ្ញុំសូមឲ្យអ្នកស្រីរំឭកឡើងវិញបន្តិចពីរឿង អ្នកស្រីបានមានជម្រាបតុលាការរួចម្ដងហើយថា ខ្មែរក្រហមគឺជាយោធាខ្មែរក្រហម ពិតប្រាកដមែនអ្នកសម្លាប់គ្រួសារអ្នកស្រី។ ហើយអ្នកដទៃផ្សេងទៀតមិនបានសម្លាប់ទេ អំមិញអ្នកស្រីបានឆ្លើយអ៊ីចឹងជាមួយខ្ញុំ។ ប៉ុន្តែឥឡូវខ្ញុំសួរឡើងវិញម្ដងទៀតថា គ្រួសារអ្នកស្រីតែមួយគ្រួហ្នឹងទេដែលត្រូវគេសម្លាប់ ឬគ្រួសារផ្សេងទៀតដែលចុះមកពីភ្នំដែរហ្នឹងគេ

បានស្លាប់ដែរ ឬក៏អត់? សូមអ្នកស្រីឆ្លើយម្តងទៀត។

**ឆ៖** សម្លាប់គ្រួសារខ្ញុំមុនគេ ដែលគ្រួសារគេដទៃទៀតគេអត់ទាន់បានសម្លាប់ទេ។ សម្លាប់គ្រួសារខ្ញុំមុនគេ និងសម្លាប់ពួកអ្នកស្វាយរៀង។

**ស៖** បើដូច្នោះមានន័យថាមិនមែនស្លាប់តែគ្រួសារអ្នកស្រីទេ គឺស្លាប់អ្នកគ្រួសារអ្នកស្វាយរៀងដែរ?

**ឆ៖** ចាស។

**ស៖** គ្រួសារអ្នកស្វាយរៀងស្លាប់ច្រើនទេ ពេលនុ៎ង?

**ឆ៖** ស្លាប់ច្រើនណាស់ ចងទាំងខ្សែៗ ក្រមុំ កម្លោះ។ ខ្ញុំនៅឃើញផ្ទាល់នឹងភ្នែក ខ្ញុំតូចមែនប៉ុន្តែខ្ញុំដឹង។

[១០:១៤:៥១]

**ស៖** ពេលនោះ អ្នកស្រីអាយុប៉ុន្មាន?

**ឆ៖** ខ្ញុំអាយុជាង១០ឆ្នាំហើយ។

**ស៖** ជាង១០ឆ្នាំហើយ មានន័យថាដឹងខុសដឹងត្រូវច្រើនហើយ។ ពេលដែលកងទ័ពខ្មែរក្រហមជម្លៀសពួក -- ដេញពួកអ្នកស្រីចុះពីលើភ្នំ ពេលហ្នឹងអ្នកស្រីបានស្តាប់សំឡេងអ្នកដេញ អ្នកជម្លៀសចុះពីលើភ្នំហ្នឹង សំឡេងអ្នកដេញហ្នឹង ជាសំឡេងខ្មែរយើងសុទ្ធសាធ ឬក៏សំឡេងប៉ៃឡាំ ឬសំឡេងជនបរទេស?

**ឆ៖** សំឡេងខ្មែរ ឲ្យចុះវិញហ្នឹង សំឡេងខ្មែរទេ ប៉ុន្តែមិនដឹងជាពីណា ក៏ខ្ញុំមិនដឹងដែរ។ ព្រោះខ្ញុំឃើញគេមកគ្រប់គ្នា ខ្ញុំដើរតាមគេមក។

[១០:១៦:០៧]

**ស៖** អរគុណ។ ខ្ញុំមានសំណួរមួយថ្មីទៀត។ អ្នកស្រីបានបន្តថា "ចំណែកខ្ញុំពួកវាបាញ់ដែរ តែបាញ់មិនចេញម្តងជាពីរ ទើបបានរត់រួចខ្លួនមកដល់សព្វថ្ងៃ"។ សូមអ្នកស្រីអាចនឹកឃើញទេ នឹកឃើញពេលដែលគេបាញ់សម្លាប់គ្រួសារអ្នកស្រីហ្នឹង ហើយមិនបានត្រូវអ្នកស្រី? នឹកឃើញសកម្មភាពហ្នឹងថាតើយ៉ាងម៉េចបានជាមិនត្រូវអ្នកស្រី? យ៉ាងម៉េចបានជាត្រូវគ្រួសារស្លាប់ទាំងអស់គ្នា?

**ឆ៖** អានេះខ្ញុំមិនដឹងមូលហេតុអីដែរ ព្រោះខ្ញុំបានរងបងប្អូនម៉ែឪខ្ញុំ ខ្ញុំគ្របលើគាត់ទៀត ខ្ញុំថាសុខចិត្តឲ្យចំខ្ញុំចុះ កុំឲ្យចំម្តាយខ្ញុំ។ ខ្ញុំអត់ដឹងមូលហេតុអី បានជាមិនចំខ្ញុំ។

**ស៖** នៅក្នុងឯកសារមួយផ្សេងទៀត ជាមួយអង្គភាពជនរងគ្រោះ។ នៅឯកសារលេខ D22/3455A, ERN 00586120, ជាអង់គ្លេស 00858556 ខ្ញុំមិនមានជាភាសាបារាំងទេ។ ខ្ញុំសូមសួរត្រង់ ERN ជាភាសាខ្មែរ 00586121 ពេលនោះអ្នកស្រីបាននិយាយខុសពីសំណួរខ្ញុំមុនបន្តិច ថា “ពេលនោះគឺខ្ញុំនៅដេកឱបសពម្តាយខ្ញុំ ស្មានថាម្តាយខ្ញុំមិនទាន់ស្លាប់ ហើយចេះតែស្រែហៅម្តាយខ្ញុំ។ ពួកវាបាញ់សម្លាប់គ្រួសារខ្ញុំ ពេលយប់ប្រហែលជាម៉ោងដប់យប់។ គេបាញ់ខ្ញុំ តែមិនចេញគ្រាប់ទេ”។ នេះជាចំណុចមួយ។ មួយទៀត “ខ្ញុំឈឺចាប់ណាស់ ខឹងណាស់ គេខ្លាចខ្ញុំសងសឹក ព្រោះ -- (សូមទោស) គេខ្លាចខ្ញុំសងសឹក ព្រឹកឡើងម៉ោង -- សងសឹក ព្រឹកឡើងម៉ោងប្រាំបួនគេតាមបាញ់ខ្ញុំទៀត តែបាញ់មិនចេញ ពេលនោះខ្ញុំគ្របក្រមា ពេលគេបាញ់ខ្ញុំ”។

[១០:១៩:១៨]

ពាក្យលោកស្រីថា “គេខ្លាចខ្ញុំសងសឹកព្រឹកឡើង” លោកស្រីមានអាវុធអីនឹងសងសឹកគេដែរ ឬក៏អត់មានទេ? បើសិនជាអត់មានទេ លោកស្រីជាមនុស្សធម្មតា ហេតុអីបានគេខ្លាចលោកស្រីមាននិយាយ -- គេខ្លាចថាខ្ញុំសងសឹក?

**ឆ៖** ខ្ញុំក៏មិនដឹងដែរ ព្រោះវាតាមបាញ់ខ្ញុំម្តងជាពីរដង វាមិនបានសម្រេចដូចបំណងវា ហើយហេតុអីបានជាវាមកឆ្លើយដាក់ខ្ញុំថា “បើមិនសម្លាប់វាមិនបាន ខ្លាចវាសងសឹក”។ ខ្ញុំមានអាវុធណាទៅសងសឹក ខ្ញុំរកតែប្រាសអាយុដែរ។

**ស៖** បើលោកស្រីគ្មានអ្វីនឹងសងសឹកគេទេ គេមានអាវុធគ្រប់ដៃ គេកងទ័ព ហេតុអីបានជាខ្លាចលោកស្រីសងសឹកទៅវិញ? ហេតុអ្វី -- អ្នកស្រីយល់ឃើញយ៉ាងម៉េចបានអ្នកស្រីនិយាយពាក្យហ្នឹង?

**ឆ៖** បើវាឆ្លើយអ៊ីចឹង វាថា ទុកវាធ្វើអី សម្លាប់វាឲ្យដាច់ពូជទៅ ខ្លាចវាសងសឹក។ បើមិនសម្លាប់មីស្រី ក៏សម្លាប់អាប្រុស។ ហើយខ្ញុំ បងប្អូនខ្ញុំមានអ្នកណាទៅសងសឹក មកទាល់ដល់សព្វថ្ងៃហ្នឹង។

**ស៖** ខ្ញុំ -- សូមអរគុណអ្នកស្រីសាថ្មីម្តងទៀត។ ខ្ញុំត្រឡប់ទៅក្រោយវិញបន្តិច ត្រង់ដែលគេដេញអ្នកស្រីនិងគ្រួសារ និងអ្នកស្វាយរៀងទាំងអស់ចុះពីលើភ្នំ ពេលហ្នឹង ពេលដែលគេបាញ់គ្រួសារអ្នកស្រីហ្នឹង តើអ្នកស្រីនៅកន្លែងណា? ឈរកន្លែងណាជាមួយគ្រួសារអ្នកស្រី?

**ឆ៖** ខ្ញុំទើបនឹងចុះពីភូមិទៅទេ ទៅនៅឯវាលស្រែ។ ដេញថ្ងៃហ្នឹង ស្លាប់ថ្ងៃហ្នឹងបណ្តោយ។ ដេញពីថ្ងៃ យប់ឡើងស្លាប់។

[១០:២១:៣៨]

**ស៖** សំណួររបស់ខ្ញុំចង់សួរថា ពេលដែលគេបាញ់គ្រួសារអ្នកស្រី ពេលហ្នឹងគ្រួសារអ្នកស្រីនៅទាំងអស់គ្នា ទាំងឪពុកម្ដាយ បងប្រាំ -- បងប្អូនប្រាំនាក់ ហើយទាំងអ្នកស្រីផង ទាំងអស់គ្នាហ្នឹង អ្នកស្រីឈរកន្លែងណា បានគេបាញ់អ្នកស្រីមិនត្រូវ?

**ឆ៖** ខ្ញុំនៅដេកជាមួយម៉ែខ្ញុំហ្នឹង ខ្ញុំមាននៅត្រង់ណា ខ្ញុំនៅដេកជាមួយម៉ែខ្ញុំទាំងអស់គ្នាហ្នឹងក្រាលប៉ាវ៉ាតង់មួយ -- មានក្រាលប៉ាវ៉ាតង់មួយដេកមួយវាល មួយត្រាញ់ហ្នឹង ដេកជុំបងជុំប្អូនជុំឪពុកជុំម្ដាយ អត់មានទៅណា នៅៗជាមួយគាត់ហ្នឹង។

**ស៖** អ៊ីចឹងពេលដែលគេបាញ់ហ្នឹង គឺពេលហ្នឹងទាំងអស់គ្នាបានដេកនៅវាលស្រែ អ៊ីចឹង?

**ឆ៖** ចាស នៅដេកវាលស្រែ។

**ស៖** ដេកវាលស្រែតែគ្រួសារអ្នកស្រីទេ ឬក៏អ្នកស្វាយរៀងនៅដេកជិតៗគ្នាហ្នឹងដែរ?

**ឆ៖** នៅដេកជិតៗគ្នាទាំងអស់គ្នាហ្នឹង ទាំងអ្នកស្វាយរៀង ទាំងអ្នកមូលដ្ឋានចាស់ ទាំងគ្រួសារខ្ញុំហ្នឹង នៅជិតៗគ្នារំលងគ្នាប្រហែលជា១០ម៉ែត្រៗហ្នឹង មួយជុំៗហ្នឹង។

**ស៖** ពេលយប់នោះ--

[១០:២៣:១៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អង្គហេតុនេះវាឆ្ងាយពីអង្គហេតុដែលយើងកំណត់ឲ្យធ្វើសវនាការ។ បើនិយាយពីកាលវេលានៅឆ្នាំ -- ចុងឆ្នាំ១៩៧៨ ឯណោះ។ យើងបានជម្រាបហើយ *(ឮមិនច្បាស់)* ភាគីព្យាយាមបំពានលើការរំឭករបស់យើងតែប៉ុណ្ណោះ។ គប្បីឲ្យមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ ដំណាក់ជម្លៀសទី១ ហើយនិងជម្លៀសទី២ ទៅដល់គោលដៅភ្លាម។ ភ្លាមហ្នឹងគឺយើងអាចបកស្រាយថា ២, ៣ ខែក្រោយ បន្ទាប់ពីទៅដល់ហ្នឹងវាមានការចាត់ចែង ការជ្រើសរើសមនុស្ស អីៗអ៊ីចឹង ដកហូតមនុស្ស ដូចជាករណី មាស សាវ៉ាន់ អីអ៊ីចឹង។ នេះគឺយើងបានធ្វើច្បាស់លាស់ហើយ ហើយឃើញភាគីបានធ្វើការសាកសួរ មាស សាវ៉ាន់ រហូតដល់ មាស សាវ៉ាន់ បានសម្រេចចិត្តរត់ចេញពីមន្ទីរសន្តិសុខទៅព្រំដែនថៃ ហើយកងទ័ពខ្មែរក្រហមបាញ់ត្រូវក រហូសគាត់ទៅបាវាំងអីអ៊ីចឹង គឺជាអង្គហេតុដែលវាឆ្ងាយពេកពីវិសាលភាពនៃជម្លៀសទី១ និងទី២។ អ៊ីចឹងហើយបានភាគីមិនសួរនាំទេ។ អ៊ីចឹងសូមឲ្យចូលមកវិញ ដើម្បីឲ្យចំនួវបញ្ហានៃគោលបំណងដែលអង្គជំនុំជម្រះកំណត់ធ្វើ

សវនាការ សំណុំរឿង០០២/០១ គឺក្នុងអំឡុងពេលនៃពាក់ព័ន្ធទៅនឹងអង្គហេតុជម្លៀសដំណាក់កាលទី១ និងទី២។

**លោក សុន អរុណ៖**

ក្នុងគោលបំណងរបស់ខ្ញុំសួរដេញដោលអ្នកស្រីត្រង់នេះ ចង់ដឹងថាតើចម្លើយរបស់គាត់ ជាមួយអង្គភាពគាំពារជនរងគ្រោះហ្នឹង ត្រឹមត្រូវទេ? ភូតកុហក--

**ប្រធានអង្គជំនុំ៖**

យើងយល់បញ្ហានេះ ប៉ុន្តែយើងឃើញថាសមល្មម យើងស្តាប់បានហើយ។ យើងយល់បញ្ហានេះ ទើបយើងអនុញ្ញាតឲ្យលោកបន្តការតាំងសំណួររបៀបនេះ ម្យ៉ាងជាការឆ្លើយតបទៅនឹងរបៀបសួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិផង។ ម្យ៉ាងសំណួរបែបសំណួរផ្ទញ់ផង យើងបានយល់ ប៉ុន្តែយើងស្តាប់យល់ហើយនូវគោលបំណងនេះ។ យើងតម្រង់ទិសលោកថា ឲ្យលោកធ្វើការពិភាក្សាដេញដោលឲ្យចំទៅនឹងអង្គហេតុទាំងឡាយ ដែលអង្គជំនុំជម្រះកំណត់វិសាលភាពឲ្យធ្វើសវនាការក្នុងសំណុំរឿង ០០២/០១។ នេះជាបេសកកម្មរបស់ប្រធានសវនាការ ត្រូវគ្រប់គ្រងដឹកនាំសវនាការធ្វើយ៉ាងណាឲ្យមានប្រសិទ្ធភាព និងឆាប់រហ័ស។

[១០:២៦:០៣]

**លោក សុន អរុណ៖**

ខ្ញុំអរគុណណាស់បានយោបល់ពីលោកប្រធាន។ ខ្ញុំមានសំណួរតែប៉ុណ្ណេះទេ ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន សូមអរគុណសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះ សូមផ្តល់វេទិកាជូនទៅ -- អ៎ សូមអញ្ជើញបាទ!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួន ហើយខ្ញុំនឹងព្យាយាមសួរឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ជាដំបូងខ្ញុំចង់បញ្ជាក់ថា ខ្ញុំបានស្តាប់ទៅលើអ្វីដែលលោកស្រីបាននិយាយ ហើយខ្ញុំសូមចូលរួមសោកស្តាយ ដែលលោកស្រីបានបាត់បង់សមាជិកគ្រួសារ

របស់លោកស្រី។ ហើយខ្ញុំនឹងសួរទៅលើព្រឹត្តការណ៍ដែលអាចកើតឡើងមុនខែមេសា ឆ្នាំ៧៥។ ជាដំបូង ខ្ញុំសូមសួរលោកស្រី ទាក់ទងទៅនឹងពេលវេលា ខ្ញុំដឹងថាលោកស្រីមិនមែនកើតនៅទីក្រុងភ្នំពេញទេ ប៉ុន្តែ តើលោកស្រីផ្លាស់ទីលំនៅមកទីក្រុងភ្នំពេញនៅពេលណាដែរ?

[១០:២៧:២៤]

**លោកស្រី អោ វី៖**

**ឆ៖** ខ្ញុំមិនចាំដែរ ព្រោះម្ដាយខ្ញុំមិនដឹងជាគាត់ទីពីថ្ងៃណា ខែណា ក៏ខ្ញុំអត់ដឹងដែរ។ ខ្ញុំដឹងក្ដីឡើង ៗ ខ្ញុំដឹងតែខ្ញុំនៅទីក្រុងភ្នំពេញ។

**ស៖** បន្ទាប់ពីលោកស្រីរស់នៅទីក្រុងភ្នំពេញ គឺនៅពេលដែលលោកស្រីធំលូតលាស់នៅទីក្រុងភ្នំពេញ។ តើមានពេលណាមួយមុនពេលដែលជម្លៀសហ្នឹង តើលោកស្រីរស់នៅទីណាដែរ នៅក្នុងទីក្រុងភ្នំពេញ នៅពេលដែលលោកស្រីធំលូតលាស់ រហូតដល់ពេលដែលលោកស្រីចាកចេញ ឬក៏រហូតដល់ពេលគេជម្លៀសចេញពីទីក្រុងភ្នំពេញ?

**ឆ៖** ខ្ញុំនៅភូមគីឡូលេខ៦។

**ស៖** តើលោកស្រីចាំទេថា នៅពេលដែលលោកស្រីទៅភូមិនុ៎ង តើនៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់ចាំទេ។ ព្រោះខ្ញុំអត់ដឹងទេ ព្រោះខ្ញុំដឹងថា ខ្ញុំដឹងឡើង ខ្ញុំដឹងតែខ្ញុំនៅគីឡូលេខ៦ហ្នឹង ព្រោះដឹងម្ដាយឪពុកខ្ញុំទៅនៅពីអង្កាល់ៗ ខ្ញុំក៏ខ្ញុំអត់ដឹងដែរ។

[១០:២៨:៥២]

**ស៖** តើខ្ញុំអាចនិយាយបានទេថា លោកស្រីចំណាយពេលច្រើនឆ្នាំនៅក្នុងទីក្រុងភ្នំពេញ មុនពេលមកដល់ពេលដែលខែមេសា ឆ្នាំ៧៥ នោះ? តើខ្ញុំអាចនិយាយអ៊ីចឹងបានដែរឬទេ?

**ឆ៖** ខ្ញុំនិយាយបាន។ ខ្ញុំអ្នកចាំស្ដាប់ ហើយចាំខ្ញុំបកស្រាយឲ្យស្ដាប់វិញ។

**ស៖** សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ឥឡូវនេះ ខ្ញុំសូមលើកសំណួរជាក់លាក់មួយចំនួន។ ម្សិលមិញនេះ យើងបានស្ដាប់នូវសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយទៀត ទាក់ទងទៅនឹងតម្លៃនៃស្រូវអង្ករនៅក្នុងទីក្រុងភ្នំពេញ ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះ បាននិយាយអំពីការកើនឡើងនៃតម្លៃស្រូវអង្ករនៅក្នុងប៉ុន្មានឆ្នាំ នៅក្នុងបណ្ដាឆ្នាំ មុនឆ្នាំ៧៥។ ដូច្នេះតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកស្រីផ្ទាល់ តើលោកស្រីដឹងដែរឬទេថា តម្លៃនៃស្រូវអង្ករចាប់ពីមុនឆ្នាំ៧៥ រហូតមកដល់ឆ្នាំ៧៥ហ្នឹង តើតម្លៃវាយ៉ាងម៉េចដែរ? តើវាថ្លៃ ឬមួយក៏វាតម្លៃសមស្របអាចទិញបាន? តើលោកស្រី

អាចបញ្ជាក់បានទេ នៅលើចំណុចនេះ?

[១០:៣០:២២]

**ឆ៖** តម្លៃអង្ករជំនាន់នុំង វាមិនថ្លៃណាស់ណាទេ។ វាល្មមនឹងអាចទិញបានហូប។

**ស៖** តើក្រោយមកតម្លៃអង្ករនុំងវាកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ដូចដែលដើមបណ្ដឹងមួយរូបផ្សេងទៀត គាត់និយាយប្រាប់ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** ខ្ញុំមិនសូវដឹងដែរទេ ព្រោះខ្ញុំដឹងតែម្ដាយខ្ញុំទិញអង្ករហ្នឹង ក៏វារៀងថ្លៃថ្លៃដែរ។ រឿងឲ្យខ្ញុំយល់ទៅជ្រៅៗទៀត ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ ចំពោះការឆ្លើយរបស់លោកស្រី។ ចុះចំនួនប្រជាជន ដែលរស់នៅក្នុងទីក្រុងភ្នំពេញ កាលពីម្សិលមិញយើងស្ដាប់ឮគេនិយាយថា ប្រជាជនក្នុងទីក្រុងភ្នំពេញកើនឡើងយ៉ាងច្រើនមុនឆ្នាំ៧៥ ហើយបុគ្គលដែលផ្ដល់សក្ខីកម្មកាលពីម្សិលមិញហ្នឹង គាត់បានរៀបរាប់ថា "គឺចំនួនប្រជាជនអាចកើនឡើងដល់ទៅបីដងឯណោះ"។ តើលោកស្រីយល់ឃើញយ៉ាងម៉េចដែរ តាមបទពិសោធន៍របស់លោកស្រីនៅក្នុងទីក្រុងភ្នំពេញមុនខែមេសា ឆ្នាំ៧៥នោះ? តើលោកស្រីមានកត់សម្គាល់ឃើញថា ប្រជាជនក្នុងទីក្រុងហ្នឹងកើនឡើងច្រើនដែរឬទេ?

**ឆ៖** កាលនុំង ខ្ញុំអត់ទាន់ដឹងអីទេ។ ពីរឿងជ្រៅៗអ៊ីចឹង ខ្ញុំអត់ទាន់ដឹងអីទេ ព្រោះខ្ញុំនៅក្មេងណាស់។ ខ្ញុំមិនទាន់មានការដឹងរាក់ជ្រៅអី ក៏ខ្ញុំអត់ទាន់ដឹងទេ។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំមានសំណួរមួយទៀត។ តើលោកស្រីចាំដែរឬទេ ដោយសារលោកស្រីនៅក្មេង បើសិនលោកស្រីអត់ចាំប្រាប់ខ្ញុំថា អត់ចាំចុះ។ តើលោកស្រីមានចាំអំពីការទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញមុនឆ្នាំ៧៣ដែរឬទេ? ប្រសិនបើលោកស្រីក្មេងពេក មិនអាចចាំបានលោកស្រីអាចប្រាប់ខ្ញុំថា មិនចាំទៅចុះ។

[១០:៣២:៤៥]

**ឆ៖** ខ្ញុំអត់ចាំទេ រឿងទម្លាក់គ្រាប់បែកហ្នឹង។

**ស៖** សូមអរគុណលោកស្រី។ មុនហ្នឹងខ្ញុំថា មានសំណួរចុងក្រោយ ប៉ុន្តែឥឡូវ ខ្ញុំនៅសល់មួយទៀត។ កាលពីម្សិលមិញ គឺគាត់បាននិយាយអំពីមន្ទីរពេទ្យធំមួយនៅទីក្រុងភ្នំពេញ ហើយលោកស្រីនិយាយថា បងប្អូនលោកស្រីបានទៅទីនោះ ដើម្បីទទួលការព្យាបាល ហើយលោកស្រីនិយាយថា ដើម្បីទទួលបានការព្យាបាល គឺគ្រួសាររបស់លោកស្រីត្រូវគេតម្រូវឲ្យបង់លុយជាមុន មុនពេលទទួលការ

ព្យាបាល។ តើនេះជាអ្វីដែលលោកស្រីបានប្រាប់យើងកាលពីម្សិលមិញ តើមែនដែរឬទេ?

**ឆ៖** បងខ្ញុំទៅព្យាបាលពេទ្យធំនុំង បើ -- ម៉ែខ្ញុំគាត់ថា បើសិនមានលុយ បុកគេឲ្យខ្លាំងទៅ ព្រោះបងខ្ញុំឆាប់ជា បើគ្មានលុយទេ នឹកឃើញនៅគេស្រែកយ៉ូយយ៉ាយៗពេញតែមន្ទីរពេទ្យហ្នឹង។ ម៉ែខ្ញុំយកលុយទៅទិញថ្នាំបញ្ចូលថែម ហ្នឹងបានឆាប់ជា។

**ស៖** សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ តាមការបកប្រែជាភាសាអង់គ្លេស គឺលោកស្រីនិយាយថា គឺយើងត្រូវសូកលុយទៅមន្ទីរពេទ្យ។ ដូច្នេះសំណួររបស់ខ្ញុំគឺថា តើលោកស្រីដឹងដែរឬទេ ផ្អែកតាមបទពិសោធន៍របស់លោកស្រី ថាតើការសូកលុយហ្នឹងគឺជាគោលនយោបាយមួយរបស់របប លន់ នល់ ដែលទាមទារឲ្យប្រជាជនហ្នឹងសូកលុយទៅវេជ្ជបណ្ឌិត ឬក៏គ្រូពេទ្យ ដើម្បីទទួលបានសេវាព្យាបាល ប្រសិនបើលោកស្រីដឹង អាចជម្រាបបាន បើលោកស្រីមិនដឹងទេ វាអត់បញ្ហាអ្វីទេ។

**ឆ៖** ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែបងរបស់ខ្ញុំ។ ខ្ញុំដឹងតែម្ដាយខ្ញុំយកលុយទៅទិញថ្នាំអាណាល្អៗឲ្យបងខ្ញុំឆាប់ជា។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

[១០:៣៥:០៧]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកស្រីដែលបានចំណាយពេលឆ្លើយនឹងសំណួររបស់ខ្ញុំ ហើយសូមជូនពរឲ្យលោកស្រីធ្វើដំណើរទៅវិញប្រកបដោយសុវត្ថិភាព។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១០:៣៥:៤៧]

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សួស្ដីតំណាងអយ្យការ សួស្ដីសហភាគីទាំងអស់ ហើយសួស្ដីផងដែរលោកអ្នកទាំងឡាយដែលចូលរួមសវនាការនេះ។

**សួរដោយលោក អាង ឧត្ដម៖**

**ស៖** សួស្ដីអ្នកស្រី អោ រី។ ខ្ញុំ អាង ឧត្ដម ជាសហមេធាវីការពារក្ដីលោក អៀង សារី។ ខ្ញុំមាន

សំណួរតែពីរ ហើយខ្លីៗសម្រាប់អ្នកស្រី។ សំណួរទី១ គឺសំណួរបញ្ជាក់ទេ ពីព្រោះខ្ញុំឃើញនៅក្នុងកំណត់ហេតុដើមបណ្ដឹងរដ្ឋប្បវេណីរបស់អ្នកស្រី និងសៀវភៅគ្រួសាររបស់អ្នកស្រីឃើញព័ត៌មានខុសគ្នា។ នៅក្នុងសៀវភៅគ្រួសាររបស់អ្នកស្រី គឺឯកសារ D22/3455 ហ្នឹងខ្ញុំឃើញអ្នកស្រីដាក់ថា -- ក្នុងហ្នឹងសៀវភៅគ្រួសារហ្នឹងចុះឆ្នាំ -- ថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៨៩។ ក្នុងទំនាក់ទំនងក្នុងគ្រួសារ លោកស្រីអះអាងថាជាៗ "ប្រពន្ធ"។ ក៏ប៉ុន្តែនៅក្នុងពាក្យទម្រង់បែបបទព័ត៌មានជនរងគ្រោះចុះនៅថ្ងៃ១៦ ខែសីហា ឆ្នាំ២០០៩នេះ លោកស្រីអះអាងថា "នៅលីវ"។ តើអ្នកស្រីអះអាងយ៉ាងម៉េចទៅនៅឆ្នាំ -- សៀវភៅគ្រួសារពី១៩៨៩ ថាជា "ប្រពន្ធ" ហើយឯកសារនេះចុះថ្ងៃ១៦ ខែសីហា ឆ្នាំ២០០៩ គឺឯកសារទម្រង់បែបបទព័ត៌មានជនរងគ្រោះហ្នឹងដាក់ថានៅ "លីវ" វិញតើអ្នកស្រីអាចពន្យល់យ៉ាងម៉េចទៅ?

[១០:៣៧:២៧]

**លោកស្រី អោ រី៖**

**ឆ៖** ខ្ញុំក៏មិនដឹងដែរ ព្រោះខ្ញុំទើបមកមានប្ដី និងបែកអាពតហ្នឹងមកទេ ខ្ញុំមកដល់បាន១ឆ្នាំបានៗខ្ញុំមានប្ដីហ្នឹង។

**ស៖** ខ្ញុំសូមឲ្យអ្នកស្រីបញ្ជាក់ឆ្នាំ១៩៨៩ សៀវភៅគ្រួសារអ្នកស្រីថា "ជាប្រពន្ធ" បានអ្នកស្រីថារៀបការហើយ លោកស្រីជាភរិយារបស់លោក ហ៊ុន ម៉ៅ ក្នុងសៀវភៅគ្រួសារនេះ។ ក៏ប៉ុន្តែនៅក្នុងទម្រង់បែបបទនេះ អ្នកស្រីថាស្ថានភាពគ្រួសារ "នៅលីវ" នេះ តើអ្នកស្រីអះអាងថាមួយណាត្រូវ មួយណាខុស ឥឡូវឆ្នាំ២០០៩ហ្នឹង ទៅជា "នៅលីវ" វិញ។ ខ្ញុំចង់ដឹងថាវាយ៉ាងម៉េច តើមួយ --ព័ត៌មានមួយណាខុស ព័ត៌មានមួយណាត្រូវ?

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ឆ្លើយទេ លោកស្រីឆ្លើយរួចហើយ។ ហើយសំណួរជាក់ស្ដែងគឺលោកស្រីនៅទីនេះហើយ វត្តមានរបស់គាត់ ហើយគាត់បានឆ្លើយរួចហើយ ទាំងយើងសួរប្រវត្តិរូបដំបូងចំពោះគាត់គឺគាត់បានឆ្លើយច្បាស់លាស់ហើយ អំមិញគាត់បានឆ្លើយច្បាស់លាស់ហើយ។ នេះមិនមែនជាហេតុផលដែលឲ្យអង្គជំនុំជម្រះពិចារណាលើឯកសារនេះជាភស្តុតាង ជាតម្លៃភស្តុតាងនៅក្នុងរឿងក្ដីនេះទេ។

**លោក អាង ឧត្ដម៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ក្រែងលោមានវិការៈអីមួយនៅក្នុងដំណើរការសួរដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។

[១០:៣៩:០២]

**សួរដោយលោក អាង ឧត្តម៖**

**ស៖** បាទ ឥឡូវខ្ញុំសុំបន្តសំណួរទី១ ទៀត នៅក្នុង -- ពីម្សិលមិញអ្នកស្រីបានអះអាងថាប្រជាជនមូលដ្ឋានចាស់ និងប្រជាជនមូលដ្ឋានថ្មី សូមលោកស្រីបញ្ជាក់ពីអន្តន័យនិងខ្លឹមសារនៃពាក្យទាំងពីរនេះយ៉ាងម៉េចបាន ពន្យល់យ៉ាងម៉េចបានសូមបញ្ជាក់បន្ថែម?

**លោកស្រី អោ រី៖**

**ឆ៖** អាហ្នឹង ខ្ញុំក៏មិនដឹងដែរ ព្រោះបើខ្ញុំទៅគេថា ខ្ញុំមូលដ្ឋានថ្មី ព្រោះគេនៅក្នុងស្រុកហ្នឹងគេថាមូលដ្ឋានចាស់ ថ្មីគេដាក់ដោយថ្មី ចាស់គេដាក់ដោយចាស់។

**លោក អាង ឧត្តម៖**

សូមអរគុណ ខ្ញុំអស់សំណួរហើយលោកស្រី អោ រី តែយ៉ាងណាក្តីខ្ញុំតាំងនាមលោក អៀង សារី ខ្ញុំសូមអរគុណអ្នកស្រីដែលឡើងមកផ្តល់សក្ខីកម្មជូនតុលាការ ដើម្បីជួយតុលាការតាមការស្វែងរកការពិត។ សូមលោកស្រីបានសេចក្តីសុខសប្បាយពេលត្រឡប់ទៅវិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ។

**កញ្ញា អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ខាងមេធាវីការពារក្តី ខៀវ សំផន មិនមានសំណួរទេលោកប្រធាន។ សូមអរគុណ។

[១០:៤០:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អរគុណលោកស្រី អោ រី។ ការស្តាប់សក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ វត្តមានរបស់លោកស្រីនៅអង្គជំនុំជម្រះ គឺលែងមានភាពចាំបាច់ទៀតហើយ។

លោកស្រី អោ រី ចុងក្រោយនេះ តើលោកស្រីមាន -- មានសិទ្ធិនៅក្នុងធ្វើសេចក្តីថ្លែងការណ៍រៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្ម គឺផលអន្តរាយ ដែលប៉ះពាល់លោកស្រី។ អង្គជំនុំជម្រះ

ផ្តល់វេទិកា និងឱកាសជូនលោកស្រី ដើម្បីឲ្យលោកស្រីធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ខ្លួន។

[១០:៤១:២៦]

**លោកស្រី អោ រី៖**

ខ្ញុំសូមនិយាយថា ពីខ្ញុំមកចេញពីទីក្រុងភ្នំពេញ ខ្ញុំបាត់បង់ផ្ទះសម្បែង ទ្រព្យសម្បត្តិ ហើយមកតាមផ្លូវ អត់មានអាហារហូបតាមផ្លូវ វេទនា រហូតទាល់តែដល់ស្រុកកំណើត។ បែរទៅដល់ស្រុកកំណើតហើយ នឹកឃើញតែស្មានថា បាននៅជាមួយនឹងជីដូនជីតា អកុសលអីបានបញ្ជូនខ្ញុំម្តងហើយទៅម្តងទៀត ទាល់តែដល់ខេត្តពោធិ៍សាត់ គេដាក់ទារុណកម្មខ្ញុំ ព្រោះខ្ញុំនៅតូច ខ្ញុំធ្វើការមិនបានជិតដិតនឹងគេ គេវ៉ៃនឹងខ្នងចប គេយក -- ខ្ញុំរែកដី គេយកដែលដែកដងរែកសំពងខ្ញុំ កំផ្ទួនជើង ឆ្អឹងខ្នង គេថាខ្ញុំនឹងចក្រពត្តិ ធ្វើការអីក៏ខ្ជិល។ ខ្ញុំរែកម៉េចនឹងរួច? បើដីពេញៗបង្គី ហើយជម្រៅណាណី ខ្ញុំអូសតែបង្គីអូសតែមិនចង់រួចផង។ ចំណែកគេឲ្យខ្ញុំទៅស្ទូង ខ្ញុំអត់ចេះស្ទូង គេយកដៃខ្ញុំមកផ្ទាប់នឹងភ្លឺស្រែ វ៉ៃខ្ញុំឡើងចង់ខ្ទេចអស់ហើយដៃ ទើបមកជាសព្វថ្ងៃនេះទេ។ ខ្ញុំធ្វើអីក៏មិនកើតដែរ ហើយឲ្យខ្ញុំបាត់បង់ឪពុកម្តាយបងប្អូនអស់ទាំងពូជ។ ធ្វើឲ្យខ្ញុំក្មេងអនាថា អត់មានឪពុកម្តាយ ក្មេងកំព្រា ឯកោគ្មានគោលដៅដើរសុំតែទានគេស៊ី រើសដែលកាកសំណល់គេសល់ពីរនាក់បងប្អូនដើររើសតាមផ្លូវ។ លើកដៃសំពះអង្វរសុំគេ សុំឲ្យតែប្អូនហូប ខ្លួនឯងសុខចិត្តអត់ ព្រោះប្អូនហើមជើងប៉ុនៗណាណី ប៉ុនៗដំរី។ ចំណែកឯខ្ញុំណាត្រូវរបួស ដើរអូស ក៏អូសជើងដែរ។ ខ្ញុំឈឺចាប់ទាល់សព្វថ្ងៃនេះ។ ណា -- សព្វថ្ងៃ ណាមួយបងស្រីមានទើបនឹងជួបគ្នា ខ្ញុំស្មានតែបងខ្ញុំហ្នឹងស្លាប់ គេបញ្ជូនទៅធ្វើការឆ្ងាយហ្នឹង បងស្រីដែលត្រូវគ្រាប់ហ្នឹង។ ឥឡូវគាត់រស់នៅទល់សព្វថ្ងៃ។

[១០:៤៤:៣៧]

របួសគាត់ គ្មានធ្វើអីកើតទេ នៅទល់សព្វថ្ងៃ នៅជាមួយនឹងខ្ញុំ។ គាត់គ្មានប្តី គ្មានសីអីទេ តែជីវិតខ្ញុំក៏អកុសល ខ្ញុំក៏អាក្រក់ម្ល៉ោះ ជួបតែទុក្ខលំបាកវេទនា។

សូមឲ្យលោកប្រធានជួយរកការខុសត្រូវឲ្យខ្ញុំផង។ ខ្ញុំសូមអរគុណណាស់។

**ប្រធានអង្គជំនុំ៖**

បាទ សាជាថ្មីម្តងទៀត គឺអរគុណលោកស្រី អោ រី ហើយការស្តាប់សក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះ ដល់ទីបញ្ចប់ហើយ។ ហើយវត្តមានរបស់លោកស្រីនៅអង្គជំនុំជម្រះនេះ លែងមាន

ភាពចាំបាច់ទៀតហើយ។ សក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។

[១០:៤៥:២២]

លោកស្រី អោ រី លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកស្រី ឬគោលដៅណាដែលលោកស្រីដែលអាចមានចំណងចង់ទៅបានហើយ។ ហើយសូមលោកស្រីជួបតែសំណាងល្អ មានសុខភាពល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី អោ រី ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងជាគោលដៅដែលគាត់ចង់បានហើយ។

លោកស្រី អោ រី អាចចាកចេញពីបន្ទប់សវនាការត្រឡប់ទៅវិញបានហើយ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

[១០:៤៦:០៩]

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅភាគីដែលពាក់ព័ន្ធនានា ដើម្បីមានឱកាសក្នុងការធ្វើការកត់សម្គាល់ទៅលើសក្ខីកម្មរបស់សាក្សី -- របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើភាគីមានបំណងធ្វើដូច្នេះ។

បាទ ទំនងជាមិនមានទេ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយចូលមកវិញនេះ អង្គជំនុំជម្រះនឹងដំណើរការផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតដែលមានរហស្សនាម TCCP-187។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៧ នាទី ដល់ម៉ោង ១១:០៩ នាទី)*

[១១:០៩:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការជាបន្តនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-187។ មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-187 ចូលមកកាន់បន្ទប់សវនាការ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១១:១០:២៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនភាគីថា អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ ឯកសារ E237/1 តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោល លើដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៤រូប ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៤រូប ក៏មានដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-187 មួយរូបដែរ។ ហើយនៅពេលនេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោល ស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដោយមានដែនកំណត់ ដោយគាត់មានបញ្ហាសុខភាព តែរូបកាយ និងបញ្ហាស្មារតីសមស្រប។

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-187 ដោយមិនមានវត្តមានលោក អៀង សារី ដោយអនុវត្តតាមវិធាន៨១ អនុវិធាន ៥ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ចៅ នី៖**

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឈ្មោះ ចៅ នី។

[១១:១១:៥៧]

**ស៖** អរគុណ។ លោក ចៅ នី មានអាយុប៉ុន្មានហើយ?

**ឆ៖** ខ្ញុំបាទអាយុ ៥៩ឆ្នាំ។

**ស៖** បាទអរគុណ។ ហើយលោក ចៅ នី តើលោកមានទីកន្លែងកំណើតនៅឯណា?

**ឆ៖** ខ្ញុំបាទមានទីកំណើតនៅភូមិភ្នំពី ភូមិចូវឡាំង ស្រុកស្វាយទង ខេត្តមាត់ជ្រូក អាងយ៉ាងបច្ចុប្បន្ន នៅកម្ពុជាក្រោម។

**ស៖** អរគុណ។ ទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅបច្ចុប្បន្ន ខ្ញុំរស់នៅភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** អរគុណ។ ឪពុករបស់លោកឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ ចៅ នុន។ ម្តាយឈ្មោះ នាង គិញ។

**ស៖** អរគុណ។ ហើយចុះប្រពន្ធរបស់លោក តើលោកមានប្រពន្ធឈ្មោះអី? ហើយមានកូនប៉ុន្មាននាក់?

[១១:១៣:១៥]

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សាន សុភុំ មានកូនបីនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ចៅ នី ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី គឺលោកមានសិទ្ធិធ្វើសេចក្តីថ្លែងរៀបរាប់ជម្រាបដល់អង្គសវនាការ អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម គឺផលអន្តរាយ ដែលបានកើតមានចំពោះលោក មានជាអាទិ៍ការខូចខាតផ្នែកខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬក៏សម្ភារៈ ហើយជាព្យសនៈផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទល្មើស និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ន ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលប៉ះពាល់ចំពោះលោកនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

នេះជាសិទ្ធិចុងក្រោយ ដែលនៃការស្តាប់សក្ខីកម្មរបស់លោក អង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនទៅលោកធ្វើសេចក្តីថ្លែងដូច្នេះ ប្រសិនបើលោកមានបំណងចង់ធ្វើដូច្នេះ។ នេះជា -- អង្គជំនុំជម្រះនឹងជម្រាបជូនលោកបន្ថែមទៀត នៅពេលទីបញ្ចប់នៃការផ្តល់សក្ខីកម្មរបស់លោក។ ហើយអង្គជំនុំជម្រះសូមជម្រាបទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា អនុវត្តនូវបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកា

ជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី នេះមុនភាគីឯទៀត។ ហើយទាំងមេធាវី ទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងសហព្រះរាជអាជ្ញា មានពេលវេលាកន្លះថ្ងៃ គឺមួយពេលនេះ ហើយនិងរសៀលមួយពេល។

សូមអញ្ជើញ!

[១១:១៥:១៩]

**លោក វ៉ែន ពៅ៖**

សូមគោរពលោកប្រធាន ក្នុងនាមសហមេធាវីនាំតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអនុញ្ញាតពីលោកប្រធានផ្ទេរសិទ្ធិជូនលោកមេធាវី គង់ ផល្លា: និងលោកមេធាវី ម៉ះដេវ ម៉ូហាន ដើម្បីសួរសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក គង់ ផល្លា:៖**

បាទ ជាបឋមសូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ គង់ ផល្លា: សូមអនុញ្ញាតសាកសួរលោក ចៅ នី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក គង់ ផល្លា:៖**

**ស៖** ជម្រាបសួរលោក ពូ!

**លោក ចៅ នី៖**

**ឆ៖** បាទ ជម្រាបសួរលោកមេធាវី។

**ស៖** លោកពូកអាចជម្រាបឈ្មោះពេញ ទៅអង្គសវនាការមួយសាទៀតបានទេ លោកពូ?

**ឆ៖** បាទ ខ្ញុំជម្រាបបាន ខ្ញុំឈ្មោះ ចៅ នី។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងសវនាការនេះ លោកពូចង់ឲ្យខ្ញុំហៅឈ្មោះលោកពូ ឬក៏ត្រឹមហៅតែលោកពូបានហើយ?

**ឆ៖** សូមអញ្ជើញលោកមេធាវីហៅឈ្មោះពេញចុះ។

**ស៖** ហៅលោក ចៅ នី តែម្តង។

**ឆ៖** បាទ។

**ស៖** បាទ សូមអរគុណ។ លោកពូសុខសប្បាយជាទេ ថ្ងៃនេះ?

[១១:១៦:៤០]

**ឆ៖** បាទ ខ្ញុំសុខសប្បាយជាធម្មតា។

**ស៖** តើលោកពូធ្លាប់ចូលរួមសវនាការទេ ពីមុនមក?

**ឆ៖** ខ្ញុំធ្លាប់ចូលរួម ប៉ុន្តែចូលខាងក្រៅ មិនដែលបានចូលនៅខាងក្នុងសវនាការធំនេះទេ។

**ស៖** ចុះថ្ងៃនេះ លោកពូ មានអារម្មណ៍យ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ពេលវេលាមានតម្លៃណាស់ ហើយមេធាវីខ្លីទេ។ សូមលោកចូលទៅសួរសំណួរសារធាតុ ពាក់ព័ន្ធទៅនឹងបំណងនៃអង្គជំនុំជម្រះកំណត់ធ្វើសវនាការក្នុងសំណុំរឿង០០២/០១។ បាទ មិនមែនយកវេទិកានេះ ទៅសួរសំណួរបន្ទាប់បន្សំ ឬក៏សំណួរមិនពាក់ព័ន្ធឡើយ។ ព្រោះជំរុញល្បឿននៃកិច្ចដំណើរការសវនាការឲ្យបានឆាប់ ហើយមានប្រសិទ្ធភាព។ បាទ បើសំណួរហើយ វាអត់មានប្រយោជន៍អីសម្រាប់អង្គជំនុំជម្រះយកមកពិចារណាបានទេ។

**លោក គង់ ផល្លា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ ផល្លា៖**

**ស៖** សូមអធ្យាស្រ័យ អ៊ីចឹង មុននឹងខ្ញុំចាប់ផ្តើមសួរទៅសំណួរដែលពាក់ព័ន្ធនឹងអង្គហេតុក្នុងសំណុំរឿង០២/០១ នេះ។ បើសិនជាលោកពូត្រូវការពិសាទឹកអី លោកពូអាចចាក់ទឹកពិសាបាន មុននឹងចាប់ផ្តើមសួរ។

[១១:១៧:៥៥]

**លោក ចៅ នី៖**

**ឆ៖** បាទ អញ្ជើញសួរចុះ អត់អីទេ។

**ស៖** បាទអរគុណច្រើនលោកពូ។ មុននេះបន្តិច លោកពូបានជម្រាបទៅអង្គសវនាការទាំងមូលថា លោកពូលមានស្រុកកំណើតកម្ពុជាក្រោម។ តើលោកពូធ្វើដំណើរមកទីក្រុងភ្នំពេញនៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំមកពីកម្ពុជាក្រោម មកភ្នំពេញឆ្នាំ១៩៧០។

**ស៖** តើមូលហេតុអ្វីបានជាពូធ្វើដំណើរមកទីក្រុងភ្នំពេញ?

**ឆ៖** គោលបំណងខ្ញុំឡើងមកភ្នំពេញ កាលណោះ ខ្ញុំបំណងមកធ្វើទាហានម៉ៃហ្វក ទាហានរបស់អាមេរិកាំង។

[១១:១៨:៤៤]

**ស៖** ចុះហេតុអ្វីបានជាលោកពូមានបំណងចង់ចូលទាហានម៉ៃហ្វក?

**ឆ៖** ពីព្រោះទាហានម៉ៃហ្វកហ្នឹង មានលុយខែខ្ពស់ ដើម្បីចិញ្ចឹមគ្រួសារខ្ញុំឲ្យបានធូរធារ។

**ស៖** តើនៅទីបញ្ចប់លោកពូ បានចូលធ្វើទាហានម៉ៃហ្វក ឬទេ?

**ឆ៖** ពេលខ្ញុំមកដល់ភ្នំពេញ ខ្ញុំព្យាយាមនឹងចូលធ្វើទាហានដែរ ក៏ប៉ុន្តែបងប្រុស និងបងថ្លៃស្រីខ្ញុំគាត់អត់ឲ្យខ្ញុំធ្វើទាហានទេ។

**ស៖** បាទ សូមអរគុណច្រើន។ តើលោកពូមកទីក្រុងភ្នំពេញរស់នៅម្តុំណាដែរ?

**ឆ៖** ខ្ញុំបាទមកនៅភ្នំពេញ នៅផ្ទះបងខ្ញុំ នៅខាងក្រោយផ្សារអូឡាំពិក។

**ស៖** បងប្រុសលោកពូបង្កើត?

**ឆ៖** បងប្រុសបង្កើតខ្ញុំ និងបងថ្លៃស្រីខ្ញុំ។

**ស៖** តើបងប្រុសលោកពូបង្កើត គាត់មានមុខរបរអ្វីដែរ? ហើយគាត់មានកូនចៅប៉ុន្មាននាក់ដែរ?

**ឆ៖** បងប្រុសខ្ញុំគាត់ធ្វើជាមន្ត្រីធនាគារឥណទានជាតិ។

**ស៖** គាត់មានកូនប៉ុន្មាននាក់ដែរ។

**ឆ៖** គាត់មានកូនបីនាក់។

**ស៖** ពូអាចរៀបរាប់ឈ្មោះកូនទាំងអស់--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោករៀនសូត្រពីអ្នកដទៃ ហើយគួរឃ្លាតបន្តិច ហើយបង្អង់បន្តិច សឹមលោកចាប់ផ្តើមសំណួរ ពីព្រោះមានការបកប្រែភាសា។ ការបកប្រែភាសាបារាំង ភាសាអង់គ្លេស ហ្នឹងគឺទម្រាំតែចប់ គឺអាចប្រើពេលវេលាមួយ ដែលសមស្របដើម្បីឲ្យធ្វើការបកប្រែហ្នឹងវាប្រព្រឹត្តទៅបានល្អ។

[១១:២០:៥៧]

**សួរដោយលោក គង់ ផល្លា៖**

**ស៖** សូមតាំងសំណួរម្តងទៀត តើបងប្រុសរបស់ពូមានកូនប៉ុន្មាននាក់ដែរ ហើយតើកូនទាំងនោះឈ្មោះអ្វីខ្លះ?

**លោក ចៅ នី៖**

**ឆ៖** បងប្រុសខ្ញុំមានកូនបីនាក់។ កូនទី១ ឈ្មោះ ចៅ សួន, កូនទី២ ឈ្មោះ ចៅ យក្ស, កូនទី៣ ឈ្មោះ ឡា តាំង -- ឡាប៉ាំង។

**ស៖** បាទ សូមអរគុណច្រើន។ ប៉ុន្តែផ្អែកតាមឯកសារដែលខាងយើងបានទទួល--

**លោក គង់ ផល្លា៖**

លោកប្រធាននិងអង្គសវនាការទាំងមូលខ្ញុំបាទសូមលើកឯកសារលេខ D22/253, ERN ជាភាសាខ្មែរលេខ 00421599, 00421600, ភាសាអង់គ្លេស 004478480 (ស៊ីក) និងភាសាបារាំង 00858937។ ប៉ុន្តែនៅក្នុងពេលនេះ ខ្ញុំសូមអានតែភាសាខ្មែរទេ។

**សួរដោយលោក គង់ ផល្លា៖**

**ស៖** នៅក្នុងឯកសារ D22 លោកពូបានមានប្រសាសន៍ប្រាប់អ្នកធ្វើរបាយការណ៍ថា "នៅក្នុងសហករណ៍នោះអស់រយៈពេល៤ខែ។ ៤ ទៅ ៥ខែ ក្មួយខ្ញុំពីរនាក់បានធ្លាក់ខ្លួនឈឺ ខ្លួនស្គមរីងរៃ ហើយគ្មានអាហារគ្រប់គ្រាន់ទេ។ ធ្លាក់ខ្លួនឈឺដោយគ្មានថ្នាំព្យាបាល។ កុមារា ចៅ សួន អាយុប្រាំបីឆ្នាំបានស្លាប់នៅពេលនោះ។ បន្ទាប់មកប្រហែល ៤ទៅ៥ខែក្រោយមកកុមារា ឡាប៉ាំង អាយុ៥ឆ្នាំបានស្លាប់ទៀត។ ក្មេងទាំងពីរនោះ បានស្លាប់នៅដើមឆ្នាំ១៩៧៦"។ នៅក្នុងរបាយការណ៍នេះ លោកពូមានប្រសាសន៍ប្រាប់អ្នកធ្វើរបាយការណ៍ថា ក្មួយលោកពូមានតែពីរនាក់ទេ ប៉ុន្តែហេតុអីនៅក្នុងអង្គសវនាការនេះ លោកពូបានលើកឡើងថា មានក្មួយបីនាក់ទៅវិញ?

**ឆ៖** បាទ សូមជម្រាបពេលដែលខ្ញុំបំពេញ ឲ្យគេអ្នកបំពេញពាក្យបណ្តឹងនោះ ខ្ញុំនិយាយតែក្មួយដែលស្លាប់ពេលខ្ញុំបានដឹង។

**ស៖** អ៊ីចឹងមានន័យថា លោកពូប្រាប់អ្នកធ្វើរបាយការណ៍តែក្មួយដែលស្លាប់ ដែលលោកពូបានដឹងទេ មែនទេ?

[១១:២៣:៤៨]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

សះ សូមអរគុណ។ អ៊ីចឹងខ្ញុំចូលទៅសំណួរមួយចំនួនពាក់ព័ន្ធនឹងព្រឹត្តការណ៍ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ចាតើនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកពូនៅទីណាដែរ?

ឆះ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំនៅផ្ទះបងខ្ញុំ នៅខាងក្រោយផ្សារអូឡាំពិក។

សះ សូមអរគុណ។ តើនៅពេលនោះ មានរឿងហេតុអ្វីកើតឡើងចំពោះក្រុមគ្រួសាររបស់លោកពូទេ ហើយបើសិនជាមានលោកពូអាចរៀបរាប់ប្រាប់អង្គសវនាការទាំងមូល ហើយក៏ដូចជារឿងហេតុទាំងឡាយណាដែលលោកពូបានដឹងនៅថ្ងៃទី១៧ មេសា នោះដែរ?

ឆះ ខ្ញុំសូមគោរពលោកប្រធាន នៅថ្ងៃ១៧ មេសា ជាថ្ងៃជោគជ័យរបស់កម្ពុជាប្រជាធិបតេយ្យដែលចូលកាន់កាប់ទីក្រុងភ្នំពេញទាំងមូល។ នៅពេលនោះ ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញ គាត់ចេញមកអបអរសាទ នៃការ អ៎! ពួកកម្ពុជាប្រជាធិបតេយ្យ មានគ្នាច្រើន -- មានប្រជាពលរដ្ឋច្រើនដែលគាត់ទៅទទួលអបអរសាទរ។ ឯចំណែកគ្រួសារខ្ញុំៗអត់បានចេញទៅទទួលអបអរសាទរនោះទេ។

[១១:២៥:២៩]

សះ តើមានអ្វីចង់បន្ថែមទៀតទេ?

ឆះ នៅពេលនោះ ខ្ញុំមិនបានចេញទៅទទួលអបអរសាទរទេ ដោយសារខ្ញុំមានក្មួយតូចៗ ហើយនិងបងគាត់អត់ស្រួលខ្លួនផង។ ខ្ញុំមិនបានចេញទៅទទួល។

សះ បាទ សូមអរគុណច្រើន។ តើនៅពេលនោះក្មួយៗរបស់ពូអាយុប៉ុន្មានដែរ ពូអាចរៀបរាប់បានទេ?

ឆះ នៅពេលនោះ ក្មួយខ្ញុំ ចៅ សួន នោះ អាយុទើបតែ៧ឆ្នាំទេ ហើយ ចៅ យក្ស នោះ អាយុ៦ឆ្នាំ ចៅ ឡាប៉ាំង គាត់៤ឆ្នាំ។

សះ អរគុណច្រើន។ ចុះថ្ងៃ១៧ មេសា មានអ្វីកើតឡើងដែរ?

ឆះ ក្រោយថ្ងៃ១៧ មេសា រំលងប្រហែលជា២ ឬ៣ថ្ងៃក្រោយមក ទើបមានពួកទាហានខ្មែរក្រហមបានចេញប្រកាស ឲ្យប្រជាពលរដ្ឋចាកចេញពីទីក្រុងភ្នំពេញ។ នៅពេលនោះ ខ្ញុំក៏បានឮសូរមានផ្ទុះអាវុធ ហើយនិងស្នូរបងប្អូនគាត់ស្រែកលាយឡំ ដើររកបងប្អូនកូនចៅ ព្រមទាំងញាតិមិត្តដើម្បីត្រៀមខ្លួននឹងចាកចេញពីទីក្រុងភ្នំពេញ។ នៅពេលនោះ ពួកខ្មែរក្រហម មានដោយប្រដាប់អាវុធ គាត់កាន់អាវុធដើរមកដល់ខាងមុខផ្ទះបងខ្ញុំ គាត់ក៏ស្រែកថា "ពួកឯងត្រូវតែចេញឲ្យឆាប់ ប្រយ័ត្នយន្តហោះអាមេរិកាំងមកទម្លាក់គ្រាប់បែកងាប់ផុតពូជអស់"។ ក្រោយមកគ្រួសារខ្ញុំក៏យឺតយ៉ាវបន្តិច ពួកគេក៏

ស្រែកបន្ថែមទៀតថា "គ្រួសារឯងម៉េចក៏យឺតម្លេះ ចេញឲ្យផុត ឆាប់ៗរយៈពេល៣ថ្ងៃ ហើយក៏មិនបាច់យកអីវ៉ាន់អ្វីទៅតាមដែរ"។ ស្រែកហើយក៏វាស្ទុះមកច្រានបងខ្ញុំ ហើយក៏ត្រឡប់ -- ខ្ញុំៗក៏ចូលទៅក្នុងផ្ទះឪបុក្ខយផង និងរៀបចំអីវ៉ាន់បានខ្លះ អីវ៉ាន់ណាដែលយើងត្រូវយកតាមបានក៏យក តែទ្រព្យសម្បត្តិអ្វីក៏ខ្ញុំចោលទាំងអស់ គឺយកតែក្ឆួយ ហើយនិងនាំបងប្អូនរត់ចេញទៅក្រៅក្រុងតែប៉ុណ្ណោះ។

[១១:២៨:១១]

**ស៖** សូមអរគុណច្រើន។ តើលោកពូអាចរៀបរាប់ពីទិដ្ឋភាពនៃការចាកចេញពីទីក្រុងភ្នំពេញនៅថ្ងៃនោះបន្តិចបានទេ?

**ឆ៖** ពេលដែលខ្ញុំចាកចេញ -- ខ្ញុំនិងបងខ្ញុំចាកចេញពីទីក្រុងភ្នំពេញ ខ្ញុំគោលបំណងក្នុងចិត្តខ្ញុំនិងបងខ្ញុំ គឺទិសដៅខ្ញុំដើម្បីទៅស្រុកកំណើតខ្ញុំវិញ។ នៅពេលនោះ ខ្ញុំដើរទៅតាមផ្លូវមានអ្នកជំងឺខ្លះ គាត់ឈឺដេកដួលនៅតាមផ្លូវ មានអ្នកស្លាប់នៅជិតហ្នឹងជាច្រើន ប៉ុន្តែដូចនៅពេលដែលយើងជម្លៀសខ្លួននោះគ្មានអ្នកណាជួយអ្នកណាបានទេ។

**ស៖** អរគុណច្រើន។ តើលោកពូធ្វើដំណើរនៅតាមផ្លូវណាដែរ។

**ឆ៖** ពេលនោះ ខ្ញុំក៏ឆ្ពោះទៅសំដៅផ្លូវជាតិលេខ២ ដើម្បីគោលដៅគោលរបស់ខ្ញុំឆ្ពោះទៅទឹកដីខ្មែរកម្ពុជាក្រោមស្រុកកំណើតរបស់ខ្ញុំវិញ។

**ស៖** ពូបានទៅដល់ស្រុកកំណើតរបស់ខ្លួនទេ?

**ឆ៖** ខ្ញុំមិនបានទៅដល់ស្រុកទេ។

**ស៖** បើអ៊ីចឹងពូទៅដល់ត្រឹមទីកន្លែងណាដែរ?

**ឆ៖** បាទ ពេលនោះ ខ្ញុំដើរទៅរយៈពេលប្រហែលជា១០ថ្ងៃ បានខ្ញុំទៅដល់ស្រុកបាទី ខេត្តតាកែវ នៅភូមិត្រពាំងសាប។ ទៅដល់នោះ ខ្ញុំត្រៀមនឹង -- បំណងរបស់ខ្ញុំគឺគោលដៅទៅៗស្រុកខ្ញុំកម្ពុជាក្រោមទេ ក៏ប៉ុន្តែខ្ញុំទៅដល់ភូមិត្រពាំងសាបនោះមានគេលបប្រាប់ខ្ញុំថា "បើបងប្អូនណាមានដើមកំណើតខ្មែរកម្ពុជាក្រោម គាត់ចុះទៅដល់ព្រំដែនគេសម្លាប់ចោលអស់ហើយ"។

**ស៖** បាទ អ៊ីចឹងពូក៏សម្រេចចិត្តនៅទីនោះតែម្តងឬ?

**ឆ៖** ខ្ញុំក៏សម្រេចចិត្តលាក់ខ្លួននៅភូមិត្រពាំងសាប ស្រុកបាទីនោះជាច្រើនថ្ងៃដែរនៅទីនោះ។

**ស៖** បាទ សូមអរគុណច្រើន។ មុននឹងទៅដល់ហេតុការណ៍នៅក្នុងឃុំត្រពាំងសាប តើលោកពូអាចរៀបរាប់លម្អិតពីទិដ្ឋភាពនៃការចាកចេញពីទីក្រុងភ្នំពេញក្នុងរយៈពេល១០ថ្ងៃ ដែលលោកពូបានធ្វើ

ដំណើរដោយថ្មើជើងទៅដល់ត្រពាំងសាបបានទេ? តើថ្ងៃទី១ ពូស្នាក់នៅទីណា? ថ្ងៃទី២ ស្នាក់នៅកន្លែងណា? ហូបចុកម៉េច? ស្នាក់នៅម៉េច? ហើយក្មួយរបស់លោកពូដែលតូចៗនោះយ៉ាងម៉េចដែរ? បើសិនជាលោកពូអាចចាំបាន ពូអាចរៀបរាប់តាមថ្ងៃ បើសិនជាពូមិនអាចចាំទេ អាចរៀបរាប់ជារួមក៏បានដែរ។

[១១:៣០:៤០]

**ឆ៖** បាទ សូមៗជម្រាបលោកមេធាវី បើរៀបរាប់ថ្ងៃប្រហែលជាខ្ញុំអត់បានចាំទេ បើសរុបជាពេលដែលយើងធ្វើដំណើរ យើងមិនអាចកំណត់ថ្ងៃណា ដែលយើងកំណត់នោះបាន លោកមេធាវី។

**ស៖** សូមអរគុណច្រើន បើអ៊ីចឹងលោកអាចសរុបព្រឹត្តិការណ៍១០ថ្ងៃនេះបន្តិចបានទេ? ទាំងការហូបចុក ទាំងការស្នាក់នៅ ទាំងសុខភាពរបស់ក្រុមគ្រួសារលោកពូ ក៏ដូចជាទិដ្ឋភាពអ្វីដែលលោកពូបានឃើញ។

**ឆ៖** ទិដ្ឋភាពដែលខ្ញុំបានចាកចេញពីទីក្រុងភ្នំពេញ ឆ្ពោះទៅដល់ស្រុកបាទី ភូមិត្រពាំងសាបនោះ ពេលចាកចេញទៅនោះគឺលំបាកមែនទែន ពីព្រោះដែលក្មេងៗគាត់មិនដែលចេញទៅនៅតាមជនបទទេ គាត់កើតនៅទីក្រុងភ្នំពេញ។ ពេលនោះបង ទាំងបងខ្ញុំ ទាំងបងថ្លៃស្រីខ្ញុំ ទាំងខ្ញុំក៏ -- ម្នាក់បីក្មួយ ម្នាក់មួយ។ ហេតុដូច្នេះហើយដែលពេលទៅនោះ គ្មានបានយកអ្វីទៅតាមខ្លួនទេ គ្រាន់តែមានសម្លៀកបំពាក់ខ្លះ ហើយនិងយើងប្រើសារុង សារុងនេះក្រាលឲ្យក្មេងដេកនៅតាមផ្លូវ។ នៅពេលធ្វើដំណើរនោះការនៅ -- ភ្លាមៗនោះនៅតាមផ្លូវយើងអាចមានដោះៗដូរបាន យើងមានលុយជាប់នឹងខ្លួនយើងអាចទិញអីវ៉ាន់ខ្លះៗឲ្យក្មួយហូបបាន ក៏ប៉ុន្តែអីវ៉ាន់នោះថ្លៃណាស់។ ទោះតម្លៃនោះប៉ុន្មានក៏ដោយក៏ត្រូវទិញឲ្យក្មេងហូបឲ្យបានគ្រប់គ្រាន់ដែរ សុខចិត្តឲ្យមនុស្សចាស់អត់ ឲ្យក្មេងឆ្អែត។

[១១:៣៣:៣៤]

**ស៖** សូមអរគុណច្រើន។ មុននេះបន្តិច លោកពូបានមានប្រសាសន៍ថា "ពេលពូទៅដល់ខេត្តតាកែវ នៅត្រពាំងសាបហ្នឹងមានគេប្រាប់ថា បើជាខ្មែរកម្ពុជាក្រោមហើយនិងធ្វើដំណើរទៅ នឹងត្រូវគេសម្លាប់"។ តើអ្នកណាជាអ្នកប្រាប់លោកពូ?

**ឆ៖** បាទ នោះជាសំណាងរបស់ខ្ញុំវិញទេ បើយើង -- បើនិយាយពីឈ្មោះពួកគាត់ដែលប្រាប់ខ្ញុំនោះ ខ្ញុំក៏អត់បានដឹងដែរ ប្រហែលជាសំណាងរបស់ខ្ញុំទេ។

**ស៖** អ៊ីចឹងពូមិនចាំបានថា តើអ្នកណាជាអ្នកប្រាប់លោកពូទេ? ប្រជាជនធ្វើដំណើរពីភ្នំពេញដែរ

ជាអ្នកថ្មីជាមួយលោកពូ ឬក៏អ្នកមូលដ្ឋាន ឬក៏អ្នកណាម្នាក់ដែរ?

**ឆ៖** បាទ នោះគាត់គឺជាអ្នកមូលដ្ឋាននោះ។

**ស៖** មូលដ្ឋាននោះ។

**លោក គង់ ផល្លះ៖**

បាទ អឺចឹងខ្ញុំសូមអរគុណលោកប្រធាន អង្គសវនាការទាំងមូល។ ខ្ញុំសូមបញ្ចប់ការសាកសួររបស់ខ្ញុំ ប៉ុន្តែសូមប្រគល់ការសាកសួរបន្តទៅឲ្យសហការីរបស់ខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរដល់អស់លោក លោកស្រីទាំងអស់គ្នា។ វាជាកិត្តិយសរបស់ខ្ញុំ ដែលខ្ញុំបានមកចូលរួមនៅក្នុងទីនេះ ហើយបានធ្វើការសួរទៅលើលោកដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក ម៉ះដេវ ម៉ូហាន៖**

**ស៖** មេធាវីជាតិបានសាកសួរលោកអំពីអ្វីដែលបានកើតឡើងមុនពេលដែលខ្មែរក្រហមចូលមកកាន់កាប់ គឺថាមុនពេលដែលមានការជម្លៀសនៅខែមេសា ឆ្នាំ៧៥។ ពាក់ព័ន្ធទៅនឹងអ្វីដែលគាត់បានចោទសួរពីមុន លោកបានឆ្លើយទៅគាត់ថា លោកមានគោលដៅធ្វើដំណើរទៅកម្ពុជាក្រោម ប៉ុន្តែលោកឈប់នៅស្រុកបាទី ខេត្តតាកែវ។ តើវាជាការត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយបែបនេះ?

[១១:៣៦:១១]

**លោក ចៅ នី៖**

**ឆ៖** បាទ លោកមេធាវីនិយាយនេះ គឺត្រឹមត្រូវ។

**ស៖** ហើយហេតុផលដែលលោកឈប់នៅស្រុកបាទីហ្នឹង គឺថាដោយសារតែមានមនុស្សម្នាក់ប្រាប់លោកថា វាមិនអាចនោះទេដែលលោកធ្វើដំណើរទៅព្រំដែនកម្ពុជា-វៀតណាមនោះ តើវាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតមែន។ បើគេមិនប្រាប់ខ្ញុំ ខ្ញុំប្រហែលជាខ្ញុំហួសទៅកម្ពុជាក្រោមហើយ។

**ស៖** តើបុគ្គលនោះ គាត់មានប្រាប់អីផ្សេងទៀតដល់លោកទេ នៅពេលដែលលោកនៅក្នុងឃុំ

ត្រពាំងសាបនោះ?

**ឆ៖** នៅពេលនោះ គាត់ប្រាប់បន្ថែមទៀតថា "បើយើងជាខ្មែរកម្ពុជាក្រោម ត្រូវលាក់ប្រវត្តិរូបទើបរស់"។

[១១:៣៧:២១]

**ស៖** តើលោកដឹងថាហេតុអ្វីបានជាលោកត្រូវលាក់អត្តសញ្ញាណរបស់លោកជាខ្មែរកម្ពុជាក្រោមដែរឬទេ?

**ឆ៖** ពីព្រោះខ្ញុំខ្លាចគេសម្លាប់ខ្ញុំ ទើបខ្ញុំលាក់ប្រវត្តិរូប លែង -- ខ្ញុំពេលនោះខ្ញុំលែងដាក់ឈ្មោះ ចៅ ទៀតហើយ។

**ស៖** តើលោកប្តូរត្រកូលរបស់លោកទៅជាអ្វីដែរ?

**ឆ៖** នៅពេលនោះ ឈ្មោះខ្ញុំនៅដដែលទេ គ្រាន់តែខ្ញុំដូរត្រកូល ខ្ញុំដាក់ លន់ នី។

**ស៖** ដូច្នេះលោកដូរត្រកូលរបស់លោកពី ចៅ ទៅជា លន់ ដោយសារតែលោកប្រាប់តុលាការថាលោកឈ្មោះ ចៅ នី។ តើលោកមានហេតុផលអ្វីទើបដូរពី ចៅ ទៅជា លន់? តើគេដឹងដែរឬទេប្រសិនបើលោកទុកត្រកូលចៅហ្នឹង? តើគេដឹងថាលោកជាខ្មែរកម្ពុជាក្រោមដែរឬទេ ប្រសិនបើលោករក្សាត្រកូលចៅ?

[១១:៣៨:៤៥]

**ឆ៖** មូលហេតុខ្មែរកម្ពុជា គឺបែងចែកត្រកូល ដូចជាខេត្តមាត់ជ្រូក គេដាក់សុទ្ធតែត្រកូល ចៅ។ បើខេត្តត្រាវិញ ច្រើនតែដាក់ សឺន។ ខេត្តឃ្លាំង គេច្រើនដាក់ ថាច់។ បើក្រមួនស គេច្រើនតែដាក់ យ៉ាន់ បើយើងនៅនេះហៅថា ដាញ់។ អ៊ីចឹងត្រកូលខ្មែរកម្ពុជាក្រោម ច្រើនខេត្ត ច្រើនតែខុសៗគ្នា ដើម្បីគេស្រណុកចំណាំ។

**ស៖** សូមអរគុណលោក ចៅ នី។ កន្លងមកលោកបានប្រាប់ថា នៅពេលដែលលោកនៅឃុំត្រពាំងសាប លោកលាក់ប្រវត្តិរូបខ្លួន ហើយនិងលាក់ប្រវត្តិរូបគ្រួសារ មិនប្រាប់គេថាជាខ្មែរកម្ពុជាក្រោម ប៉ុន្តែប្រជាជនដែលរស់នៅមូលដ្ឋានហ្នឹង គេដឹងថាលោកជាប្រជាជនថ្មីដែរឬទេ?

**ឆ៖** នៅពេលនោះ គេនៅមូលដ្ឋាននោះ គេដាក់ខ្ញុំតែ ហៅតែពួក១៧ទេ គេមិនដែលហៅអ្វីផ្សេងពីនេះទេ។

**ស៖** ហើយក្រៅពីក្រុមគ្រួសារលោក តើមានប្រជាជន១៧មេសាដទៃទៀតនៅឃុំត្រពាំងសាប

ជាមួយលោកដែរឬទេ?

**ឆ៖** ពេលខ្ញុំនៅទីនោះពួក១៧មានច្រើនណាស់ ច្រើនៗមិនមែនតែគ្រួសារខ្ញុំមួយនោះទេ។

**ស៖** តើក្រុមគ្រួសារលោក និងប្រជាជន១៧មេសាដទៃទៀតហ្នឹង តើត្រូវគេប្រព្រឹត្តបែបណាដាក់ដែរនៅពេលរស់នៅក្នុងឃុំត្រពាំងសាបនោះ?

[១១:៤១:00]

**ឆ៖** ពេលនោះនៅទីនោះគេមិនដែលនិយាយអ្វីល្អឲ្យដល់ពួក១៧ទេ។ គេតែងតែមានពាក្យថាពួក១៧ ពួកមូលធននិយម។ ពួកធ្វើស្រែលើខ្នងរាស្ត្រ ហេតុដូច្នេះហើយពួក១៧ នៅត្រង់ណាត្រូវតែពួកមូលដ្ឋានតំបន់នោះតែងតែរិះគន់ ភាសានេះ។

**ស៖** ក្នុងពេលដែលលោករស់នៅជាមួយគ្រួសារនៅត្រពាំងសាបនោះ តើក្រុមគ្រួសារលោកធ្វើអ្វីដើម្បីអាចរស់រានមានជីវិតបាន? ព្រោះដោយសារលោកមានបងប្អូន មានបង ហើយមានក្មួយបីនាក់ទៀត តើលោកធ្វើអ្វីដើម្បីទទួលបានអាហារ ឬក៏ទទួលបានចំណីនៅពេលនោះ?

**ឆ៖** នៅពេលថ្មីៗ ពេលរំដោះដែលយើងទៅដល់ទីនោះ ៩, ១០ថ្ងៃ រហូតដល់១ខែនេះ គឺការងារអ្វីយើងមិនទាន់បានធ្វើទាំងអស់។ គឺថានៅពេលនោះយើងមានភ្ជាប់អីវ៉ាន់ទៅពីទីក្រុងនេះ ដូចជាមាសប្រាក់អីហ្នឹង ដោះដូរ ហូបបន្ត ចេះចល័តរហូត ចេះតែនៅម្តងកន្លែងនេះ ចល័ត ចេះចល័តទៅរហូត គេឲ្យនៅត្រង់ណា ចេះតែយើងនៅតៗ រហូតពេលនោះទៅដល់មានឃើញផ្លូវរថភ្លើង ខ្ញុំចេះតែនៅបន្តប្រប ៗផ្លូវរថភ្លើងហ្នឹងរហូតទៅ។

[១១:៤២:៤៥]

**ស៖** លោកទើបតែប្រាប់ថា លោកទៅដល់ទីតាំងមួយដែលមានផ្លូវរថភ្លើង។ ឥឡូវនេះខ្ញុំចង់ឲ្យលោកនិយាយអំពីត្រពាំងសាប។ ហេតុអ្វីបានជាលោករស់នៅត្រពាំងសាប ក្នុងស្រុកបាទីខេត្តតាកែវ តើស្ថានភាពនៅត្រពាំងសាបនោះវាមានលក្ខណៈបែបណាដែរ?

**ឆ៖** ស្ថានភាពប្រជាពលរដ្ឋមូលដ្ឋានគេ គេមិនសូវយកចិត្តទុកដាក់ជាមួយយើងទេ តែងតែគេរិះគន់ឲ្យយើងមិនដែលឲ្យពួក១៧ ឲ្យល្អទេ។ ស្ថានភាពនេះយើងមិនទ្រាំអាចនៅបាន អ៊ីចឹងចេះតែជម្លៀសខ្លួនទៅបន្តៗ ចល័ត។

**ស៖** តើលោកនៅឃុំត្រពាំងសាបហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** នៅពេលនោះប្រហែលជានៅឃុំត្រពាំងសាបចំនោះ ប្រហែលជា ៩, ១០ថ្ងៃតែប៉ុណ្ណោះទេ

ប្រហែល១០ថ្ងៃ ឬ១ខែប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកចាកចេញពីឃុំត្រពាំងសាប តើលោកទៅទាំងអស់គ្នាជាមួយក្រុមគ្រួសារលោកតែម្តង ឬក៏លោកទៅតែម្នាក់ឯងទេ?

[១១:៤៥:១៧]

**ឆ៖** ខ្ញុំទៅនោះជារួមទាំងអស់ គ្រួសារខ្ញុំមាននឹងពួក១៧ជាច្រើន ទៅរួមគ្នា។

**ស៖** នៅពេលដែលលោកចាកចេញជាមួយគ្រួសាររបស់លោក និងប្រជាជន១៧មេសា ដោយសារតែអ្វីដែលប្រជាជនមូលដ្ឋានគេនិយាយហ្នឹង តើលោកចាកចេញទៅណាដែរ? តើលោកទៅកម្ពុជាក្រោម ឬក៏ទៅកន្លែងណាផ្សេង?

**ឆ៖** ខ្ញុំសូមជម្រាបមេធាវី ពីព្រោះខ្ញុំកាលពីមកពីកម្ពុជាក្រោមមកនោះ ខ្ញុំមកដល់ -- មកពីកម្ពុជាក្រោមឡើងទៅនៅភ្នំពេញតែម្តង។ ដល់ចូលទៅតំបន់គេក្នុងហ្នឹង ខ្ញុំអត់គេកន្លែងណាជាកន្លែងណាទេ។ គ្រាន់តែ ចេះតែទៅអ៊ីចឹង ឃើញផ្លូវរថភ្លើងតែប៉ុណ្ណោះទេ មិនដឹងថាតំបន់នោះជាតំបន់ណាទេ។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ ដើម្បីជម្រាបដល់អង្គជំនុំជម្រះទាំងមូល តើលោកចង់និយាយថាលោកស្គាល់ផ្លូវជាតិលេខ២ ដោយសារតែលោកធ្វើដំណើរពីកម្ពុជាក្រោមមកភ្នំពេញ។ ប៉ុន្តែនៅពេលដែលលោកចាកចេញពីត្រពាំងសាបទៅភ្នំពេញលោកអត់ដឹងទេ លោកគ្រាន់តែចាកចេញទៅជាមួយគ្រួសារតែម្តង។ តើវាជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ នេះជាការពិត។

**ស៖** នៅពេលដែលលោកធ្វើដំណើរ គឺនៅពេលដែលលោកចាកចេញពីឃុំត្រពាំងសាបជាមួយគ្រួសារ និងប្រជាជន១៧មេសាដទៃទៀត តើលោកពឹងផ្អែកទៅលើអ្វីដើម្បីរស់រានមានជីវិត? ព្រោះថាលោក ថាលោកយកតែអីវ៉ាន់ ឬក៏ម្ហូបអាហារបន្តិចបន្តួច នៅពេលដែលលោកចាកចេញពីភ្នំពេញ។ ដូច្នេះ នៅពេលដែលលោកចាកចេញពីត្រពាំងសាបទៅកន្លែងផ្សេងហ្នឹង លោកមានអ្វីដើម្បីហូប មានអ្វីដើម្បីរស់រានមានជីវិតបន្ត?

**ឆ៖** នៅក្នុងរយៈពេល ២, ៣ខែ ហ្នឹង គឺដោះដូរហូបរហូត មិនទាន់បានចេញទៅធ្វើការងារអីទាំងអស់។ មិនទាន់បានធ្វើអ្វីដើម្បីចំណូល ដើម្បីហូបទេ អ៊ីចឹងនៅមានអីវ៉ាន់នៅជាប់ខ្លួនហ្នឹងដោះដូរហូបបន្ត។

[១១:៤៧:០៧]

**សៈ** តើការធ្វើដំណើរហ្នឹងវាមានការប៉ះពាល់ដល់ក្រុមគ្រួសាររបស់លោកទេ ជាពិសេសក្មួយៗ ដែលមានអាយុ ៥, ៦ ឆ្នាំនោះ? តើមានការប៉ះពាល់អ្វីដែរទេ?

**ឆៈ** បាទ សូមជម្រាបប្រសាសន៍ បើនិយាយពីការប៉ះពាល់ ការវេទនា លំបាកនោះ គឺលំបាកខ្លាំង ខ្លាំងមែនទែន មិនមែនជាធម្មតាទេ។ យើងទៅនៅកណ្ដាល -- នៅពេលនោះគឺពេលភ្លៀងខ្យល់ខ្លាំង ក្មេងតូចនៅតាមវាលស្រែ ហេតុដូច្នេះហើយ តែងប៉ះពាល់ពីការទុក្ខលំបាកវេទនានោះខ្លាំងមែនទែន។

**សៈ** ដោយសារលោកធ្វើដំណើរពីកន្លែងមួយទៅមួយកន្លែង ដើម្បីស្វែងរកម្ហូប និងសម្លៀកបំពាក់។ មុននេះលោកបានប្រាប់ថាលោកបានមកដល់កន្លែងមួយដែលមានផ្លូវរថភ្លើង។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ពេលយើងធ្វើដំណើរនោះ យើងមកបានប៉ះ គឺបានជួបផ្លូវរថភ្លើងមែន។

**សៈ** តើលោក ហើយនិងក្រុមគ្រួសាររបស់លោកធ្វើដំណើរតាមផ្លូវដែក ដើម្បីត្រឡប់មកភ្នំពេញវិញដែរឬទេ?

**ឆៈ** នៅពេលនោះខ្ញុំគិត សម្រេចចិត្តជាមួយគ្រួសារខ្ញុំ ជាមួយបងខ្ញុំ និងបងថ្លៃស្រីខ្ញុំដើម្បីវិលត្រឡប់មកទីក្រុងភ្នំពេញវិញ។

**សៈ** នៅពេលដែលលោកធ្វើដំណើរជាមួយគ្រួសាររបស់លោកតាមផ្លូវដែក ត្រឡប់មកពីខេត្តតាកែវ មកភ្នំពេញ តើមានមនុស្សដទៃទៀតធ្វើដំណើរជាមួយលោកដែរឬទេ? ឬមួយក៏លោកធ្វើដំណើរតែជាមួយក្រុមគ្រួសាររបស់លោកទេ?

**ឆៈ** បាទ មាន មានច្រើនៗ។

[១១:៤៩:៤០]

**សៈ** ចំពោះមនុស្សដទៃទៀត ឬក៏គ្រួសារដទៃទៀតដែលធ្វើដំណើរជាមួយលោកហ្នឹង តើពួកគាត់ជាប្រជាជន១៧មេសា ដែរឬមួយក៏យ៉ាងម៉េច?

**ឆៈ** ពីព្រោះគ្នាច្រើន យើងមិនដឹងថាអ្នកទាំងអស់នោះជា១៧មេសា ទាំងអស់ ហើយឬមានមូលដ្ឋានលាយនឹងយើងដែរ ក៏ខ្ញុំមិនបានកំណត់ដឹងដែរ។

**សៈ** នៅពេលដែលលោកធ្វើដំណើរតាមផ្លូវដែកឆ្ពោះមកទីក្រុងភ្នំពេញនោះ តើលោកអាចរៀបរាប់បានដែរឬទេ អំពីស្ថានភាពក្រុមគ្រួសាររបស់លោក? តើលោកបែបណាដើម្បីរកបាននូវម្ហូបអាហារ សម្លៀកបំពាក់ ហើយនិងទឹក នៅពេលដែលលោកធ្វើដំណើរតាមផ្លូវដែកនោះ?

**ឆ៖** ដូចខ្ញុំមានប្រសាសន៍ពីមុនមកហើយថា យើងមិនទាន់ធ្វើអ្វីមួយនឹងបានទេ។ មានតែទ្រព្យសម្បត្តិជាប់ពីទីក្រុងភ្នំពេញហ្នឹងទៅ យើងដោះដូរគ្នា ដែលយើងបានហូប។ បើសិនថាយើងទៅការងារអ្វីផ្សេង អត់ទាន់បានធ្វើទេ។ នៅក្នុងពេលនោះ គឺចល័តពេលរហូត ចល័តមិនទាន់បានទាន់ធ្វើអ្វីទាំងអស់ នៅក្នុងសហករណ៍គេក៏គេមិនទាន់ឲ្យយើងចូលដែរ។

[១១:៥១:១០]

**ស៖** តើពេលហ្នឹងលោកអាចធ្វើដំណើរមកដល់ភ្នំពេញដែរឬក៏អត់ នៅពេលដែលលោកធ្វើដំណើរតាមផ្លូវដែកនុ៎ង?

**ឆ៖** ពេលខ្ញុំធ្វើដំណើរត្រឡប់មកវិញនោះ គឺអត់បានដល់ទីក្រុងភ្នំពេញទេ។

**ស៖** ហេតុអ្វីបានជាលោកមិនធ្វើដំណើរមកភ្នំពេញ ដោយសារតែលោកឈប់ ឬក៏យ៉ាងម៉េច?

**ឆ៖** នៅពេលនោះ ខ្ញុំសម្រាកគ្រប់ទីកន្លែង។ ក៏ប៉ុន្តែគោលដៅកន្លែងដែលខ្ញុំស្នាក់នោះ គឺខ្ញុំមិនបានដឹងទីណា ឬទីណាទេ។ គ្រាន់តែដឹងថាពេលចល័តមកម្ដងៗ ដឹងថាត្រឡប់មកក្រោយ សំដៅមកទីក្រុងភ្នំពេញវិញ។

**ស៖** ហើយចំពោះគ្រួសាររបស់លោក សមាជិកគ្រួសារ រួមទាំងលោកធ្វើដំណើរមកភ្នំពេញនោះ តើមានកងឈ្លប ឬក៏ទ័ពខ្មែរក្រហមនោះបញ្ឈប់លោកតាមផ្លូវដែរឬទេ?

**ឆ៖** រយៈពេលជាយូរ ដែលខ្ញុំធ្វើដំណើរត្រឡប់តាមផ្លូវរថភ្លើងដើម្បីមកភ្នំពេញនោះ មកដល់កន្លែងជាច្រើនដែលមាន មិនដឹងជាឈ្លប ហើយឬជាកងទ័ព ពីព្រោះគាត់ជាខោអាវខ្មៅ ហើយប្រដាប់អាវុធ មានក្រមារ័ណ្ដក មិនដឹងថាគាត់ហ្នឹងជាកងទ័ព ហើយឬមួយជាឈ្លបទេ។ គាត់ហ្នឹងមានការឲ្យយើងឈប់សម្រាក ឬមួយគាត់ឲ្យយើងបន្តទៅមុខទៀត អាហ្នឹងមាន មានជួបច្រើន។

[១១:៥៣:៣០]

**ស៖** តើលោកអាចរៀបរាប់ជូនតុលាការ ថាតើឈ្លបទាំងអស់ហ្នឹងស្លៀកពាក់បែបម៉េចដែរ? ហើយគេនិយាយបែបម៉េចទៅកាន់លោក?

**ឆ៖** កងឈ្លបទាំងអស់នោះ គាត់ស្លៀកខោអាវខ្មៅ មានក្រមារ័ណ្ដក ហើយនិងទ្រនាប់ជើងគាត់កង់ឡាន។ ហើយគាត់ពោលពាក្យថា ពួក១៧ ត្រូវតែត្រឡប់ទៅកន្លែងផ្សេងទៀត ពីព្រោះកន្លែងគេហ្នឹងគេអត់ប៉ានឲ្យនៅយូរ។ អ៊ីចឹង គេឲ្យយើងបន្តចេះតែមកហើយ ខ្ញុំចេះតែមកអ៊ីចឹងជាមួយបងប្អូនជាមួយប្រជាពលរដ្ឋច្រើនទៀត ហើយខ្ញុំមិនដឹងទីតាំងទេ មិនដឹង -- ហើយមកដល់គោលដៅត្រង់ណា

ខ្ញុំអត់ដឹងទេ។

**ស៖** តើនៅពេលណាមួយនោះ កងឈ្លបទាំងអស់នេះ មានបញ្ជប់លោកទេ ឬក៏ឲ្យលោកឡើងទៅជិះរថភ្លើងអីដែរឬទេ?

**ឆ៖** ពេលនោះ រយៈពេលជាយូរទើបមានកងឈ្លបគាត់ឃាត់ឲ្យប្រជាពលរដ្ឋហ្នឹងនៅទីនោះមួយកន្លែង ហើយក្រោយមករយៈពេលប៉ុន្មានថ្ងៃក្រោយមក ទើបមានរថភ្លើងនេះ រត់កាត់។ ហើយពួកទាំងនោះ ក៏បង្ខំឲ្យប្រជាពលរដ្ឋទាំងអស់នោះ ឡើងរថភ្លើង។

**ស៖** ដូច្នេះ លោក ចៅ នី គឺថាលោកធ្វើដំណើរយ៉ាងវែងដែលលោកធ្វើដំណើរ និងស្នាក់នៅកន្លែងផ្សេងៗ អស់រយៈពេលយ៉ាងយូរ តើដោយសារតែលោកមិនអាចប្រាប់កាលបរិច្ឆេទបាន តើលោកអាចគ្រាន់តែប៉ាន់ប្រមាណមើល ថាតើនៅចុងឆ្នាំ៧៥ និងដើមឆ្នាំ៧៦ហ្នឹង តើលោកធ្វើតាមរថភ្លើងហ្នឹងទៅត្រង់ណាខ្លះ? ពេលណាខ្លះ?

[១១:៥៥:៥៦]

**ឆ៖** នៅពេលដែលខ្ញុំឡើងរថភ្លើងនោះ មិនដឹងថា កំណត់ហ្នឹងប៉ុន្មានទេ ប្រហែលជាពេលឡើងរថភ្លើងរយៈពេលប្រហែលជាមួយថ្ងៃទេ។ ពេលនោះ ខ្ញុំទៅដល់ស្រុកមោងឫស្សី ចុះនៅរ៉ាមោងឫស្សី។

**ស៖** មុននឹងយើងនិយាយអំពីអ្វីដែលកើតឡើងនៅមោងឫស្សី ខេត្តបាត់ដំបង។ ខ្ញុំសូមត្រឡប់ក្រោយបន្តិច ដូច្នេះ លោកអាចជម្រាបជូនតុលាការនូវឧប្បត្តិហេតុដែលលោក និងគ្រួសាររបស់លោកត្រូវគេបង្ខំឲ្យឡើងជិះរថភ្លើង តើលោកអាចរៀបរាប់អំពីស្ថានភាពនេះទេ? តើលោកមានជម្រើសអីដែលថាខ្មែរក្រហមអាចអនុញ្ញាតឲ្យលោកបន្តដំណើរដោយថ្មើរជើងបានតទៅទៀតទេ? ឬក៏ថាលោកត្រូវតែឡើងជិះរថភ្លើងដោយសារតែការបង្ខិតបង្ខំនោះ?

**ឆ៖** បាទ សូមជម្រាប នៅពេលនោះ គឺគ្មានអ្នកណាហ៊ានប្រឆាំងជាមួយបទបញ្ជារបស់ពួកឈ្លបទាំងនោះទេ។

**ស៖** ហើយថាតើមានកងឈ្លបប៉ុន្មាននាក់ ដែលជួបលោក និងគ្រួសាររបស់លោក ក៏ដូចជាប្រជាជនដទៃទៀត ហើយបង្ខំឲ្យអ្នកទាំងនោះ ឡើងជិះរថភ្លើងនោះ?

**ឆ៖** ពេលនៅដែលកន្លែងបងប្អូន កូនក្មួយខ្ញុំនៅនេះ ខ្ញុំឃើញប្រហែល ១០នាក់ទេ ដែលបង្ខំឲ្យពួកខ្ញុំឡើងរថភ្លើង។ ប្រដាប់ដោយអាវុធគ្រប់ដៃ។

[១១:៥៧:៤៦]

**សៈ** ក្រៅពីគ្រួសាររបស់លោក និងលោកផ្ទាល់ ថាតើមានប្រជាជនប៉ុន្មាននាក់ដែលធ្វើដំណើរថ្មើរជើងជាមួយលោក ហើយត្រូវបានគេបង្ខំឲ្យឡើងជិះរថភ្លើងនោះ លោកអាចប៉ាន់ប្រមាណចំនួននេះដោយប្រហាក់ប្រហែលបានទេ?

**ឆៈ** បាទ នៅពេលនោះ ប្រជាពលរដ្ឋជាច្រើនដែលនៅលើរថភ្លើងនោះ មិនមែនតែគ្រួសារខ្ញុំទេ។ ពីព្រោះរថភ្លើងនោះ មកដល់កន្លែងនេះ នៅលើរថភ្លើងនោះ មានមនុស្សជាច្រើនហើយដែរ។

**សៈ** តើស្ថានីយឈ្មោះអីដែរ ដែលគេបង្ខំឲ្យលោកឡើងជិះរថភ្លើងនោះ ដែលលោកត្រូវធ្វើដំណើរពីតាកែវ មកភ្នំពេញ តែលោកមិនបានមកដល់ភ្នំពេញទេ។ តើស្ថានីយនោះ ជាស្ថានីយចន្លោះពីខេត្តតាកែវ មកភ្នំពេញនោះ ឈ្មោះអីដែរ?

[១១:៥៨:៥៦]

**ឆៈ** សូមជម្រាបប្រសាសន៍ ខ្ញុំមិនដឹងកន្លែងនោះ ជាកន្លែងណាទេ ពីព្រោះខ្ញុំមិនដែលនៅតំបន់នោះ ខ្ញុំអត់បានដឹងទេ។

**សៈ** នៅលើរថភ្លើង តើមានកងឈ្លបខ្មែរក្រហមនៅលើរថភ្លើងនោះដែរឬទេ?

**ឆៈ** នៅលើរថភ្លើងមានកងការពាររថភ្លើង មានពួកខ្មែរក្រហមនៅលើនោះដែរ។

**សៈ** តើពួកគេមានផ្តល់បាយទឹកទៅដល់ក្រុមគ្រួសាររបស់លោក និងប្រជាជនដែលជិះនៅលើរថភ្លើងនោះដែរឬទេ?

**ឆៈ** បាទ នៅពេលនោះ អត់មានទេ។

**សៈ** នៅលើរថភ្លើង តើគេអនុញ្ញាតឲ្យលោកនិយាយទៅកាន់ប្រជាជនដទៃទៀតដែរឬទេ?

**ឆៈ** នៅពេលនោះ យើងនិយាយបានតែអ្នកនៅជិតយើងទេ។

**សៈ** ហើយនៅលើរថភ្លើងនោះ តើពួកគេមានប្រាប់លោកថាលោកត្រូវទៅដល់គោលដៅណាៗដែរឬទេ?

**ឆៈ** អត់មានទេ។ គេអត់បានប្រាប់យើងថា ទៅដល់គោលដៅទីណាគេអត់បានប្រាប់ទេ។

**សៈ** ថាតើលោកអាចរៀបរាប់ថា លោក និងគ្រួសាររបស់លោកត្រូវបានគេបង្ខំឲ្យឡើងជិះរថភ្លើង ហើយមិនដឹងថា ទៅទីណាលោកអាចរៀបរាប់អំពីព្រឹត្តិការណ៍នេះបន្តិចបានទេ?

**ឆៈ** សូមទោស សូមសួរសំណួរឡើងវិញ ខ្ញុំស្តាប់អត់បានច្បាស់។

[១២:០១:២៩]

**ស៖** បាទ ខ្ញុំសូមសួរឡើងវិញ។ សំណួររបស់ខ្ញុំគឺថា លោកបានជម្រាបជូនតុលាការថា លោកឡើងជិះរថភ្លើង គេមិនបានផ្តល់បាយទឹកឲ្យលោកទេ ហើយគេមិនបានប្រាប់ថា លោកត្រូវទៅទីណានោះទេ។ ថាតើលោក និងគ្រួសាររបស់លោកមានអារម្មណ៍យ៉ាងម៉េចដែរ? មានការភ័យខ្លាចយ៉ាងម៉េចដែរ លោកអាចរៀបរាប់បន្តិចបានទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ពេលឡើងនុំងខ្ញុំអារម្មណ៍មិនដឹងថា អារម្មណ៍ហ្នឹងមិនដឹងថាទៅកន្លែងស្លាប់ ឬមួយទៅកន្លែងណាទេ។ គ្រាន់តែថា បើបទបញ្ជាពួកឈ្លបហ្នឹង ខ្មែរក្រហមនោះ គឺគេបញ្ជាអ៊ីចឹងហើយ គឺត្រូវតែទៅ។ មិនមែនអ្វីមួយដែលយើងប្រឆាំងនឹងពាក្យគេទេ។ ទោះបីទៅកន្លែងនោះឲ្យស្លាប់ក៏យើងត្រូវតែទៅដែរ ពីព្រោះបើយើងមិនអាចប្រឆាំងគេបាន។

[១២:០២:២៩]

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថា មានអ្វីកើតឡើងនៅពេលដែលលោកទៅដល់ស្រុកមោងឫស្សីខេត្តបាត់ដំបងនោះ?

**ឆ៖** ពេលខ្ញុំទៅដល់ស្រុកមោងឫស្សី ពេលចុះពីលើរថភ្លើង នៅពេលនោះ គឺមានរទេះគោគេមកចាំៗដឹកយើងចុះទៅកន្លែងសហករណ៍ហ្នឹង។

**ស៖** តើលោកចាំឈ្មោះសហករណ៍ដែលគេបញ្ជូនលោកទៅនោះដែរឬទេ? តើគេបញ្ជូនលោកទៅសហករណ៍នោះជាមួយនឹងក្រុមគ្រួសាររបស់លោក ឬក៏អត់ទេ?

**ឆ៖** ពេលរទេះគោដឹកទៅចុះទៅសហករណ៍នោះ គឺខ្ញុំមុនដំបូងខ្ញុំមិនបានស្គាល់សហករណ៍នោះជាសហករណ៍អ្វីដែរ ហើយភូមិនោះ កន្លែងមូលដ្ឋាននោះក៏មិនដឹងមូលដ្ឋានអ្វីដែរ។ លុះដល់ ២, ៣ថ្ងៃក្រោយមកទើបមានគេ -- ឮសម្តីគេនិយាយ គេថាគេហ្នឹងជាសហករណ៍តាហឹយ ប៉ុន្តែសហករណ៍គេលេខប៉ុន្មានគេអត់ដឹងថា លេខប៉ុន្មានទេ សហករណ៍នោះ។ ខ្ញុំដឹងថា គ្រាន់តែដឹងថា សហករណ៍តាហឹយតែប៉ុណ្ណោះទេ។

[១២:០៤:០៨]

**ស៖** មុននឹងលោកទៅតាហឹយ តើលោកអាចរៀប -- និយាយពី តាហឹយនេះ គឺថាអាចនិយាយអំពីស្ថានភាពរស់នៅរបស់លោក និងគ្រួសារនៅសហករណ៍នោះបានដែរឬទេ?

**ឆ៖** ស្ថានភាពនៅសហករណ៍នោះ ពេលដែលរទេះគោដឹកប្រជាពលរដ្ឋទៅនៅទីនោះមុនដំបូងគឺមានច្រើនណាស់។ ទៅដល់នោះមានគេសង់ផ្ទះហែជាជួរៗអ៊ីចឹងទុកឲ្យប្រជាពលរដ្ឋទៅនៅ។ នៅ

ពេលនោះគ្រួសារខ្ញុំ និងបងខ្ញុំមានគេឲ្យនៅតែមួយផ្ទះទេ ហើយខ្ញុំនេះក៏មិនទាន់បានគេបំបែកចេញទៅណាដែរនៅជាមួយគ្នា។ ទៅដល់នោះ ទើបដឹងថាសហករណ៍ហ្នឹងគេនៅចកធំ នៅខាងស្រុកមោងឫស្សី ខេត្តបាត់ដំបងហ្នឹង។

**ស៖** ហើយនៅពេលដែលលោកនៅសហករណ៍នោះ ជាមួយគ្រួសាររបស់លោក តើមានប្រជាជនរស់នៅច្រើនទេនៅសហករណ៍ចកធំនោះ?

[១២:០៥:៣៥]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក អៀង សារី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន អង្គសវនាការ។ តាមដីកា E124 ហ្នឹង នៅប្រការលេខ៧ ស្ដីពីសហករណ៍ហ្នឹង មិនត្រូវបានអនុញ្ញាតឲ្យលើកយកមកសួរដេញដោលនៅក្នុងសវនាការរបស់យើងនេះទេ។ អ៊ីចឹង សូមលោក -- ខ្ញុំសូមជំទាស់នឹងការសំណួរចូលពាក់ព័ន្ធនឹងអង្គហេតុនេះ។ សូមអរគុណ។

**លោក ម៉ះដេវ ម៉ូហាន៖**

លោកប្រធាន អស់លោក លោកស្រីចៅក្រម ខ្ញុំសូមឆ្លើយតប។ គឺថា យើងបានចូលទៅដល់រចនាសម្ព័ន្ធនៃសហករណ៍ ក៏ដូចជាអ្វីដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ ដូចដែលលោក ចៅ នី ទើបតែបានរៀបជម្រាបជូនតុលាការថា គាត់ត្រូវបានគេបង្ខំឲ្យឡើងជិះរថភ្លើងទៅកាន់បាត់ដំបង ហើយនៅទីនោះគឺថា ពួកខ្មែរក្រហមបានទទួលគាត់នៅទីនោះ។ តើខ្ញុំអាចបន្តទៅទៀតបានទេលោកប្រធាន?

[១២:០៦:៥០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់មិនមានមូលដ្ឋានត្រឹមត្រូវទេ។ សេចក្ដីជំទាស់មិនមានប្រសិទ្ធភាព។

ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរនេះ។ នេះមិនមែនជាការសួរដេញដោលសហករណ៍ទេ ជាការសួរដេញដោល អំពីផលទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងដំណាក់កាលចុងក្រោយ នៃការទើបតែទៅដល់ នៃការជម្លៀសដំណាក់កាលទី២ គ្រាន់តែការទៅរស់នៅ ការចាត់ចែង ការរស់នៅរបស់

អ្នកដែលត្រូវជម្លៀសទៅដល់ទីនោះ។ ការប្រើប្រាស់សហករណ៍ទីនេះ មិនមែនការដេញដោលលម្អិតអំពីរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃសហករណ៍នោះទេ។

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណប្រធាន អស់លោក លោកស្រីចៅក្រម។

**សួរដោយលោក ម៉ះដេវ ម៉ូហាន៖**

**ស៖** លោក ចៅ នី ខ្ញុំសូមសួរសំណួរអម្បាញ់មិញនេះឡើងវិញ ដើម្បីឱ្យបានច្បាស់។ សំណួររបស់ខ្ញុំថា នៅពេលដែលលោកនៅស្រុកមោងឫស្សី ដែលលោក គ្រួសាររបស់លោក ក៏ដូចប្រជាជនដទៃទៀត នៅសហករណ៍ចកធំនោះ តើលោកអាចរៀបរាប់អំពីស្ថានភាពរបស់នៅទីនោះ អំពីចំណីអាហារ អំពីថ្នាំសង្កូវ ជូនអង្គជំនុំជម្រះបានទេ?

[១២:០៨:១០]

**លោក ចៅ នី៖**

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន ពេលទៅដល់សហករណ៍ចកធំនោះ ខ្ញុំពេលដល់ភ្លាមៗហ្នឹងគឺ ចំណីអាហារអ្វីក៏អត់បានគ្រប់គ្រាន់ដែរ។ ទៅដល់ហ្នឹងគឺបបរអឺចឹងទៅហូបសុទ្ធតែទឹកបបរ អត់មានកាកអង្ករទេ។ នៅក្នុងសហករណ៍នោះ ពេលយើងទៅនោះគេទទួលដឹងថា យើងឱ្យដែលអ្នកទៅថ្មីហ្នឹង ទឹកបបរមួយកូនចានតូចទេ ឱ្យយើងហូបទៅ។ នៅក្នុង -- សមាជិកគ្រួសារនីមួយៗគឺបានតែទឹកបបរទេ មិនបានបាយហូបទេ។ នេះការហូបចុកនោះគឺពិបាក។ រហូតដល់ទៅនៅសហករណ៍នោះប្រហែជា ៣, ៤ខែ ក្មួយៗខ្ញុំធ្លាក់ខ្លួនឈឺអស់ហើយ។ ពេលក្មួយខ្ញុំឈឺនោះ គឺអត់មានថ្នាំអ្វីព្យាបាលទេ សូម្បីតែក្មួយខ្ញុំ ចៅ សួន ឈឺរាក ពេលនោះ ពេលឪពុក ចៅ សួន នេះទៅធ្វើការបានផ្លែពោតមួយយកមកឱ្យកូនៗហូប ហើយរាកៗ សូម្បីតែរាកមកហ្នឹងចេញគ្រាប់ពោតមក ក៏ក្មួយខ្ញុំរើសទៅហូបវិញដែរ។

**ស៖** លោក ចៅ នី មុននឹងបន្តទៅ -- សួរបន្តទៅទៀត អំពីការប៉ះពាល់ទៅដល់គ្រួសាររបស់លោក និងលោក ដ៏អាក្រក់នេះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា មានប្រជាជនប៉ុន្មានដែររស់នៅសហករណ៍ចកធំ? តើមានមនុស្សច្រើនកកកុញ ឬក៏យ៉ាងណាដែរ រួមទាំងប្រជាជន១៧មេសាផងនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍ ពេលនោះ ខ្ញុំទៅមុនដំបូងនោះឃើញមនុស្សនៅច្រើនណាស់ នៅច្រើន ក៏ប៉ុន្តែស្មានប៉ុន្មាននោះ គឺថាប្រហែលជាខ្ញុំស្មានអត់បានទេ។

**ស៖** តើប្រជាជនទាំងអស់នេះ គឺសុទ្ធតែប្រជាជន១៧មេសា ឬក៏យ៉ាងណាដែរ?

**ឆ៖** បាទ នៅពេលនោះ ខ្ញុំមិនដឹងថា អ្នកទាំងអស់នោះជា១៧មេសា ទាំងអស់ ឬលាយនឹងមូលដ្ឋានដែរ ខ្ញុំក៏អត់បានដឹងទាំងអស់ទេ ពីព្រោះកន្លែងសហករណ៍នោះ គេអត់ឲ្យយើងនិយាយរកគ្នាទេ។

[១២:១១:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយ សាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបានកំណត់ គឺម៉ោងមួយនិងសាមសិបនាទីរសៀលនេះ។

បាទ សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន ខ្ញុំបានពិភាក្សាជាមួយកូនក្តីរបស់ខ្ញុំ នៅពេលឈប់សម្រាកពីព្រឹកមិញ គឺថាគាត់ទទួលការឈឺក្បាល ឈឺចង្កេះ និងបាត់បង់ការផ្តង់អារម្មណ៍នៅពេលម៉ោងដប់ ប្រហែលដប់ដប់នាទីព្រឹកមិញនេះ គឺថាគ្រូពេទ្យបានមកពិនិត្យរបស់គាត់។ ពេលនោះគឺថាគាត់កំពុងតែសម្រាន្តលក់។ វេជ្ជបណ្ឌិតបានពិនិត្យហើយ ខ្ញុំសូមដើម្បីប្រតិចារឹក គឺថាគាត់សម្រាកលក់ប្រហែលជាកន្លះម៉ោង។ ដូច្នេះគាត់មិនបានតាមដានដំណើរការនីតិវិធី ប្រកបដោយប្រសិទ្ធភាពនៅពីព្រឹកមិញនេះ។

[១២:១២:៣៣]

ដូច្នេះ យើងខ្ញុំសូមស្នើសុំដូចសព្វមួយដង។ សូមឲ្យកូនក្តីរបស់ខ្ញុំចូលទៅក្នុងបន្ទប់ឃុំឃាំងខាងក្រោម ហើយក៏ដូចជាការ -- ហើយយើងខ្ញុំក៏ស្នើសុំឲ្យវេជ្ជបណ្ឌិតពិនិត្យគាត់ នៅពេលបាយថ្ងៃត្រង់នេះផងដែរ។ បាទ នេះគឺជាសំណើសុំពីរជូនចំពោះអង្គជំនុំជម្រះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលថ្ងៃនេះ ដោយមូលហេតុលោក នួន ជា មានបញ្ហាសុខភាព មិនអាចអង្គុយតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះបាន។ ឯម្យ៉ាងទៀត គឺមានការស្នើសុំបន្ថែមឲ្យលោកវេជ្ជបណ្ឌិត ដែលទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់។

អង្គជំនុំជម្រះយល់ឃើញថា សំណើសុំរបស់លោក នួន ជា ធ្វើឡើងមានមូលហេតុសមស្រប អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដែលលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។

[១២:១៤:១០]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោម ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់។

ហើយនិងបង្គាប់ឲ្យលោកគ្រូពេទ្យ ទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅមន្ទីរឃុំឃាំង អ.វ.ត.ក ធ្វើការត្រួតពិនិត្យជនជាប់ចោទ នួន ជា នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យរាយការណ៍មកអង្គជំនុំជម្រះ តាមរយៈក្រឡាបញ្ជីឲ្យបានមុនអង្គជំនុំជម្រះដំណើរការសវនាការ បន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីនេះនៅរសៀលវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និង លោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួន

ខាងក្រោម ដោយនៅរសៀលទុកឲ្យលោក នួន ជា នៅបន្តតាមដាននៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ឡើងត្រឡប់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៥ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយសូមបញ្ជាក់ផង ថាតើត្រូវការពេលវេលាប៉ុន្មានទៀត? ហើយលៃពេលវេលាជាមួយនឹងក្រុមតំណាងសហព្រះរាជអាជ្ញាផង។

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណលោកប្រធាន យើងខ្ញុំត្រូវការពេលវេលាប្រហែលជា ៤៥នាទី។ ដូច្នេះ ខ្ញុំអាចបន្តទៅបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ បន្តបានហើយ។ ប៉ុន្តែតំណាងសហព្រះរាជអាជ្ញាយ៉ាងម៉េចទៅ ពេលវេលាមានការបែងចែកគ្នា? ពីព្រោះមួយពេលនេះទេ សម្រាប់ភាគីទាំងពីរ គឺនៅតែមួយពេលនេះទេ ដល់ម៉ោងសម្រាកចប់ហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ យើងខ្ញុំក៏ គឺថានឹងត្រូវការពេលវេលាប្រហែលជា២០ ទៅ៣០នាទីទេ លោក

ប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

រៀបចំបែងចែកឡើងវិញ យើងមិនអនុញ្ញាតទេ។ ទាំងពីរនេះ គឺត្រឹមតែពេលសម្រាកចប់ហើយ។ ពេលវេលាសម្រាប់ពីរក្រុមនេះ ត្រឹមពេលសម្រាក។ ម៉ោងទី១នេះ អស់ហើយ។

**លោក ម៉ះដេវ ម៉ូហាន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំនឹងគោរពទៅតាមសេចក្តីបង្គាប់នេះ។ ខ្ញុំនឹងសូមចាប់ផ្តើម។

**សួរដោយលោក ម៉ះដេវ ម៉ូហាន៖**

**ស៖** លោក ចៅ នី សូមអរគុណចំពោះភាពអត់ធ្មត់របស់លោក ហើយនិងការខិតខំប្រឹងប្រែងឆ្លើយអស់ពីសមត្ថភាពនៅព្រឹកមិញនេះ។ នៅពេលដែលយើងនិយាយជាចុងក្រោយ ហើយលោកជម្រាបជូនតុលាការអំពីពេលវេលារបស់លោក នៅពេលដែលលោកទៅដល់ស្រុកមោងឫស្សី ខេត្តបាត់ដំបង និងពេលវេលារបស់លោកនៅចក នៅសហករណ៍ចកធំ។ ខ្ញុំមានសំណួរមួយ ឬក៏ពីរទៀត មុននឹងយើងចាប់ផ្តើមនិយាយអំពីសហករណ៍ចកធំ ហើយពេលនោះ សឹមយើងចូលទៅនិយាយលម្អិតអំពីពេលវេលាក៏ដូចជាបទពិសោធន៍របស់លោកនៅសហករណ៍ចកធំនោះ។

[១៣:៣៨:១៩]

នៅក្នុងចម្លើយរបស់លោកពីលើកមុន លោកបានជម្រាបជូនអង្គជំនុំជម្រះថា នៅពេលដែលលោកឡើងជិះរថភ្លើង បន្ទាប់ពីលោកចាកចេញពីត្រពាំងសាប ខេត្តតាកែវ ហើយលោកបានធ្វើដំណើរតាមបណ្តោយផ្លូវរថភ្លើង ហើយឈ្លបបានបង្ខំឲ្យលោកឡើងជិះរថភ្លើង។ លោកបានជម្រាបជូនតុលាការថា ជាពេលវេលាដ៏លំបាកលំបិនសម្រាប់លោក និងគ្រួសាររបស់លោក។ ពីព្រោះថា លោកមិនដឹងថាលោកត្រូវទៅទីណា លោកមិនដឹងថា គោលដៅលោកត្រូវទៅទីណានោះទេ។ តើអ៊ីចឹងមែនទេ?

**លោក ចៅ នី៖**

**ឆ៖** សូមជម្រាប នៅពេលនោះ គឺខ្ញុំអត់មានគោលដៅដែលខ្ញុំបំណងទេ គឺតែលតោលអត់មានគោលដៅទេ។

**ស៖** សូមអរគុណ។ តើលោកអាចរំឭកជូនតុលាការបានឬទេ នៅពេលវេលារបស់លោកដោយសារពីមុននេះ គឺលោកបានថា នៅក្នុងការជម្លៀសនៅដំណាក់កាលទី២នោះ លោកបាននិយាយ

អំពីការជម្លៀសនូវដំណាក់កាលទី២។ តើលោកជម្រាបជូនតុលាការបានទេ នៅពេលដែលកងឈ្លបខ្មែរក្រហមបង្ខំឱ្យលោកឡើងជិះរថភ្លើងនោះ គឺថាវាអាចនៅចុងឆ្នាំ៧៥ ឬក៏ដើមឆ្នាំ១៩៧៦។ តើធ្វើម៉េចបានជាលោកចាំថា លោកត្រូវបានគេបង្ខំឱ្យឡើងជិះរថភ្លើងនៅក្នុងអំឡុងពេល ប្រហែលជាអំឡុងពេលនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍នៅពេលនោះ ខ្ញុំក៏មិន គ្រាន់តែសន្និដ្ឋានថា ប្រហែលជាចុងឆ្នាំ៧៥ ឬដើមឆ្នាំ៧៦តែប៉ុណ្ណោះទេ។

[១៣:៤០:២៥]

**ស៖** សូមអរគុណ។ លោក ចៅ នី ឥឡូវនេះ ខ្ញុំសូមចូលទៅការរំឭកឡើងវិញឆាប់ទេ គឺគ្រាន់តែរំឭកតែសង្ខេបទេ។ នៅពេលដែលលោកទៅដល់ខេត្តបាត់ដំបង ដូចដែលលោកបានជម្រាបពីខាងដើមរួចមកហើយ ដោយសារស្ថានភាពរស់នៅទីនោះ ដោយសារតែលោកត្រូវបានឈ្លបខ្មែរក្រហមឱ្យជិះរថភ្លើង ហើយពួកគេមិនបានប្រាប់លោកថា ត្រូវទៅទីណានោះទេ។ លោកយល់ឃើញថា ពេលនោះប្រហែលជាទិសដៅរបស់លោក ជោគវាសនារបស់លោកគឺសេចក្តីស្លាប់នោះឯង។ ហើយពេលលោកទៅដល់បាត់ដំបង លោកក៏បានប្រាប់ផងដែរថា គេបានយករទេះគោយកមកដឹកលោកទៅកាន់សហករណ៍។ លោកអាចជម្រាប់ជូនអង្គជំនុំជម្រះបានទេថា អ្នកណាដែលយករទេះគោមកទទួលលោកទៅសហករណ៍ហ្នឹង ដែលទៅដល់ខេត្តបាត់ដំបងហ្នឹង?

**ឆ៖** បាទ សូមជម្រាប ពេលដែលអ្នកបើកបររទេះគោនោះ ខ្ញុំមិនដឹងថាជាឈ្លប ឬមួយជាប្រជាពលរដ្ឋធម្មតាក៏ខ្ញុំអត់បានដឹងដែរ ពីព្រោះសម្លៀកបំពាក់អ្នកទាំងនោះ ហើយនិងយើងធ្លាប់ឃើញសម្លៀកបំពាក់របស់ទាហានខ្មែរក្រហមនោះប្រហាក់ប្រហែលគ្នាទេ។ មានខោអាវខ្មៅ និងមានកន្សែងវ័ណ្ណក ដូចគ្នា។

**ស៖** សូមអរគុណ។ នៅពេលដែលលោកជួបអ្នកទាំងនេះ តើពួកគេបានប្រាប់មកលោកគ្រួសាររបស់លោក និងប្រជាជនដទៃទៀតថាម៉េចដែរ នៅពេលដែលលោកចុះពីលើរថភ្លើងទៅនោះ?

**ឆ៖** នៅពេលនោះគេឱ្យ -- អត់និយាយអីទាំងអស់ គេជំរុញឱ្យយើងឡើងរទេះគោ។

**ស៖** ហើយនៅពេលដែលលោកបានទៅដល់សហករណ៍ចកធំ តើកងឈ្លបទាំងនោះបានប្រាប់លោកថាម៉េចដែរ?

[១៣:៤២:៤៨]

**ឆ៖** ពេលទៅដល់ចកធំ កងឈ្លបទាំងនោះប្រើពាក្យអសុរោះ ដើម្បីតែមកលើប្រជាពលរដ្ឋថ្មី គេហៅថា "ពាក្យពួក១៧" ដូចជា ពាក្យប្រើថា "ពួកនាយទុន ពួកសក្តិភូមិ ពួកមូលធននិយម ធ្វើស្រែលើខ្នងរាស្ត្រ"។ ហេតុដូច្នេះហើយគឺ ដល់ពេលនោះហើយ គេដាក់យើងទៅនៅតាមផ្ទះរៀងៗខ្លួន។ ផ្ទះដែលទៅដល់នោះ ផ្ទះគេមានសង់ហើយស្រេច។

**ស៖** នៅពេលដែលលោកជួបកងឈ្លបជាលោកដំបូងនៅសហករណ៍ចកធំ តើលោកមានបានបង្ហាញអត្តសញ្ញាណ បង្ហាញប្រាប់គេថាលោកគឺជាខ្មែរក្រោមដែរទេ?

**ឆ៖** ពីព្រោះនៅពេលនោះ ខ្ញុំអត់ប៉ានថាខ្ញុំជាខ្មែរក្រោមទេ ពីព្រោះខ្ញុំលាក់ប្រវត្តិរូបខ្ញុំតាំងពីគេខ្សឹបប្រាប់ខ្ញុំនៅខេត្តតាកែវម្ល៉េះ។

[១៣:៤៤:២១]

**ស៖** សូមអរគុណ។ ដូច្នេះ លោកបន្តលាក់អត្តសញ្ញាណរបស់លោក ហើយលោកក៏បានផ្លាស់ប្តូរត្រកូលរបស់លោកពី ចៅ ទៅ លន់។ តើកងឈ្លបនៅសហករណ៍ចកធំ បើសិនណាជាគេដឹងថាលោកជាខ្មែរក្រោមនោះ តើគេអាចនឹងសម្លាប់លោកដែរឬយ៉ាងណា?

**ឆ៖** នៅពេលនោះ ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមជំទាស់នឹងសំណួរនេះ ដោយសារវាជាសំណួរឧបមានវិធី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ត្រឹមត្រូវ មានមូលហេតុសមស្រប។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះទេ។

[១៣:៤៥:២៦]

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងរៀបចំសំណួរនេះជាថ្មីឡើងវិញ។

**សួរដោយលោក ម៉ះដេវ ម៉ូហាន៖**

**ស៖** លោក ចៅ នី លោកបានបញ្ជាក់ជូនអង្គជំនុំជម្រះថា លោកមិនបានប្រាប់គេថាលោកជាខ្មែរក្រោមទេ ដោយសារថា វាអាចនឹងមានរឿងមិនល្អកើតឡើងទៅចំពោះប្រជាជនថ្មីនៅចកធំនោះ។ តើលោកអាចជម្រាបជូនថាតើខ្មែរក្រហមហ្នឹង គេបាននិយាយមកប្រាប់លោក គ្រួសារលោក ក៏ដូចជាប្រជាជនទាំងអស់ទៀតថាម៉េចដែរ នៅចកធំនុ៎ង?

**លោក ចៅ នី៖**

**ឆ៖** សូមជម្រាបថា ពេលដែលខ្ញុំទៅនៅសហករណ៍ចកធំនោះ គឺគេអត់រំឭកឡើងនិយាយពីអំពីទៀតទេ។ គ្រាន់តែដឹងថា បើយើងទៅដល់នោះគឺគិតពីបង្កបង្កើនផល លើកកម្លាំងដើម្បីធ្វើឱ្យបង្កបង្កើនផល ១ឆ្នាំធ្វើឱ្យបានពីរដងឬបីដង។ ក្នុងមួយហិកតាឱ្យបានបីតោន។ ហេតុដូច្នេះហើយប្រជាពលរដ្ឋទាំងអស់ត្រូវតែប្រឹងធ្វើបង្កបង្កើនផលនោះជារៀងរាល់ថ្ងៃ។ បង្ខំធ្វើការជាទម្ងន់ ដោយគ្នាសឹងតែគ្មានពេលសម្រាក។

[១៣:៤៥:៥២]

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ ថាតើលោកទទួលរបបអាហារហ្នឹងបានប៉ុនណាដែរក្នុង១ថ្ងៃ នៅពេលដែលលោកនៅសហករណ៍ចកធំនោះ?

**ឆ៖** នៅក្នុងសហករណ៍ហ្នឹងយើងមិនមែនបាននិយាយអំពីអាហារ១ថ្ងៃទេ បើនិយាយក្នុងមួយពេលបានតែមួយជងទឹកបបរ ចានតូចទឹកបបរទេ។

**ស៖** តើរបបអាហារហ្នឹងគ្រប់គ្រាន់សម្រាប់លោក គ្រួសារលោក រួមបញ្ចូលទាំងកូនរបស់លោកបីនាក់ផង គ្រប់គ្រាន់ទេ? ក្មេងៗនៅក្នុងបន្ទុករបស់លោកបីនាក់ផង តើគ្រប់គ្រាន់ទេ?

**ឆ៖** បាទ នៅពេលនោះអាហារនេះគឺអត់គ្រប់គ្រាន់ទេ។ បើធៀបនឹងកម្លាំងធ្វើការ ហើយបើប្រៀបធៀបមកអាហារដែលយើងហូបចុក វាអត់តុល្យភាពគ្នាទេ។ កម្លាំងធ្វើការច្រើនខ្លាំង -- ច្រើនជាងអាហារដែលគេផ្គត់ផ្គង់ឱ្យយើងហូប។

[១៣:៤៨:២០]

**ស៖** សូមអរគុណលោក ចៅ នី គឺថាវាមានប៉ះពាល់ទៅដល់កម្លាំងពលកម្ម លោកថាដូច្នេះ។ តើការខ្វះម្ហូបអាហារហ្នឹងវាប៉ះពាល់ទៅដល់ក្មេងៗនៅក្នុងគ្រួសាររបស់លោក ចៅ សួន, ចៅ យក្ស និង ចៅ ឡាប៉ាំង នោះយ៉ាងម៉េចដែរ?

**ឆ៖** មកពីខ្វះអាហារមិនគ្រប់គ្រាន់ ទើបធ្វើឲ្យក្មួយខ្ញុំទាំងបីទៅដល់នោះ ព្រមទាំងបងប្រុសខ្ញុំម្នាក់ទៀត គាត់ឈឺស្លាប់នៅទីនោះដោយសារខ្វះអាហារ។ ក្មួយខ្ញុំមុននឹងស្លាប់ វេទនាណាស់។ សូម្បីតែគ្រាន់ពោតអាចម៍មកហើយហ្នឹង ក៏គ្មាយកទៅហូបរិញដែរ យើងត្រូវគិតទៅ។ ហើយបើបងប្រុសខ្ញុំមុននឹងស្លាប់ សូមស្ករត្នោតតែមួយចុងស្លាបព្រាទេ ដើម្បីហូប។ ឲ្យតែបានស្ករត្នោតបន្តិច គាត់ដាច់ខ្យល់ស្លាប់ក៏ដាច់ចុះ ប៉ុន្តែដល់ពេលទៅរកមិនបាន គាត់អត់បានហូបទេ។ បងថ្លៃស្រីខំទៅរកឲ្យបាន បានមួយចុងស្លាបព្រា យកមកអត់បានហូប មកដល់ប្ដីដាច់ខ្យល់ស្លាប់បាត់ទៅ។

**ស៖** សូមអធ្យាស្រ័យលោក ចៅ នី ដែលខ្ញុំដាក់ -- ធ្វើឲ្យលោកមានអារម្មណ៍រន្ធត់បែបនេះ។ ខ្ញុំសូមបញ្ជាក់ចំណុចចុងក្រោយថា លោកបានលើកឡើងថា ក្មេងៗក្មួយរបស់លោកបងប្រុសរបស់លោកមានជំងឺជាទម្ងន់ ហើយក៏បានស្លាប់ទៅ។ តើកងឈ្លបខ្មែរក្រហមហ្នឹង មានបានផ្ដល់ថ្នាំពេទ្យអីដល់ពួកគាត់ និងពួកក្មេងៗទាំងនោះទេ?

**ឆ៖** ពេលក្មេងៗឈឺ គាត់គ្មានថ្នាំអីព្យាបាលក្រៅពីថ្នាំអាចម៍ទន្សាយនោះទេ។ អារាកក៏អាចម៍ទន្សាយ អាក្ដៅខ្លាំងក៏អាចម៍ទន្សាយ អាឈឺអ្វីមួយក៏អាចម៍ទន្សាយដែរ។ ក៏ប៉ុន្តែមិនដឹងថ្នាំនោះ លោកខ្មែរក្រហមនោះគាត់ផ្សំមកពីជាតិអីទេ បានព្យាបាលគ្រប់ៗបែបគ្រប់យ៉ាងជំងឺ។

[១៣:៥០:៥០]

**ស៖** តាមដែលលោកដឹងនោះ ថាតើមានប្រជាជនអ្នក -- ថ្នាំអាចម៍ទន្សាយហ្នឹង ដែលផ្ដល់ទៅហ្នឹង តើវាជួយឲ្យសុខភាពប្រជាជនណាមួយ បានធូរស្រាល បានធូរស្បើយដែរទេ តាមដែលលោកដឹងនោះ?

**ឆ៖** បើតាមខ្ញុំដែលឃើញ ក្មួយខ្ញុំលេបហ្នឹងកំពុងតែរាកអ៊ីចឹង លេបហើយប្រហែលជា៣ម៉ោងក្រោយដាច់ខ្យល់។

**ស៖** សូមអរគុណលោក ចៅ នី។ ពីខាងដើម លោកបានជម្រាបជូនតុលាការថា នៅសហករណ៍ចកធំនោះ គឺដឹកនាំដោយឈ្មោះ តាហ៊ុយ គឺគេហៅប្រធានសហករណ៍នោះ ឈ្មោះថា តាហ៊ុយ។ តើលោកអាចរៀបរាប់ ថាតើគាត់បាននិយាយមកកាន់លោក គ្រួសារលោក ឬប្រជាជននៅសហករណ៍ហ្នឹងថាយ៉ាងម៉េចដែរ?

[១៣:៥១:៥៤]

**ឆ៖** ពីព្រោះភាសាគេ និយាយមកពួក១៧នេះគឺអត់ អត់មានពាក្យអ្វីដែលលួងលោមយើងថា

ដើម្បីអីទេ។ មានតែការបុកម្ទេញ ធ្វើម៉េចឲ្យយើងឈឺចាប់តែប៉ុណ្ណោះ។ គ្មានអ្វីក្រៅពីពួកអានាយទុន ហ្នឹងទេ។

**ស៖** សូមអរគុណលោក ចៅ នី។ យោងទៅលើចម្លើយរបស់លោក D22/253, ERN អង់គ្លេស004--

**អ្នកបកប្រែ៖**

លោកប្រធានសូមអធ្យាស្រ័យ គាត់ លោកមេធាវីអានញាប់ពេក។ អ្នកបកប្រែមិនអាចតាមទាន់។

[១៣:៥២:៣៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអានឡើងវិញលេខឯកសារ លេខ ERN ហើយឲ្យយឺត ដើម្បីបង្កលទ្ធភាពឲ្យអ្នកបកប្រែភាសាអាចបកប្រែទាន់។

**លោក ម៉ះដេវ ម៉ូហាន៖**

បាទ ខ្ញុំនឹងអនុវត្តតាមលោកប្រធាន។

**សួរដោយលោក ម៉ះដេវ ម៉ូហាន៖**

**ស៖** នេះគឺជាចម្លើយរបស់ជនរងគ្រោះ D22/253, ERN ជាភាសាអង់គ្លេស 00478480, ERN ខ្មែរ 00421599 ហើយ ERN ជាភាសាបារាំង 00858937។ លោក ចៅ នី នៅក្នុងចម្លើយរបស់លោកនេះ លោកបាននិយាយថា "សហករណ៍ដែលទើបតែជម្រាបជូនតុលាការនេះ គឺដឹក -- គ្រប់គ្រងដោយឈ្មោះ តាហ៊ុយ។ តាហ៊ុយ គេហៅថា ឃាតករមុខញញឹម ឈាមត្រជាក់"។ ហេតុអីបានជាគាត់មានឈ្មោះតាហឹយ ហ្នឹង គេហៅគាត់ ម៉េចបានគេហៅរហស្សនាមគាត់ថាអ៊ីចឹង?

[១៣:៥៤:២២]

**លោក ចៅ នី៖**

**ឆ៖** នៅពេលនោះ ខ្ញុំក៏មិនដឹងគេដាក់រហស្សនាមតាហ្នឹងយ៉ាងណាដែរ។ គ្រាន់តែឮគេហៅ ហើយតានេះបើឃាតករសម្លាប់មនុស្សដោយញញឹម ដោយគ្មានញញើតដៃ ឈ្មោះគាត់ហ្នឹង តាហឹយ មិនមែន តាហ៊ុយ ទេ។

**ស៖** តើលោកអាចរៀបរាប់អំពីស្ថានភាពរស់នៅក្រោមការគ្រប់គ្រងរបស់ តាហ៊ុយ នៅពេលនោះបានទេ? -- របស់ តាហឹយ នៅពេលនោះបានទេ? តើលោកធ្លាប់បានឃើញផ្ទាល់ ឬក៏ធ្លាប់ឮថាគាត់

មានការកាប់សម្លាប់ប្រជាជនដែរឬទេនៅក្រោមការគ្រប់គ្រងរបស់គាត់នោះ ឬក៏មានមនុស្សបាត់ខ្លួន នៅក្រោមការគ្រប់គ្រងរបស់គាត់នោះដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាប ពេលខ្ញុំទៅនៅទីនោះមិនដែលឃើញគាត់សម្លាប់ផ្ទាល់ភ្នែកខ្ញុំទេ។ ក៏ប៉ុន្តែ របស្សនាមរបស់គាត់នេះ ប្រហែលជាជាប់ពីណាមកក៏មិនដឹងទេ នេះឮតៗគ្នាទេ។ ក៏ប៉ុន្តែប្រជាពលរដ្ឋ នៅក្នុងសហករណ៍នោះកាន់តែយូរ កាន់តែតិច តិចទៅៗ ក៏ប៉ុន្តែមិនដឹងថាស្លាប់ដោយអាហារ ហើយឬ គេជម្លៀសគាត់ទៅណាទៀត ក៏ខ្ញុំមិនបានដឹងដែរ។

[១៣:៥៥:៥៩]

**ស៖** សូមអរគុណលោក ចៅ នី។ នៅពេលដែលប្រជាជនចេះតែនៅតិចទៅៗ នៅសហករណ៍ ចកធំនោះ តាមដែលលោកដឹងនោះ តើទឹក ចំណីអាហារសម្រាប់ឲ្យប្រជាជននោះ ក្រៅពីគ្រួសាររបស់ លោកហ្នឹង តើប្រជាជនបានទទួលទឹកបានគ្រប់គ្រាន់ ឬទទួលថ្នាំពេទ្យគ្រប់គ្រាន់គ្រាន់បើជាងគ្រួសារ លោក ឬក៏ដូចតែគ្រួសារលោកដែរ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ សំណួរនេះប្រហាក់ប្រហែលជា-- ទឹកធម្មតា យើងមិនដែល មានទឹកសុទ្ធហូបដូចបច្ចុប្បន្ននេះទេ គឺទឹកត្រពាំង យើងទៅហូប យើងទៅត្រង់ណា ជួបទឹកត្រង់ណា ហូបត្រង់ហ្នឹងទេ។ បើយើងយកមកផ្ទះ ត្រូវយួរមួយកូនឆ្នាំងអីយកមកផ្ទះ សម្រាប់កូនចៅគាត់ហូប ទៅ។ ថ្នាំពេទ្យ ធម្មតាថ្នាំពេទ្យអត់មានថ្នាំព្យាបាលទេ។ ពេលឈឺគ្មានថ្នាំអ្វីមកព្យាបាលទេ ខុសពីថ្នាំ អាចម៍ទន្សាយទេ។ ពេលបងខ្ញុំឈឺ គាត់សុខចិត្តឈឺនៅនឹងផ្ទះ មិនទៅដេកពេទ្យទេ។ បើអ្នកណាទៅ ដេកពេទ្យគេនោះ គឺអត់អាហារហើយ។ របបដែលយើងមាននៅក្នុងពេលដែលយើងនៅផ្ទះហ្នឹង ដែល ពេលយើងទៅធ្វើការ តែយើងទៅដេកពេទ្យ គឺអត់មានរបបទៀតទេ។

[១៣:៥៧:៤០]

**ស៖** បាទ ដើម្បីបញ្ជាក់ឡើងវិញនូវអ្វីដែលលោកទើបបានជម្រាបជូននេះ ទឹកក៏ដូចជាអាហារ គឺថាដែលលោកបានទទួល ក៏ដូចជាប្រជាជន គឺថាតិចជាងពេលធម្មតាអីចឹងមែនទេ បានតិចជាងពេល ធម្មតា?

**ឆ៖** ទឹកមិនមែនបានតិចជាងធម្មតាទេ។ តែធម្មតាទឹកត្រពាំងយើងទៅហូប ត្រង់ណាក៏បាន ដែរ ឲ្យតែយើងស្រេក ក៏ប៉ុន្តែវាមិនបានទឹកស្អាតទេ។ ទឹកត្រពាំង ទឹកអីហ្នឹង យើងចេះតែហូបទៅ។ ពេលយើងស្រេក យើងធ្វើការហត់ ស្រេកចេះតែហូបទៅ ក៏ប៉ុន្តែបើថ្នាំពេទ្យ គឺអត់មានទេ ហើយបើ

អ្នកឈើទៅដេកពេទ្យ គឺដាច់របបអាហារហើយ។

**ស៖** លោកអាចជម្រាបជូនត្រួសៗបាន តើមានប្រជាជនប៉ុន្មាននាក់ដែរ -- ប្រហែលប៉ុន្មាននាក់ដែររស់នៅសហករណ៍ចកធំនោះ ក្រៅពីបន្ថែមទៅលើក្រុមគ្រួសាររបស់លោកនោះ មានប្រជាជនប្រហែលជាប៉ុន្មានដែរនៅចកធំនោះ?

[១៣:៥៩:០០]

**ឆ៖** ដូចខ្ញុំនិយាយប្រាប់ពីមុនមក ថាពេលមុនដំបូងដែលយើងចុះទៅនៅចកធំមុនដំបូង ជិះរទេះគោទៅហ្នឹង គឺឃើញមនុស្សច្រើន ស្មានមិនបានទេមនុស្ស ប្រហែលជាខ្ទង់រយ ខ្ទង់ពាន់អីដែរ។ ជាច្រើនគ្រួសារ ផ្ទះវាមានពីរបីជួរ អ៊ីចឹងខ្ញុំស្មានមនុស្សនោះអត់ដឹងថា ប្រហែលជាប៉ុន្មានទេ។ ក៏ប៉ុន្តែដល់មកចុងក្រោយកាន់តែខើចទៅៗ ឃើញតែផ្ទះចោលទេ អត់ដឹងថាមនុស្សហ្នឹងទៅណាទេ។ ប៉ុន្តែផ្ទះអត់មានមនុស្សនៅទេ។

**ស៖** សូមអរគុណ។ លោកបានជម្រាបថា គឺថាផ្ទះនៅដដែល ប៉ុន្តែប្រជាជននៅសហករណ៍នោះគឺថាចេះតែតិចទៅៗ។ លោក ចៅ នី បើសិនណាលោកអាចជម្រាបជូនតុលាការបាន គឺថាពីខាងដើម លោកនិយាយថា “ទាំងតាហ៊ីយ ក៏ដូចជាកងឈ្លបខ្មែរក្រហមបាននិយាយទៅកាន់ប្រជាជនរស់នៅសហករណ៍ចកធំ ថាអ្នកឯងត្រូវផ្លាស់ប្តូររបៀបមូលធននាយទុន”។ តើពួកគេមានន័យម៉េច ហេតុម៉េចក៏ប្រាប់ប្រជាជនឲ្យកែប្រែរបៀបនេះ?

**ឆ៖** ភាសាខ្មែរក្រហម គេប្រើប្រាស់តើធនហ្នឹង ឲ្យតែយើងពួក១៧ ប្រហែលជាដូចគ្នាទេ។ នៅពេលនោះ យើងមិនអាចសន្និដ្ឋានថា គេហ្នឹងចង់ឲ្យយើងធ្វើយ៉ាងណានោះទេ។

[១៤:០០:៥៨]

**ស៖** តើគេធ្លាប់ពន្យល់លោកដែរឬទេ ពីមូលហេតុថា មិនឲ្យលោកធ្វើអ្វីដែលលោកបានចង់ធ្វើនោះ ចំពោះប្រជាជន១៧មេសា ហើយហេតុអីបានជាបង្ខំឲ្យប្រជាជន រួមទាំងលោករស់នៅក្នុងសហ-ករណ៍នោះ?

**ឆ៖** ពីព្រោះនៅសហករណ៍ នៅទីណា នៅក្នុងរបប ប៉ុល ពត គ្រប់គ្រងនោះ គឺកន្លែងណាគឺនៅតាមសហករណ៍ទាំងអស់។ បើយើងគេចវេះទៅណា ក៏អត់បានដែរ។ គឺគោលការណ៍របស់បក្សមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ គឺនៅក្នុងប្រទេសកម្ពុជាទីណា ដូចទីណាដែរ ត្រូវតែនៅក្នុងសហករណ៍ យើងជៀសវាងមិនបានទេ។ ប្រជាពលរដ្ឋណា ដែលប៊ានប្រឆាំងនឹងបក្សកុម្មុយនីស្ត

កម្ពុជាប្រជាធិបតេយ្យ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរំឭកម្ដងទៀត វិសាលភាពនៃការដេញដោល មិនឲ្យហួសផុតឆ្ងាយអំពីរយៈពេលវេលានៃការជម្លៀស ហើយទៅគោលដៅនៃការជម្លៀសទី១ និងទី២ ហ្នឹងទេ។ ពេលវេលាដែលថាអាចសួរដេញដោលហ្នឹង ជុំវិញនៃការវិវត្តនការប្រែប្រួលនូវទីកន្លែងស្នាក់ ឬក៏ការទទួលសម្របសម្រួលនៅទីកន្លែងនោះ គឺកម្រិតត្រឹមយ៉ាងយូរ ៣ខែអីប៉ុណ្ណោះ។ អ៊ីចឹងលោកអាចច្រឡំ។ បាទ បញ្ហាទី២ យើងបញ្ជាក់ឡើងវិញ សហករណ៍ ការចាត់តាំង និងការប្រព្រឹត្តទៅនៃសហករណ៍ មិនមែនជាអង្គហេតុដែលអង្គជំនុំជម្រះកំណត់មកធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១ទេ។

[១៤:០២:៤៤]

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគោរពតាមការរំឭកនេះ ហើយខ្ញុំនឹងសួរសំណួរក្នុងវិសាលភាពនៃដំណាក់កាលនៃការជម្លៀស ដូចលោកប្រធានមានប្រសាសន៍អម្បាញ់មិញនេះ។

**លោក ម៉ះដេវ ម៉ូហាន៖**

**ស៖** លោក ថៅ នី ខ្ញុំមានតែសំណួរពីរបីទៀតទេ ពីព្រោះថា លោកឆ្លើយដ៏មានសារៈសំខាន់ដល់តុលាការ។ កាលពីខាងដើមលោកបាននិយាយថា ភាគច្រើននៃប្រជាជនដែលនៅសហករណ៍ចកធំនោះ គេដឹកតាមរថភ្លើងជាមួយប្រជាជនថ្មីទៀត។ ហើយលោកនិយាយថា គឺមានការរើសអើងប្រឆាំងប្រជាជនថ្មី។ សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងចំណុចនេះ ហើយលោកក៏បាននិយាយថា លោកមិនដឹង មិនលាតត្រដាងអត្តសញ្ញាណរបស់លោកថាជាខ្មែរក្រោមទេ ទាំងនៅត្រពាំងសាប តាកែវផងដែរ"។ សួរថាតើមានអ្នកផ្សេងទៀតដែរឬទេ នៅចកធំនោះ ដែលគេអះអាង ដែលគេប្រាប់ខ្មែរក្រហមថា គេជាខ្មែរក្រោម តើពួកគេបាន អ្នកណាម្នាក់បានប្រាប់ពីអត្តសញ្ញាណរបស់គេថា ជាខ្មែរក្រោមដែរឬទេ?

[១៤:០៤:០០]

**ឆ៖** សូមជម្រាបមេធាវី នៅពេលនោះ គ្មានអ្នកណាហ៊ានបង្ហើបថា ជាខ្មែរក្រោមទេ។

**ស៖** នៅក្នុងពេលដែលគេជម្លៀសលោក នៅពេលដែលគេបង្គាប់ឲ្យលោកជិះរថភ្លើង ដែលបញ្ជូនទៅបាត់ដំបងទៅស្រុកមោងឫស្សី តើពេលណាមួយលោកមានឱកាស ឬក៏អ្នកផ្សេងទៀតមាន

ឱកាសទេ ក្នុងក្រុមគ្រួសាររបស់លោក ដែលថាមិនធ្វើតាមការបញ្ជារបស់គេនោះ? ឬក៏លោកធ្លាប់បានព្យាយាមគេចខ្លួន ឬក៏មិនគោរពបញ្ជាដែរទេ?

**ឆ៖** នៅពេលនោះ ខ្ញុំមិនប៊ានប្រឆាំងបទបញ្ជាគេទេ។ អ្វីមួយឲ្យតែគេបញ្ជា ធ្វើអ្វី គឺធ្វើតាមបទបញ្ជារបស់មាគ៌ាបក្សគេទាំងអស់។

[១៤:០៥:១៣]

**ស៖** ថាតើនេះដូចគ្នានឹងអ្វីដែលលោកបានឃើញ ឬក៏លោកបានកត់សម្គាល់ចំពោះប្រជាជននៅក្នុង -- ប្រជាជននៅសហករណ៍ចកធំ ឬក៏អ្នកផ្សេងទៀត តើលោកបានសង្កេតឃើញអ្នកណាម្នាក់បានដើរចេញពីសហករណ៍ ឬក៏ធ្វើដំណើរចាកចេញពីកន្លែងណាមួយដោយមិនគោរពបញ្ជាដែរឬទេ?

**ឆ៖** ខ្ញុំអត់បានឃើញទេ។

**ស៖** សូមអរគុណ។ លោក ថៅ នី លោកនឹងមានឱកាសមួយដែលតុលាការនឹងផ្តល់ឲ្យលោកនិយាយអំពីការឈឺចាប់របស់លោក ប៉ុន្តែខ្ញុំមិនសួរលម្អិតអំពីបញ្ហានេះនោះនៅពេលនេះនោះទេ។ ប៉ុន្តែបើសិនជាលោកចង់ប្រាប់ខ្ញុំអំពីពេលវេលាដែលលោកនៅចកធំនៅឆ្នាំ១៩៧៦ និង១៩៧៧ ដែលយើងខ្ញុំចង់ដឹងដែលទាក់ទងទៅនឹងរូបលោក ហើយនិងក្រុមគ្រួសាររបស់លោក ថាតើស្ថានភាព ហើយនិងជីវភាពទីនោះវាដូចម្តេច?

**ឆ៖** ស្ថានភាព និងជីវភាពនៅកោះធំនុំងភាគច្រើនអត់អាហារដាច់ពោះបាយស្លាប់។

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណ។

លោកប្រធាន លោក លោកស្រីចៅក្រម ដោយសារពេលវេលាមានកម្រិតហើយដើម្បីឲ្យមានប្រសិទ្ធភាព។ ខ្ញុំសូមអនុញ្ញាតបញ្ចប់ការតាំងសំណួររបស់ខ្ញុំត្រឹមប៉ុណ្ណេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៤:០៧:៣២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម មេធាវី ហើយសូមជម្រាបសួរលោក ថៅ

នី ខ្ញុំឈ្មោះ ថារីក អាប់ឌុលឡាក់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំនឹងសួរសំណួរលោកមួយចំនួនតូច ក្នុងនាមខ្ញុំ ហើយនិងសហសេវិករបស់ខ្ញុំផងដែរ។ សំណួររបស់ខ្ញុំទាក់ទងទៅនឹងពីការចាកចេញរបស់លោកពីភ្នំពេញជាដំបូង ហើយបន្ទាប់ទៅទៀត ខ្ញុំនឹងសួរសំណួរមួយចំនួនទាក់ទងអំពីការជម្លៀសលោកជាបន្តទៅបាត់ដំបង ហើយខ្ញុំសួរដំបូងគឺទាក់ទងទៅនឹងថ្ងៃទី១៧ ខែមេសា នោះ ឆ្នាំ១៩៧៥ បាទ។ សូមឱ្យលោកជួយបំភ្លឺខ្ញុំ និងតុលាការចំណុចទី១ មុនគេ លោកបានឆ្លើយទៅមេធាវីថា "នៅថ្ងៃទី១៧ ខែមេសា ខ្មែរក្រហមចូលមកដល់ ហើយក្រោយមកគេប្រកាសថា ឱ្យប្រជាជនចេញពីទីក្រុង" ថាតើពេលណាដែលមុនគេបំផុតលោកបានឮការប្រកាសរបស់ខ្មែរក្រហមថា ឱ្យចាកចេញពីទីក្រុង? តើលោកឮក្នុងថ្ងៃ១៧មេសា ឬក៏ក្រោយពីថ្ងៃហ្នឹងដែលថា គេប្រកាសឱ្យចាកចេញពីទីក្រុងនោះ?

[១៤:០៨:៥២]

**លោក ចៅ នី៖**

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញា ខ្ញុំឮក្រោយពីថ្ងៃ១៧មេសា។ មិនមែននៅក្នុងថ្ងៃ១៧មេសាទេ។

**ស៖** នៅពេលដែលលោកបានឃើញទាហានដែលគេមកដល់ជិតផ្ទះរបស់លោក ហើយបញ្ជាឱ្យលោក និងក្រុមគ្រួសាររបស់លោកចាកចេញនោះ តើថ្ងៃ -- បន្ទាប់ពីថ្ងៃ១៧មេសាភ្លាមៗ ឬក៏នៅប៉ុន្មានថ្ងៃក្រោយពីថ្ងៃ១៧មេសា នោះ តើលោកនៅចាំទេ តើប៉ុន្មានថ្ងៃ?

**ឆ៖** ប្រហែលជា២ថ្ងៃ ឬ៣ថ្ងៃក្រោយមក។

**ស៖** សូមអរគុណ។ នៅពេលដែលគេប្រាប់ឱ្យលោកចាកចេញ សូមលោករៀបរាប់ថា តើហេតុការណ៍ដែលកើតមានឡើងជុំវិញអ្នកនៅជុំវិញលោកនោះ ដែលថានៅក្រោយផ្សារអូឡាំពិកនោះ តើអ្នកជិតខាងរស់នៅទីនោះ តើគេជួបស្ថានភាពដូចម្ដេចដែរ?

**ឆ៖** ពេលកងទ័ពខ្មែរក្រហមគេប្រកាសឱ្យចាកចេញពីទីក្រុងភ្នំពេញ គឺប្រជាពលរដ្ឋគាត់ផ្អើលឈូឆរ។ ឈូឆរទាំងគេទាំងខ្ញុំ ដើម្បីរកច្រកចេញពីទីក្រុងដូចគ្នា មិនមែនតែគ្រួសារខ្ញុំទេ ប្រជាពលរដ្ឋដទៃក៏ដូចខ្ញុំអ៊ីចឹងដែរ។ ហើយនៅពេលនោះពួក -- បើយើងនៅយឺតយ៉ាវក៏គេបង្ខំឱ្យយើងចេញដែរ។

[១៤:១០:៥០]

**ស៖** លោកអាចបានឆ្លើយរួចហើយសំណួរនេះ អំពីភាពមិនប្រាកដនេះ ផ្អែកលើអ្វីដែលលោកបានឃើញ បានសង្កេត តើអ្នកជំងឺ ជាឧទាហរណ៍ ឬក៏ជនចាស់ជរា ដែលពិបាកនឹងធ្វើដំណើរ តើគាត់អាចស្នាក់នៅបានទេ មិនព្រមចាកចេញបានទេ?

**ឆ៖** ពេលនោះខ្ញុំចាកចេញពីទីក្រុងភ្នំពេញ ខ្ញុំមិនបានមើលនៅក្នុងផ្ទះទេ។ ក៏ប៉ុន្តែដែលខ្ញុំទៅដល់តាមផ្លូវជាតិលេខ២ មានឃើញចាស់ជរាខ្លះគាត់នៅដេកដួលនឹងផ្លូវ មានក្មេងខ្លះក៏ព្រាត់ឪពុកម្ដាយនៅស្រែកយំពេញហ្នឹងដែរ ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍។ ពេលនោះ គ្មានអ្នកណាជួយអ្នកណាបានទេ។

**ស៖** ក្នុងពេលនោះគឺថ្ងៃទី១៧ ខែមេសា ហើយនិងប៉ុន្មានថ្ងៃក្រោយនោះមក តើលោកដឹងដែរឬទេ លោកបានឃើញដែរឬទេ ថាមានទាហាន ឬក៏យោធា ឬក៏មន្ត្រីយោធារបស់ លន់ នល់ នៅកន្លែងណា? ហើយពួកអ្នកទាំងអស់នោះមានបញ្ហា ឬក៏ជួបនឹងហេតុការណ៍អ្វីដែរទេ?

[១៤:១២:២៣]

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញា ពេលដែលថ្ងៃរំដោះថ្ងៃ៧ មករា(ស៊ីក) ទើបខ្ញុំឃើញទាហាន លន់ នល់ ចេញទៅអបអរមួយចំនួននៅក្នុងកន្លែងជិតស្ពាតអូឡាំពិក។ ទទួលអបអរសាទរដើម្បីថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ដែលពេលដែលខ្ញុំជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្ញុំមិនបានឃើញទាហាន លន់ នល់ នៅទីណាទៀតទេ។

**ស៖** នៅពេលដែលគេបញ្ជូន -- ជម្លៀសលោកពីភ្នំពេញទៅតាកែវ លោកមិនដែលបានឃើញទាហាន លន់ នល់ ណាទៀតទេ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** សូមអរគុណ។ ឥឡូវនេះ លោកបាននិយាយទៅមេធាវីដែលសួរលោកថា គេប្រាប់លោកគឺខ្មែរក្រហមជាអ្នកប្រាប់លោកថា លោកត្រូវតែចាកចេញ ហើយថាទីក្រុងនឹងត្រូវទម្លាក់គ្រាប់បែកដោយអាមេរិកាំង។ សួរលោកថាតើមានការទម្លាក់គ្រាប់បែក នៅលើទីក្រុងភ្នំពេញដែរឬទេ ក្រោយពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នោះ?

[១៤:១៣:៤៩]

**ឆ៖** នៅពេលនោះខ្ញុំអត់មានឮសូរសំឡេងគ្រាប់បែកផ្ទុះទេ មានតែឮសំឡេងកាំភ្លើងរាយបាញ់រប៉េះរប៉ោះ ប្រហែលជាកាំភ្លើងនេះបាញ់គំរាមឲ្យប្រជាពលរដ្ឋចេញពីទីក្រុងតែប៉ុណ្ណោះ។ បើសំឡេង

គ្រាប់បែករបស់យន្តហោះអាមេរិកាំង ប្រហែលជាអត់ អត់ឮទេ។

**ស៖** គេប្រាប់លោកថា ព្រឹកនេះដែលលោកនិយាយនោះថា គេឲ្យចាកចេញទីក្រុងភ្នំពេញតែ ២, ៣ថ្ងៃតែប៉ុណ្ណោះ ដើម្បីចៀសពីការទម្លាក់គ្រាប់បែក។ ហើយក្រោយមកទៀត នៅពេលដែលលោកធ្វើដំណើរតាមផ្លូវ លោកបានសម្រេចចិត្តថា ត្រឡប់ទៅតំបន់ គឺថាស្រុកកំណើតនៅកម្ពុជាក្រោម។ នៅក្នុងប៉ុន្មានថ្ងៃនោះដែលលោកបានធ្វើដំណើរទៅ ហើយថាតើលោកបានស្នើសុំ ឬក៏ប្រាប់អ្នកណាម្នាក់ថាត្រូវត្រឡប់មកទីក្រុងភ្នំពេញ ឬក៏លោកបានឮថាទីក្រុងភ្នំពេញនោះត្រូវបានទម្លាក់គ្រាប់បែកដែរឬទេ?

**ឆ៖** សូមជម្រាបសហព្រះរាជអាជ្ញា សូមលោកសួរសំណួរនេះឡើងវិញ។ ខ្ញុំហាក់ដូចជា -- ពេលជម្លៀសចេញ ឬមួយពេលខ្ញុំត្រឡប់តាមផ្លូវរថភ្លើងមកភ្នំពេញវិញ? ពីព្រោះកន្លែងនេះ ខ្ញុំសូមឲ្យសួរឡើងវិញ។

[១៤:១៥:៤៥]

**ស៖** បាទ នេះជាសំណួរដែលគួរឲ្យច្រឡំ។ នៅពេលណាមួយ គឺថា១ថ្ងៃ ឬ ១សប្ដាហ៍ក្រោយពេលដែលលោកចាកចេញពីភ្នំពេញទៅនោះ តើអ្នកណាប្រាប់ថាឲ្យលោកត្រឡប់មកទីក្រុងភ្នំពេញដែរឬទេ ឬក៏លោកបានឮដំណឹងថា ទីក្រុងភ្នំពេញគេទម្លាក់គ្រាប់បែកហ្នឹងដែរឬទេ?

**ឆ៖** នៅពេលនោះគ្មានៗ ទទួលដំណឹងអ្វីទាំងអស់។ ទម្លាក់គ្រាប់បែកក៏អត់បានទទួលដំណឹងថាមានអ្នកគេប្រាប់ថាឲ្យយើងត្រឡប់មកភ្នំពេញវិញ ក៏អត់មានដែរ។ ទិសដៅរបស់ខ្ញុំ ដែលសំណុំ និងគ្រួសារបងប្អូនក្មួយខ្ញុំ គឺទិសដៅចង់ទៅស្រុកកំណើតទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងផ្ដោតទៅលើចំណុចដែលថា លោកធ្វើដំណើរចេញពីភ្នំពេញនៅពេលដែលលោកធ្វើដំណើរតាមផ្លូវ តើលោកបានឃើញទាហានខ្មែរក្រហម នៅតាមផ្លូវជួយដល់ប្រជាជនជាជនស៊ីវិលដែរឬទេ ក្នុងការធ្វើដំណើរចេញពីទីក្រុងនៅតាមផ្លូវនោះ?

**ឆ៖** សូមជម្រាប ពេលនោះខ្ញុំអត់បានឃើញទេ អត់បានឃើញទាហាន លន់ នល់ ណាដែលជួយឧបត្ថម្ភឲ្យប្រជាពលរដ្ឋ ដែលភៀសខ្លួនចេញពីទីក្រុងនេះទេ។

**ស៖** គឺថាអាចនឹងមានការច្រឡំ ដោយសារមានការបកប្រែ។ សំណួររបស់ខ្ញុំគឺ សួរថាតើមានកងទ័ពខ្មែរក្រហមណានៅតាមផ្លូវដើម្បីជួយដល់ប្រជាជនទេ នៅពេលដែលលោកធ្វើដំណើរចេញពីទីក្រុងទៅខាងក្រៅក្រុងនោះ?

[១៤:១៧:៥៩]

**ធ៖** សូមជម្រាបសហព្រះរាជអាជ្ញា នៅពេលដែលជម្លៀសចេញពីទីក្រុងនោះគឺ គ្មានទ័ពខ្មែរក្រហមណាដែលជួយឧបត្ថម្ភអាហារ ឬទឹកភក់តាមផ្លូវនោះ គឺអត់មានទេ។ អ្វីមួយក៏ដោយដែលប្រជាពលរដ្ឋ គាត់ដោះស្រាយដោយខ្លួនឯងនៅពេលជម្លៀស ទាំងគ្រួសារខ្ញុំ ទាំងប្រជាពលរដ្ឋដទៃ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ដំណើរបន្ទាប់របស់លោក នៅពេលដែលគេឲ្យលោកជិះរថភ្លើងដែលថា ដឹកលោកទៅមោងឫស្សី ខេត្តបាត់ដំបង បាទ ជានៅក្នុងស្រុកបាត់ដំបង។ លោកនិយាយថានៅពេលដែលគេឲ្យលោកជិះរថភ្លើងនោះ ក៏មានមនុស្សជាច្រើននៅលើរថភ្លើងនោះរួចទៅហើយ។ ខ្ញុំចង់សួរលោកថា តើរថភ្លើងហ្នឹង ជារថភ្លើងដឹកជញ្ជូនអ្នកដំណើរ ឬក៏ជារថភ្លើងដែលដឹកទំនិញនោះ? បាទ តើលោកអាចរៀបរាប់ប្រាប់តុលាការបានទេ?

**ធ៖** ពេលរថភ្លើងនោះឈប់ ខ្ញុំមិនបានមើលថា *វ៉ាហ្គុង* នោះជាបាហ្គុង ទំនិញ ឬវ៉ាហ្គុងសម្រាប់ដឹកអ្នកដំណើរទេ។ ដែលវ៉ាហ្គុង ខ្ញុំឡើងនេះ គឺអត់មានឃើញទំនិញនៅក្នុងនោះទេ ឃើញតែវ៉ាហ្គុង ហ្នឹងទំនេរ គឺមួយក្រុមដែលខ្ញុំនេះហ្នឹងឡើង ឡើងលើរថភ្លើងហ្នឹងទៅ។ ត្រង់វ៉ាហ្គុងផ្សេងគេ ខាងខ្មែរក្រហមគេដឹកស្អីទៀត ក៏ខ្ញុំមិនបានទៅមើលលើវ៉ាហ្គុងនោះដែរ។ ប៉ុន្តែលើវ៉ាហ្គុងដំបូលនោះគឺមានមនុស្សអង្គុយពេញលើហ្នឹងដែរ។

[១៤:២០:០៣]

**ស៖** សូមអរគុណ។ សូមលោកធ្វើការអត្ថាធិប្បាយអំពី និយាយអំពីទូដែលលោកជិះហ្នឹង ថាតើជាទូសម្រាប់ដឹកអ្នកដំណើរដែរឬទេ ឬក៏លោកអាចសម្គាល់ថាអាហ្នឹងជាទូសម្រាប់ដឹកទំនិញ ឬក៏ដឹកអ្នកដំណើរជំនួស។ តើលោកអាចសម្គាល់ អាចរៀបរាប់បានដែរឬទេ?

**ធ៖** ពីព្រោះទូរថភ្លើងនេះ ខ្ញុំក៏មិនស្គាល់ថា ទូណាដែលដឹកទំនិញ ទូណាដែលដឹកភ្ញៀវទេ។ ក៏ប៉ុន្តែដែលទូខ្ញុំជិះនេះ គឺមានចំហមុខក្រោយ។

**ស៖** សូមអរគុណ។ ឥឡូវនេះ តើលោកអាចរកមើលថា តើអ្នកដំណើរផ្សេងទៀតនោះ ពួកគេនោះមកពីណា តើលោកបានដឹងទេកាលនោះ?

**ធ៖** សូមជម្រាបសហព្រះរាជអាជ្ញា ពេលនោះខ្ញុំមិនបានសួរគេទេ ប៉ុន្តែថាអ្វីមួយ ទិសដៅរបស់គេ ដឹកទៅហើយ គឺយើងអត់ធ្មត់ខ្លួនឯង មិនប៉ានសួរ មិនប៉ាននិយាយទេ គឺទៅដឹក ដឹងតែថាគេបញ្ជាទៅណា ពេលគេដាក់ចុះត្រង់ណា គឺដាក់ចុះត្រង់ហ្នឹង គឺអត់មានប្រឆាំងបទបញ្ជា ហើយអ្នកអង្គុយគ្នាឯងហ្នឹង។ គ្រួសារខ្ញុំ ដឹងតែអង្គុយគ្រួសារខ្ញុំទៅ គេក៏គេមាន គេក៏មិនប៉ានសួរយើង យើងក៏អត់ប៉ាន

សួរគេដែរ។

**ស៖** លោកបានឆ្លើយពីខាងដើមនេះថា គេមិនអនុញ្ញាតឱ្យលោកជជែកជាមួយអ្នកផ្សេងទៀតទេនៅលើរថភ្លើង។ តើលោកអាចប្រាប់បានទេថា ហេតុអ្វីបានជាយើងមិនអាចសួរគ្នា មិនអាចនិយាយគ្នារវាងអ្នកធ្វើដំណើរជាមួយគ្នានោះ មកពីហេតុអ្វី?

**ឆ៖** នៅពេលនោះខ្ញុំបានចាំច្បាស់ថា ដែលពេលគេខ្សឹបខ្ញុំ ប្រាប់ខ្ញុំនៅខេត្តតាកែវនោះ។ អ្វីមួយគឺដឹងពេលនោះមក គឺខ្ញុំលែងហ៊ាននិយាយអ្វីទាំងអស់។ ប្រាប់ដឹងថា បើ -- ពីព្រោះសំឡេងខ្ញុំ កាលនោះខ្ញុំនិយាយទៅ វាខុសពីសំឡេងខ្មែរកណ្តាល។ ខ្ញុំជាខ្មែរក្រោម សំឡេងខ្ញុំនិយាយទៅវាខុសពីសំឡេងខ្មែរកណ្តាល។ ហេតុដូច្នេះហើយ ខ្ញុំទៅណាក៏ដោយ ក៏ខ្ញុំអត់សូវហ៊ាននិយាយស្តីឱ្យខុសពីហ្នឹងទេ។

[១៤:២៣:០៤]

**ស៖** ផ្អែកលើអ្វីដែលលោកបានសង្កេតនោះ នៅប៉ុន្មានថ្ងៃនោះ តើលោកយល់ដែរឬទេថាអ្នកផ្សេងទាំងអស់នោះដែលធ្វើដំណើរតាមរថភ្លើងនោះត្រូវបានគេបង្ខំដូចដែលគេបង្ខំលោកដែរឬទេ? ឬក៏អ្នកទាំងនោះធ្វើដំណើរដោយស្ម័គ្រចិត្តទេ?

**ឆ៖** បើតាមខ្ញុំសម្លឹងមើលដែលអ្នកជិះនៅក្នុងទូរថភ្លើងជាមួយខ្ញុំ។ ទឹកមុខគេប្រហាក់ប្រហែលជាមិនមែនជាអ្នកដំណើរទេ ប្រហែលជាដូចខ្ញុំដែរហើយ។

**ស៖** នៅពេលដែលលោកនិយាយថាដូចគ្រួសារខ្ញុំ។ តើលោកចង់និយាយថា គឺត្រូវបានគេបង្ខំឱ្យឡើងរថភ្លើងដូចក្រុមគ្រួសាររបស់លោកទៅបាត់ដំបងអ៊ីចឹង ឬក៏មានន័យខុសពីនេះ?

**ឆ៖** ជម្រាបព្រះរាជអាជ្ញា គឺន័យនេះ។

**ស៖** ហើយនៅក្រុមមនុស្សទាំងនោះ តើលោកអាចរៀបរាប់បានដែរឬទេ ថាតើមានបុរសស្ត្រីកុមារ មានចាស់ជរាដែរឬទេ តាមអ្វីដែលលោកបានឃើញនោះ ដើម្បីឱ្យតុលាការបានជ្រាប?

**ឆ៖** បាទនៅពេលនុ៎ង គឺមានលាយឡំគ្នាដូចគ្រួសារខ្ញុំដែរ មានទាំងចាស់ក្មេងដូចគ្នា។

[១៤:២៥:១២]

**ស៖** នៅពេលដែលលោកបានទៅដល់ខេត្តបាត់ដំបង តើលោកធ្លាប់បានឃើញរថភ្លើងផ្សេងទៀត ឬក៏អ្នកដំណើរផ្សេងទៀត ដែលគេដឹកតាមរថភ្លើងមកពីកន្លែងផ្សេងៗ ដូចលោកដែរឬទេ នៅពេលដែលលោកទៅដល់ទីនោះហើយ?

**ឆ៖** សូមជម្រាប ពេលនោះ ខ្ញុំចុះនៅវ៉ាហ្នឹងហើយ គឺអត់បាននៅជិតហ្នឹងទៀតទេ។ គេយក

រទេះគោដឹកចេញទៅហើយ ខ្ញុំអត់បានឃើញក្រោយពីហ្នឹងទៀតទេ។

**ស៖** ខ្ញុំនឹងសួរលោកសំណួរមួយចំនួនដែលលោកបានឆ្លើយហើយ។ គឺអាចអ៊ីចឹង ប៉ុន្តែខ្ញុំសូមសួរដើម្បីឱ្យលោកឆ្លើយ ដើម្បីកត់ត្រាច្បាស់លាស់ក្នុងកំណត់ត្រាតុលាការ។ នៅពេលដែលលោកទៅដល់មោងឫស្សី នៅស្ថានីយដែលលោកចុះពីរថភ្លើងនោះ តើលោកអាចទៅកន្លែងណាមួយ ដែលលោកចង់ទៅបានទេ បន្ទាប់ពីនោះ? ឬក៏គេប្រាប់ថា ត្រូវតែទៅសហករណ៍នេះ ឬក៏ទៅកន្លែងនេះ កន្លែងនោះ?

[១៤:២៦:២៨]

**ឆ៖** នៅពេលនោះ គឺមិនអាចតាមចិត្តយើងបានទេ។ ពីព្រោះទៅដល់ទីនោះ គឺមានក្រុមរទេះគោ គេចាំដឹកយើងហើយជាស្រេចទៅហើយ។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ លោក ចៅ នី។ បាទ នៅពេលដែលលោកចុះពីរថភ្លើង តើលោកអាចឃើញថា តើមានមនុស្សប៉ុន្មានដែលថា មួយជើងរថភ្លើងជាមួយលោកនោះ ប្រហែលជាចំនួនប៉ុន្មាន?

**ឆ៖** មួយជើងនោះ បើខ្ញុំស្មានទៅ ប្រហែលជារាប់ពាន់មនុស្ស។

**ស៖** តើអ្នកទាំងអស់នោះ ដែលថាដល់ពាន់នោះ តើគេត្រូវចុះនៅក្នុងស្ថានីយនៅមោងឫស្សីតែមួយជាមួយលោកហ្នឹង ដែរឬទេ?

**ឆ៖** ពេលចុះហ្នឹង ចុះអត់អស់ទេ។ រថហ្នឹង គឺទៅទៀត ប៉ុន្តែទៅដល់ ខ្ញុំអត់ដឹងទេ។

[១៤:២៧:៥៨]

**ស៖** តើតាមអ្វីដែលលោកបានសង្កេតឃើញនោះ តើអ្នកដែលគេដឹកនោះ មានខ្មែរក្រហមទាហានខ្មែរក្រហមគេយាមដែរឬទេ?

**ឆ៖** នៅពេលខ្ញុំជិះលើទូរថភ្លើងនោះ គឺមានគេដើរចុះដើរឡើង តាមវ៉ាហ្គុងហ្នឹង ខ្ញុំដែរ។ ក្រុមអាវខ្មៅនោះ គេដើរចុះដើរឡើង ក៏ប៉ុន្តែបើគេដើរទៅបង្ហួត ឬក៏ទៅត្រឹមណាទៀត ក៏ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែដែលនេះ មានពួកអាវខ្មៅហ្នឹង គេដើរចុះដើរឡើងនៅតាមវ៉ាហ្គុង ខ្ញុំដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ដើម្បីជាអត្ថប្រយោជន៍ការសន្សំពេល ខ្ញុំសូមអនុញ្ញាតបញ្ចប់សំណួររបស់ខ្ញុំ ហើយសូមអរគុណលោក ចៅ នី ដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្មដល់តុលាការ ហើយសូមឱ្យលោកធ្វើដំណើរដោយសុវត្ថិភាព។ សូមអរគុណលោកប្រធាន និងលោកស្រីចៅក្រម។

[១៤:២៨:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្វង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ហើយលោក ចៅ នី ជម្រាបសួរ។

**សួរដោយចៅក្រម ហ្វង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនតូចតែប៉ុណ្ណោះដើម្បីសុំការបំភ្លឺ។ លោកបាននិយាយអំពីការភ័យខ្លាចរបស់លោកជាច្រើន។ ពីព្រោះថាលោកជាខ្មែរក្រោម ហើយលោកក៏បាននិយាយផងដែរ អំពីអ្វីដែលចំពោះលោកនោះ គឺថាខ្មែរក្រហមជាកម្មវត្ថុនៃការរើសអើង។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺថាតើការភ័យខ្លាចនេះ កើតមានឡើងចាប់តាំងពីពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក៏ភ័យខ្លាចនេះកើតមានឡើងពេលក្រោយហើយមកដែរទេ?

**លោក ចៅ នី៖**

**ឆ៖** សូមជម្រាបលោកប្រធាន ពេលនោះខ្ញុំពេលរំដោះភ្លាមមិនបានថា ដឹងថាខ្មែរក្រហមគេរើសអើងថា ខ្មែរក្រោម ខ្មែរកណ្ដាល ខ្មែរលើទេ។ ទើបតែខ្ញុំជម្លៀសទៅដល់ខេត្តតាកែវ មានគេខ្សឹបប្រាប់ខ្ញុំទេ បានខ្ញុំមានការភ័យខ្លាចការរើសអើង។

**ស៖** ហើយមុនថ្ងៃទី១៧ មេសា តើលោកធ្លាប់ឮគេនិយាយពីការរើសអើងនេះទេ ឬក៏លោកធ្លាប់ឮនិយាយពីអាកប្បកិរិយាណាមួយផ្សេងទៀតរបស់ពួកខ្មែរក្រហមនោះ? តើលោកគិតយ៉ាងម៉េចដែរអំពីពួកខ្មែរក្រហម?

**ឆ៖** តាមខ្ញុំមើល ខ្ញុំឮអាកប្បកិរិយាខ្មែរក្រហម កាលពីគាត់នៅតស៊ូក្នុងព្រៃហាក់ដូចជាមិនរើសអើងជនជាតិណាមួយទេ។ ហេតុអីដល់ពេលគាត់បានចូលកាន់កាប់រំដោះទីក្រុងភ្នំពេញ ពេលនោះទើបខ្ញុំដឹងថា ខ្មែរក្រហមគាត់រើសអើង។

[១៤:៣១:៣៩]

**ស៖** តើលោកធ្លាប់ចូលរួមការអប់រំនយោបាយ ឬទិតៀន ស្វ័យទិតៀន ដែលនៅក្នុងកិច្ចចូលក្នុងការប្រជុំហ្នឹងគេមាននិយាយពីខ្មែរក្រហម ហើយមានពន្យល់ -- ខ្មែរក្រោម ហើយនិងគេមានពន្យល់ពីមូលហេតុនៃការរើសអើងចំពោះពួកខ្មែរក្រោមនេះ លោកធ្លាប់ចូលរួមការរៀនសូត្របែបហ្នឹងទេ?

**ឆ៖** ជម្រាបលោកប្រធានពេលនោះខ្ញុំបានអត់បានចូលប្រឡូកក្នុងកិច្ចការអ្វីមួយទេ។

**ស៖** អ៊ីចឹងតើលោកដឹងថា ហេតុអ្វីបានជាមានការរើសអើងបែបនេះទេ នេះបើតាមលោកដឹងខ្លួនឯងផ្ទាល់?

**ឆ៖** ដំបូងឡើយខ្ញុំមិនគិតថា ខ្មែរក្រហមគាត់រើសអើងនៃបងប្អូនខ្មែរកម្ពុជាក្រោមទេ។ សូម្បីតែគេប្រាប់ខ្ញុំនៅតាកែវថា ឲ្យលាក់ប្រវត្តិរូបខ្មែរកម្ពុជាក្រោមកុំបញ្ចេញក៏ខ្ញុំនៅ -- គ្រាន់តែសង្ស័យក្នុងខ្លួនតែប៉ុណ្ណោះទេ។ ទើបតែថ្ងៃរំដោះហើយ ថ្ងៃរំដោះ ៧៩ ហើយខ្ញុំទៅរករូបឪពុកធំខ្ញុំ បងប្អូនខ្ញុំស្លាប់នៅក្នុងទួលស្លែងទើបឃើញដែលបទបញ្ជារបស់ខ្មែរក្រហមសរសេរនៅក្នុងមាត្រាទី៨ ឬទី៩ ខ្ញុំមិនបានចាំទេ។ នៅក្នុងក៏មានសរសេរថា "កុំឆ្លើយថា ខ្មែរក្រោម ដើម្បីយកលេសរួចខ្លួនឯង"។ នៅក្នុងគុកទួលស្លែងគឺមានអក្សរនេះ។

[១៤:៣៣:៥៥]

**ស៖** បាទ ដើម្បីជាកំណត់ត្រាប្រតិចារឹក តើលោកអាចនិយាយឃ្លាចុងក្រោយឡើងវិញ បានទេព្រោះថា ឃ្លាចុងក្រោយនេះអត់មានការបកប្រែទេ មានឮតែពាក្យទួលស្លែងតែប៉ុណ្ណោះអំមិញនេះ។

**ឆ៖** ពេលដែលខ្ញុំឮគេប្រាប់ខ្ញុំនៅខេត្តតាកែវ ខ្ញុំមិនបានចាប់អារម្មណ៍ប៉ុន្មានទេ ដែលថា ឲ្យលាក់ប្រវត្តិរូបខ្មែរក្រោមកុំឲ្យបញ្ចេញ។ ខ្ញុំគ្រាន់តែលាក់ទេ រហូតមកដល់ពេលរំដោះឆ្នាំ១៩៧៩ ខ្ញុំដើរស្វែងរកបងប្អូន ហើយនិងចូលទៅគុកទួលស្លែងរកមើលរូបថត ក្រែងឃើញបងប្អូនខ្ញុំស្លាប់នៅក្នុងទួលស្លែង។ ពេលនោះ ខ្ញុំបានឃើញពាក្យស្លោករបស់ខ្មែរក្រហមគាត់សរសេរនៅដាក់ស្លាកជញ្ជាំងនៅមាត្រាទី៨ ឬទី៩ ខ្ញុំមិនបានចាំលេខទេ។ គាត់សរសេរដាក់នៅក្នុងនោះថា "កុំឆ្លើយថាឯងជាខ្មែរក្រោមដើម្បីរួចខ្លួន"។ នេះហ្នឹងអត្ថន័យរបស់ខ្មែរក្រហមនេះ គាត់ចង់ថាខ្មែរក្រោមនេះយ៉ាងណា។

[១៤:៣៥:២៧]

**ស៖** ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីស្ថានភាពនៅភ្នំពេញ ថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ខ្ញុំ -- បើខ្ញុំយល់មិនច្រឡំទេនោះថា បងប្រុសរបស់លោកមានតួនាទីនៅក្នុងកងទ័ពរបស់ លន់ នល់។ តើលោកអាចរៀបរាប់អំពីស្ថានភាពយោធានៅពេលនោះដែរឬទេ? ហើយបងប្រុសរបស់លោកនោះធ្វើយ៉ាងម៉េចដែរ? តើគាត់រត់គេចខ្លួន ឬក៏គាត់ទទួលបទបញ្ជាជាក់លាក់ណាមួយពីថ្នាក់លើ?

**ឆ៖** សូមទោសនៅក្នុងចម្លើយមុន ខ្ញុំបងប្រុសខ្ញុំអត់មាននៅក្នុងជួរទាហានទេ ធ្វើក្នុងធនាគារឥណទានជាតិ ធនាគារ។ ខ្ញុំអត់មានឆ្លើយថា បងខ្ញុំនៅក្នុងជួរទាហាន លន់ នល់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំភ័ន្តច្រឡំអម្បាញ់នេះ។ បាទ ហើយខ្ញុំសូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំលែងមានសំណួរចោទសួរទៅលោកទៀតហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញ អ៎! ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក្នុងការ -- ក្នុងរយៈពេលនៃការឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបីខ្វះដប់នាទី។

សូមអញ្ជើញ! សូមអញ្ជើញលោកមេធាវី!

[១៤:៣៧:៣៥]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំគិតថា ខ្ញុំអាចមានលទ្ធភាពជួយដល់អង្គជំនុំជម្រះបាន។ យើងមិនមានសំណួរអ្វីទេសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ហើយខ្ញុំក៏បានដំណឹងដែរគឺថា សហមេធាវីផ្សេងទៀត ដូចជាមិនមានសំណួរអ្វីនោះទេ។ ហើយសូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការបញ្ជាក់នូវបញ្ហានេះ។ ចុះមេធាវីពីរក្រុមទៀតយ៉ាងម៉េចដែរ? មេធាវីការពារក្តីលោកអៀង សារី?

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ដូចលោក អ៊ីនូហ្ស៊ី លើកហើយ ត្រឹមត្រូវតាមហ្នឹងហើយ ហើយប្រហែលជាលោកប្រធានអាចបន្តដំណើរការនេះឲ្យចប់តែម្តងទៅ គឺទាក់ទង -- គ្រាន់តែទាក់ទងទៅលើហើយសម្តីចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ទាក់ទងនឹងរឿងទុក្ខសោករបស់គាត់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន យើងអត់មានសំណួរដែរ ក្រុមលោកខៀវ សំផន។ ដូច្នេះសូមលោកប្រធានអាចបន្តនីតិវិធី ដើម្បីបញ្ចប់។ បាទ សូមអរគុណ។

[១៤:៣៨:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណណាស់ដែលបានទទួលព័ត៌មាននេះ។ អ៊ីចឹងយើងមិនចាំបាច់សម្រាកទេ យើងបន្តបញ្ចប់តែម្តង ពីព្រោះនៅមានពេលវេលាតិចតួចទេ។ នេះគឺជាច្បាស់លាស់ហើយ។

ជាចុងក្រោយនេះ អង្គជំនុំជម្រះបានជម្រាបជូនលោករួចហើយ លោក ចៅ នី អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅ ដើម្បីមានឱកាសក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្ម គឺផលអន្តរាយទាំងឡាយដែលប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

**លោក ចៅ នី៖**

សូមជម្រាបលោកប្រធាន ខ្ញុំសូមសំណូមពរលោកប្រធាន ហើយនិងមេធាវី សហព្រះរាជអាជ្ញាបន្ថិច បានសូមសួរទៅលោកអ៊ំ ខៀវ សំផន បានដែរឬអត់? ខ្ញុំពាក់ព័ន្ធនឹងអ៊ំខ្ញុំមួយ ដែលពាក់ព័ន្ធជាមួយលោកពូ ខៀវ សំផន។

[១៤:៣៩:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤០:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាចម្លើយរបស់ខ្ញុំប្រហែលជាមិនច្បាស់លាស់នោះទេ ក៏ប៉ុន្តែខ្ញុំព្យាយាមដើម្បីជាប្រយោជន៍ប្រតិចារឹកនេះ គឺថាជាការសំខាន់ណាស់ដែលដើមបណ្តឹងរដ្ឋប្បវេណី

អាចនិយាយនៅក្នុងអង្គជំនុំជម្រះនេះ អំពីការឈឺចាប់របស់ខ្លួន ហើយនិងការលំបាកដែលខ្លួនបានជួប។ ក៏ប៉ុន្តែមិនជាការសមស្របទេ ក្នុងការនិយាយជាមួយជនជាប់ចោទនោះ ព្រោះថាអង្គជំនុំជម្រះគួរតែរំឭកអំពីក្របខ័ណ្ឌ នៃវិសាលភាព នៃការជម្រះសេចក្តីយើងនេះ និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយអ៊ីចឹងសូមឲ្យរំឭកដល់ដើមបណ្តឹងរដ្ឋប្បវេណី អំពីវិធាន និងនីតិវិធីនៅទីនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា នេះជាករណីលើកទី១ ប៉ុន្តែមិនមានការហាមឃាត់នៅក្នុងវិធានផ្ទៃក្នុង ដែលរារាំងមិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើសេចក្តីថ្លែងការណ៍ជាទូទៅ អំពីរូបគាត់ ហើយនិងគាត់យោងទៅរកហេតុការណ៍ ដូចដែលគាត់ស្នើនោះទេ។ ដូច្នេះ សូមតុលាការអនុញ្ញាតឲ្យគាត់ធ្វើដូច្នេះ។

[១៤:៤២:១៦]

**ប្រធានអង្គជំនុំ៖**

ម៉េចពីរក្រុមហ្នឹង ដូចជាអាច -- ដូចស្រេចចិត្តហើយនេះ មែនទេ? ពីរក្រុមហ្នឹងចូលរឿងស្រេចនឹងចិត្តហើយ នេះវាដូចជា -- ឥឡូវឲ្យក្រុមមេធាវីការពារក្តីមុន។ ហើយលោក អាង ឧត្តម សូមអញ្ជើញ ហើយឲ្យអស់ខាងមេធាវីការពារក្តីសិន សូមខាងភាគីចោទហ្នឹង គឺសូមលើកឡើងឲ្យបានជាក់ច្បាស់លើបញ្ហាស្អីឲ្យច្បាស់លាស់។ មិនមែនដើបតាមតែចិត្តចង់អ៊ីចឹងទេ។

**លោក អាង ឧត្តម៖**

បាទ សូមអរគុណលោកប្រធាន ហើយសូមអធ្យាស្រ័យផង។ ខ្ញុំគ្រាន់តែចង់មានអន្តរាគមន៍ចង់ជួយតុលាការ ក្នុងការពិចារណាកិច្ចការនេះតែប៉ុណ្ណោះ។ មុននឹងសម្រេចថា -- តាមពិតដើមបណ្តឹងរដ្ឋប្បវេណី គាត់មានសិទ្ធិក្នុងការសួរមែន ក៏ប៉ុន្តែក៏គិតដល់សិទ្ធិរបស់ជនជាប់ចោទក្នុងទីនេះ គឺលោក ខៀវ សំផន ថាតើគាត់រក្សាសិទ្ធិមិនឆ្លើយនឹងសំណួរណាមួយ ឬមួយយ៉ាងម៉េច សូមតុលាការពិចារណា។ បើគាត់រក្សាសិទ្ធិមិនឆ្លើយ នោះប្រហែលជាយើងមិនអាចបង្ខំឲ្យគាត់ឆ្លើយទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ មានបញ្ហាអីទៀតទេ? សូមអញ្ជើញ!

[១៤:៤៣:៤២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនប្រើពេលវែងទេ ខ្ញុំគាំទ្រ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយយើងមិនមានការហាមឃាត់ក្នុងការហាមមិនឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនេះ ធ្វើសេចក្ដីថ្លែងអំពីការថ្លែងទុក្ខរបស់គាត់ ដែលយោងទៅដល់ករណីដែលគាត់បានស្នើនោះទេ។ ដូច្នេះហើយគាត់បានបញ្ជាក់ច្រើនហើយ ហើយខ្ញុំកត់សម្គាល់ថា ជនជាប់ចោទគឺបានលើកឡើងដែរ គឺថាគាត់ឆ្លើយតបទៅនឹងយោងទៅរកនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះហើយ យើងសង្កេតឃើញថា នៅទីបំផុតនោះនៅក្នុង ជាកំណត់ហេតុហ្នឹងគឺថា មេធាវីរបស់ អៀង សារី និយាយថា លោក ខៀវ សំផន គាត់អាច ពេលខ្លះធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងដំណាក់កាលជំនុំជម្រះ។ ដូច្នេះ ការដែលគាត់អះអាងថា គាត់លោក ខៀវ សំផន នឹងប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ អាហ្នឹងគឺ ដូចជាលោកមេធាវីជំនួសឲ្យគាត់ដូច្នោះ។ ដូច្នេះ សូមតុលាការពិនិត្យពិចារណា។ អរគុណបាទ។

**ប្រធានអង្គជំនុំ៖**

លោក ខៀវ សំផន តើលោករហូតដល់ពេលនេះ លោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏លោកប្រើសិទ្ធិរបស់លោកក្នុងការឆ្លើយតប? ពីព្រោះលោកស្ដាប់អម្បាញ់មិញហើយ គឺឮទាំងអស់គ្នាគឺដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មានសំណួរមួយចំនួនចង់សួរទៅលោក។

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន នៅក្នុងអន្តរាគមន៍ខ្ញុំពីពេលមុនៗ តាមខ្ញុំចាំ ខ្ញុំបានសុំសិទ្ធិធ្វើអត្ថាធិប្បាយលើកថាខណ្ឌ ដែលលោកប្រធានបានតម្រូវឲ្យធ្វើអត្ថាធិប្បាយ។ ក៏ប៉ុន្តែខ្ញុំក៏បានបញ្ជាក់ថា ខ្ញុំមិនឆ្លើយសំណួរ -- មិនទាន់ឆ្លើយសំណួរណាទេ ពីព្រោះចាំឲ្យផ្ដល់ភស្តុតាងឲ្យបានសព្វគ្រប់សិននៅពេលចុងសវនាការនេះ ទើបខ្ញុំនឹងឆ្លើយជាយថាហេតុទៅនឹងសំណួរ។ បាទ សូមរំឭក គោរពលោកប្រធានតែប៉ុណ្ណេះ។ សូមអរគុណបាទ។

[១៤:៤៦:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយ ច្បាស់លាស់ហើយ ពីព្រោះបញ្ហានេះ គឺវាពាក់ព័ន្ធជាមួយនឹងការដែលប្រើសិទ្ធិដែលមិនឆ្លើយតបរបស់ជនជាប់ចោទ ដោយសារគាត់បានបង្ហាញជំហរនេះច្បាស់លាស់ទាំងពីដើម

ទីមក។ អ៊ីចឹងបើសួរទៅ បើគាត់នៅតែរក្សាសិទ្ធិមិនឆ្លើយតបដូចនាពេលនេះ គឺមិនមានប្រយោជន៍អីទេ។

[១៤:៤៦:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៧:០៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញដើមបណ្ដឹងតាំងសំណួរ ប៉ុន្តែលោកសួរមកយើង។ ពីព្រោះចៅក្រមទាំងអស់គេអត់ព្រមទេ។ ការសម្រេចអំមិញគឺយើងតែម្នាក់ឯងទេ។ អ៊ីចឹងយើងសម្រេចឲ្យលោកសួរ ហើយចាំសួរថាតើលោក ខៀវ សំផន ឆ្លើយឬក៏អត់។ លោកតាំងសំណួរមកយើង មិនអាចសួរទៅផ្ទាល់ទៅ ខៀវ សំផនទេ។ នេះជានីតិវិធីដែលចែងក្នុងច្បាប់ តាមរយៈប្រធានសវនាការ។

**លោក ចៅ នី៖**

សូមជម្រាបលោកប្រធាន។ សំណួរដែលខ្ញុំចង់សួរទៅលោក ខៀវ សំផន នោះគឺអត់មានអ្វីនឹងចងគំនុំជាមួយអ៊ំ ខៀវ សំផន ទេ។ គ្រាន់តែខ្ញុំសួរថា ពេលដែលថ្ងៃ១៧ មេសា រំដោះនៅទីក្រុងភ្នំពេញ លោក ខៀវ សំផន បានចារលិខិតមួយទៅអញ្ជើញឈ្មោះអ៊ំរបស់ខ្ញុំ ឈ្មោះ ចៅ សៅ ឲ្យចូលទីក្រុងភ្នំពេញវិញ។ តើមូលហេតុអ្វី? ហើយពេលនោះអ៊ំ តើលោក ខៀវ សំផន ហ្នឹងបានជួបអ៊ំខ្ញុំដែរឬអត់? ទី១។ ទី២ទៀត តែកុងឡានរបស់លោក ចៅ សៅ នៅពេលខែ -- ពេលឆ្នាំ១៩៧៩ ខ្ញុំបានជួបគាត់នៅភ្នំពេញ គាត់បាននិយាយថា “ពេលលោក ចៅ សៅ ជម្លៀសខ្លួនទៅដល់ព្រៃកក្ដាម មានទាហានពីរនាក់យកលិខិតរបស់លោកអ៊ំ ខៀវ សំផន យកទៅឲ្យលោក ចៅ សៅ”។ ហើយក្នុងលិខិតនោះបាន និយាយថា “សូមអញ្ជើញលោក ចៅ សៅ ចូលទីក្រុងភ្នំពេញវិញ”។ តែលោក ចៅ សៅ បានបដិសេធ គាត់ថា “បើឲ្យគាត់ចូលទីក្រុងភ្នំពេញវិញ លុះត្រាប្រជាពលរដ្ឋទាំងអស់ចូលទីក្រុងភ្នំពេញវិញ គាត់ក៏អត់ចូលទេ”។ ក្រោយមក លោកពូ ខៀវ សំផន បាន -- ទាហានពីរនាក់ហ្នឹងទៅលើកទី២ទៀត។ អញ្ជើញគាត់ចូលទីក្រុង គាត់ក៏អត់ចូលដែរ។ រហូតតាំងពីនោះមក លោក ចៅ សៅ បាត់ខ្លួនរហូតដល់ពេលនេះ។

[១៤:៤៩:៤០]

ខ្ញុំចង់សួរលោកអ៊ំ ខៀវ សំផន ថា តើគាត់ស្លាប់នៅទីណា? នៅពេលនេះ គាត់ស្លាប់នៅទីណា? ខ្ញុំចង់សួរដឹងតែប៉ុណ្ណឹង ដើម្បីខ្ញុំទៅរកសាកសពគាត់យកមកធ្វើបុណ្យ តាមប្រពៃណីជាតិរបស់ខ្មែរទេ។

ខ្ញុំមិនមែនទៅចងកំហឹងអ្វីជាមួយលោកអ៊ំ ខៀវ សំផន ទេ។

**ប្រធានអង្គជំនុំ៖**

លោក ខៀវ សំផន អាចឆ្លើយបានទេថា តើ ចៅ សៅ ហ្នឹង គាត់ស្លាប់នៅទីណា?

យើងសួរលោក ខៀវ សំផន។ លោកស្រីមេធាវី យើងសួរមេធាវី -- ខៀវ សំផន បើគាត់មិនឆ្លើយទេ ឲ្យគាត់ឆ្លើយថា គាត់មិនឆ្លើយតបទេ។ បើគាត់ឆ្លើយ សូមអញ្ជើញឆ្លើយ!

[១៤:៥០:៤៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំត្រូវតែអន្តរាគមន៍នៅពេលនេះ តែម្តង លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

យើងសួរទៅលោក ខៀវ សំផន។ លោកស្រីមេធាវីអង្គុយចុះសិនទៅ លោកចង់ធ្វើអន្តរាគមន៍គឺលោកពេលក្រោយ! យើងចង់បានស្តាប់សំឡេងពីលោក ខៀវ សំផន។ តើគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏គាត់ឆ្លើយតប? បើឆ្លើយតប ឆ្លើយនឹងសំណួរអំមិញ តើស្គាល់ ចៅ សៅ ទេ? ហើយ ចៅ សៅ នោះ ស្លាប់នៅកន្លែងណា? នេះជាសំណួរដែលសួរ។ លោក ខៀវ សំផន!

[១៤:៥១:២០]

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

យើងឲ្យលោក ខៀវ សំផន ជាអ្នកសម្រេចចិត្ត ព្រោះយើងសួរទៅលោក ខៀវ សំផន។

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរបញ្ជាក់ តើការដែលឆ្លើយរបស់ខ្ញុំ នៅពេលនេះចំពោះតែសំណួរមួយនេះ វាប៉ះពាល់ដល់ការរក្សាសិទ្ធិនៅស្ងៀមរបស់ខ្ញុំទេ? បើមិនប៉ះពាល់ទេ ខ្ញុំឆ្លើយឥឡូវហ្នឹងបាន។

**ប្រធានអង្គជំនុំ៖**

នេះជាការសម្រេចចិត្តរបស់លោក ពីព្រោះលោកក៏មិនបានសម្រេចចិត្តដាច់ណាត់ថា លោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបពេញដំណើរការនីតិវិធីសវនាការរឿងក្តី០០២ នេះដែរ។ លោករក្សាសិទ្ធិ

នៅស្ងៀមមិនឆ្លើយតប មានលក្ខខណ្ឌ។ ដូច្នេះ អ្វីទាំងអស់នេះ គឺសម្រេចចិត្ត ដោយសារលោកខ្លួន។

[១៤:៥២:១៧]

លោកឆ្លើយ គឺអាចឆ្លើយនឹងសំណួរនេះ។ បើលោកថាមិនឆ្លើយទេ គឺលោកថា រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ នេះជាវិធីក្នុងការឆ្លើយ។ ការសម្រេចចិត្តនៅលើលោកផ្ទាល់ខ្លួន។

**លោក ខៀវ សំផន៖**

បានលើកជាហូរហែហើយមកហើយបាទ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

ឲ្យច្បាស់លាស់ ឆ្លើយមែនទែន ឆ្លើយថាម៉េច?

លោកស្រីមេធាវីសូមអង្គុយចុះ! យើងជាអ្នកសួរលោក ខៀវ សំផន មិនមែនលោកស្រីទេ។ ហើយមិនមែនភាគីទេ។ ឥឡូវនេះ គឺយើងជាអ្នកសួរ។

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

មិនមានមុខងារលោកទេ។ សូមអង្គុយចុះ! អង្គុយចុះ!

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:៥៤:០០]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោក ខៀវ សំផន?

**លោក ខៀវ សំផន៖**

បាទ សូមទោសលោកប្រធាន ខ្ញុំបានប្រគល់សិទ្ធិឲ្យមេធាវីខ្ញុំ តំណាងឲ្យខ្ញុំ។ ឯផ្ទាល់ខ្លួនខ្ញុំ ខ្ញុំបាននិយាយតាំងពីដើមទី ថា "ខ្ញុំបាទនឹងឆ្លើយជាយថាហេតុ នៅសំណួរ នៅពេលដែលចុងមានភស្តុតាងគ្រប់សព្វ គឺនៅចុងសវនាការនេះ"។ បាទ សូមអស់។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវជាបន្ត តើលោកមានអ្វីថ្លែងការណ៍ទេ ឥឡូវគាត់អត់ឆ្លើយនឹងសំណួរនេះទេ គាត់រក្សា

សិទ្ធិនៅស្ងៀមមិនឆ្លើយតប ពីព្រោះនៅក្នុងនីតិវិធីនោះ គាត់បានបញ្ជាក់ជាហូរហែ នៅក្នុងនីតិវិធី គាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ឥឡូវហ្នឹង សំណួរដែលប៉ុនប៉ងដែលសួរគាត់ គឺគាត់មិនឆ្លើយតបទេ គាត់នៅរក្សាសិទ្ធិមិននៅស្ងៀម មិនឆ្លើយតបដដែល។ សំណួរចុងក្រោយរបស់យើងសួរថា តើលោកប្រើសិទ្ធិរបស់លោកក្នុងការថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រាប់ដល់អង្គសវនាការដែរឬទេ ឥឡូវនេះ? សូមអញ្ជើញ!

**លោក ចៅ នី៖**

សូមជម្រាបលោកប្រធាន ខ្ញុំសោកស្តាយណាស់ដែលសំណួររបស់ខ្ញុំចង់សួររកអ៊ំរបស់ខ្ញុំ គាត់មិនមែនឆ្ងាយ -- មិនមែនថា ខៀវ សំផន នេះគាត់អត់ស្គាល់ទេ។ ខៀវ សំផន គាត់ស្គាល់ ចៅ សៅ នេះច្បាស់ណាស់ គាត់ធ្លាប់ហូបបាយជាមួយគ្នាទៀត។ គាត់មិនមែនថា បដិសេធថាមិនដឹងថា សាកសពរបស់គាត់ស្លាប់នៅទីណាទេ? គាត់មិនមែន -- គាត់មិនគួរបដិសេធទេ។ សំខាន់បំផុត គាត់គ្រាន់តែបង្ហើបប្រាប់ថា គាត់ស្លាប់នៅកន្លែងណាឲ្យខ្ញុំនឹងយកធាតុរបស់គាត់ យកទៅធ្វើបុណ្យតាមប្រពៃណីខ្មែររបស់យើងតែប៉ុណ្ណោះទេ។

[១៤:៥៦:០៩]

អ៊ីចឹងទុក្ខសោករបស់ខ្ញុំនៅដដែលហ្នឹង ទោះបីបានឡើងតុលាការយ៉ាងណាក៏ខ្ញុំមិនអស់ៗចិត្តទេៗ តើឲ្យខ្ញុំថ្លែងៗទុក្ខហ្នឹងទៅប្រាប់នរណាបើដល់តុលាការហើយ តុលាការគ្រាន់តែឲ្យគាត់ឆ្លើយប្រាប់ថា អ៊ំខ្ញុំស្លាប់នៅកន្លែងណា? ក្មួយខ្ញុំស្លាប់ខ្ញុំមិននិយាយទេ ហើយខ្ញុំមិនចងកំហឹងជាមួយគាត់ទេ។ ខ្ញុំគ្រាន់តែឲ្យគាត់បង្ហើបរឿងដែល ចៅ សៅ ស្លាប់នៅកន្លែងណា ខ្ញុំនឹងទៅយកធាតុគាត់ យកមកធ្វើបុណ្យតាមប្រពៃណីជាតិ -- បុណ្យប្រពៃណីខ្មែរយើងតែប៉ុណ្ណោះទេ។

យើងបើគាត់មិនដែលស្គាល់ ចៅ សៅ ខ្ញុំយករូបថតឲ្យមើល។ រូបថត ចៅ សៅ បើៗលោកភ្លេចមុខ ចៅ សៅ ខ្ញុំយករូបថតឲ្យមើល ហើយលោកអ៊ំមិនគួរបដិសេធទេ។

**ប្រធានអង្គជំនុំ៖**

មានអីទៀតទេ?

[១៤:៥៧:៣៤]

**លោក ចៅ នី៖**

ខ្ញុំមានតែប៉ុណ្ណឹងទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់លោក ថៅ នី។ ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះ បានចប់ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងការពិតក្នុងរឿងក្តីនេះ ហើយលោក ថៅ នី អាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោក ថៅ នី ជួបតែសំណាងល្អ មានសុខភាពល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងណាគាត់ដែលគាត់ចង់ទៅបានហើយ។ លោក ថៅ នី អាចចាកចេញពីបន្ទប់សវនាការត្រឡប់ទៅវិញបានហើយ។

[១៤:៥៨:៤៧]

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវី ឬក៏ភាគីដែលពាក់ព័ន្ធនៃរឿងក្តី សូមធ្វើការកត់សម្គាល់អំពីខ្លឹមសារនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី ដែលបានផ្តល់សក្ខីកម្មរួចហើយអម្បាញ់មិញនេះ។ តើមានអ្វីចង់កត់សម្គាល់ដែរឬទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអន្តរាគមន៍នៅពេលនេះ បើសិនជាលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

យើងអនុញ្ញាតដូចអ្វីដែលយើងបានជម្រាបអ៊ីចឹង គឺឲ្យធ្វើការកត់សម្គាល់នូវខ្លឹមសារនៃសក្ខីកម្មរបស់ ថៅ នី ដែលបានផ្តល់សក្ខីចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ការដែលសំខាន់ក្នុងការកត់សម្គាល់នេះ ថាតើចម្លើយណាខ្លះដែលវាក្រៅអង្គហេតុ ក្រៅវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការក្នុងសំណុំរឿង០០២/០១ ប៉ុណ្ណោះ។ បញ្ហាដទៃទៀត យើងមិនអនុញ្ញាតទេ។ នេះជាវិធានរួមដែលយើងបានកំណត់ក្នុងការធ្វើស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី។

[១៥:០០:១៨]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំចង់និយាយអំពីការផ្តល់សក្ខីកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណីនេះហើយ ដែលខ្ញុំចង់ធ្វើការកត់

សម្គាល់។ ទី១ គឺខ្ញុំគិតថាមានធាតុផ្សំនៃចម្លើយរបស់គាត់ គឺយើងអាចនិយាយថាជាចម្លើយរបស់គាត់ថាមានសំណួរមួយចំនួន ដែលមិនបានកំណត់ជាក់លាក់ អំពីសំណាក់អង្គជំនុំជម្រះ។ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺថាវាហួសពីវិសាលភាពនៃសំណុំរឿង០០១/០២ ក៏ប៉ុន្តែលើពី -- /១ លើសពីហ្នឹងទៀត គឺថាខ្ញុំសូមគូសបញ្ជាក់ថា ខ្ញុំឆ្ងល់ ហើយនិងរង្កៀសចិត្តមែនទែននូវដំណើរការស្ដាប់សវនាការនេះ។ ពីព្រោះថា ខ្ញុំមិនមែនចំពោះដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវនិយាយតែពីការឈឺចាប់របស់ខ្លួនទេ ត្រូវនិយាយ -- ត្រូវនាំយកពីភស្តុតាងមកផង ហើយត្រូវគោរពតាម -- គោរពវិសាលភាពនៃការជម្រះសេចក្ដីនេះផង។

[១៥:០១:២៥]

ដូច្នេះវាបង្កើតឲ្យមាន -- បង្កបញ្ហាប៉ះពាល់ដល់ខាងការពារក្ដី។ បើខ្ញុំមិនច្រឡំទេ គឺថានៅពេលដែលយើងស្ដាប់សក្ខីកម្មសាក្សីនេះចប់ យើងជាមេធាវីការពារក្ដីមិនត្រូវបានអនុញ្ញាតឲ្យចោទសំណួរសួរដើមបណ្ដឹងរដ្ឋប្បវេណីទេ។ អ៊ីចឹងបានន័យថា ក្នុងក្របខ័ណ្ឌនៃការនិយាយការឈឺចាប់របស់គាត់នេះ គាត់ចាកចេញពីវិសាលភាព។ អ៊ីចឹងយើងត្រូវគេចងដៃចងជើង អត់មានលទ្ធភាពអ្វីតតាំង ពិភាក្សាអំពីភស្តុតាងនោះទេ។ អ៊ីចឹងវាខុសពីវិសាល ក្រៅពីវិសាលភាពនៃសំណុំរឿង ០០២/១។ ដូច្នេះវាធ្វើ -- ឧទាហរណ៍ដូចជាមកនិយាយសួរកូនក្ដីខ្ញុំដោយផ្ទាល់នេះ ហើយខ្ញុំជាមេធាវីនេះ ខ្ញុំគ្មានសិទ្ធិអីសួរទៅសាក្សីវិញ ទៅដើមបណ្ដឹងរដ្ឋប្បវេណីទេ។ ដូច្នេះយើងមានបញ្ហានីតិវិធីសំខាន់បំផុត។ អ៊ីចឹងខ្ញុំសូមឲ្យអង្គជំនុំជម្រះសម្រេច ដើម្បីជៀសវាងឲ្យមានបញ្ហា -- កុំឲ្យមានបញ្ហានេះទៀតនៅពេលក្រោយ។ ហើយនៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀតមកនៅពេលក្រោយនោះ ដែលពាក់ព័ន្ធនឹងរយៈពេលនេះទៀតដដែលនេះ ហើយយើងនឹងមិនមានលទ្ធភាពសួរគាត់ទៀត។ អ៊ីចឹងគឺថា ឥឡូវនេះដូចឧទាហរណ៍ឥឡូវនេះ គឺថាដើមបណ្ដឹងរដ្ឋប្បវេណីនេះគាត់និយាយចប់ហើយ អ៊ីចឹងខាងការ សិទ្ធិដែលសួរផ្ចញ់ទៅគាត់នោះត្រូវបានរឹតត្បិត។

[១៥:០៣:០៨]

ហើយខ្ញុំគិតថា ធ្វើដូច្នេះមិនអាចទទួលបានទេ រំលោភយ៉ាងធ្ងន់ធ្ងរទៅសិទ្ធិខាងការពារក្ដី។ អ៊ីចឹងខ្ញុំសូមគូសបញ្ជាក់ត្រង់ចំណុចនេះ។ ហើយជាថ្មីម្ដងទៀត នៅចំពោះអង្គជំនុំជម្រះនេះ គឺថាចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី គឺថាមិនមែនផ្ដោតទៅការចោទសំណួរទៅជនជាប់ចោទនោះទេ។ ដូច្នេះគឺថាធ្វើឲ្យប៉ះពាល់ ហើយនិងមិនសមស្របតែម្ដងចំពោះជនជាប់ចោទ។ ជាក់លាក់គឺថាលោក ខៀវ សំផន តែម្ដង

ដែលថាគាត់ខំប្រឹងប្រែងជាងជនជាប់ចោទអ្វីផ្សេងទាំងអស់។ ហេតុដូច្នេះ គេសង្កត់កគាត់តែម្តងឥឡូវនេះ ហើយខ្ញុំគិតថា សូមឲ្យគោរពនូវនីតិវិធី ហើយនិងគោរពសិទ្ធិ។

ដូច្នេះចំពោះចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ ពុំមានជាប់ពាក់ព័ន្ធទៅនឹងការរៀបរាប់ ការឈឺចាប់ប៉ុន្មាននោះទេ គឺថាមកលើកយកភស្តុតាងផ្សេងៗមកផ្ចាញ់នឹងកូនក្តីខ្ញុំទៅវិញ។ ដូច្នេះ សូមទាញចំណាប់អារម្មណ៍ត្រង់ចំណុនេះ ហើយសូមឲ្យចាំថាយើងកំពុងកាត់ក្តីពីបទឧក្រិដ្ឋ យើងមិនមែនជាការលេងសើចនោះទេ ធ្វើនេះមិនមែនជាការលេងសើចទេ។

[១៥:០៤:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមធ្វើការកត់សម្គាល់ខ្លីមួយទាក់ទងទៅនឹងការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីមុននេះ។

បញ្ហាដែលគាត់លើកឡើងចំពោះការតាំងសំណួរឲ្យលោក ខៀវ សំផន ស្វែងរកទីសាកសពរបស់ឪពុកមារបស់គាត់។ ខ្ញុំយល់ថាវាមិនមែនជាសាច់រឿង ដែលស្ថិតនៅក្នុងវិសាលភាពនៃតុលាការនេះទេ។ ហើយតុលាការនេះក៏មានសមត្ថកិច្ចណានឹងទៅស្វែងរកសាកសពនោះដែរ។ ហើយម្យ៉ាងទៀតការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏មិនមានភស្តុតាងបញ្ជាក់ថា លោក ខៀវ សំផន ហ្នឹងជាអ្នកបញ្ជា ឬក៏ជាអ្នកធ្វើអីឲ្យគេសម្លាប់ឪពុកមារបស់គាត់ ដើម្បីបង្ហាញថា ឪពុកមារបស់គាត់ហ្នឹងស្លាប់នៅកន្លែងណាទីតាំងណាដែរ។

[១៥:០៥:២៤]

ហើយជាក់ស្តែងការលើកឡើងអំពីលិខិត ដែលថាមានលិខិតសរសេរដោយលោក ខៀវ សំផន នោះគឺមិនមានអ្វីបញ្ជាក់ថា មានលិខិតនោះមកដាក់បង្ហាញ ហើយថាជាលិខិតរបស់លោក ខៀវ សំផន ពិតប្រាកដ ឬមួយយ៉ាងណានោះទេ។ ដូច្នេះការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពេលនេះ គឺការលើកឡើងដោយមិនមានមូលដ្ឋានច្បាស់លាស់ ហើយមិនពាក់ព័ន្ធទៅនឹងវិសាលភាពនៃតុលាការនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតទេ។ អង្គជំនុំជម្រះសម្រេចលើបញ្ហានេះជាមុនសិន។

[១៥:០៦:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៨:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីធ្វើការកត់សម្គាល់ ឬក៏ឆ្លើយតបទៅនឹងអ្វី ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី លោក ខៀវ សំផន។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជាបឋម ខ្ញុំសូមធ្វើការកត់សម្គាល់មួយ ហើយយើងបានផ្តល់វេទិកាទៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីថ្លែងទុក្ខរបស់គាត់។ ខ្ញុំគិតថា យើងទាំងអស់គ្នាច្បាស់ហើយ គឺថាការឈឺចាប់ដែលដើមបណ្តឹងរដ្ឋប្បវេណីចង់ថ្លែង ទាក់ទងទៅនឹងពូ អ៊ំរបស់គាត់ឈ្មោះ ចៅ សៅ ដែលបាត់ខ្លួននៅពេលជម្លៀសចេញពីក្រុងភ្នំពេញ។

ដូច្នេះ ខ្ញុំគិតឃើញថា អ្វីដែលគាត់លើកឡើងនោះវាពាក់ព័ន្ធយ៉ាងច្បាស់លាស់ នៅក្នុងក្របខ័ណ្ឌយើងនេះ។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ យើងស្ថិតនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡ ហើយដើមបណ្តឹងរដ្ឋប្បវេណីជាភាគី។ អ៊ីចឹងមានសិទ្ធិចោទសំណួរ ហើយជនជាប់ចោទ ក៏មានសិទ្ធិអនុវត្តសិទ្ធិរបស់ខ្លួននៅស្ងៀមមិនឆ្លើយតប។ ខ្ញុំមិនយល់ទាល់តែសោះថាហេតុអីក៏មានការរំលោភសិទ្ធិលើភាគីការពារក្តី។ បើសិនជាមើលទៅឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយទៅមានអង្គហេតុណាមួយ ដែលថាខាងការពារក្តីនេះចង់ចោទសួរនោះ។ ក្នុងករណីនេះយើងអាចអនុញ្ញាតឲ្យខាងការពារក្តីសួរបាន ក៏ប៉ុន្តែតាមស្ថានភាពនេះ ខ្ញុំមិនយល់ថាហេតុអ្វីក៏ថាមានរឿងអីដែលត្រូវចោទសំណួរទៅគាត់នោះទេ ព្រោះថាអត់មានឃើញមានបញ្ហានីតិវិធីអីផង។

[១៥:១០:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមការបំភ្លឺទៅលោកចៅក្រម ឡាវែន៍។ តើខ្ញុំត្រូវយល់ថានៅពេលដែលដើម

បណ្ដឹងរដ្ឋប្បវេណីរៀបរាប់អំពីទុក្ខរបស់ខ្លួន ហើយនៅពេលនោះគាត់លើកភស្តុតាងថ្មីដែលមិនទាន់បានសួរដោយភាគី។ ឧទាហរណ៍ដូចដើមបណ្ដឹងដែលយើងបានស្ដាប់នោះ អ៊ីចឹងមិនដែលមាននិយាយលើកឡើងអំពីសំបុត្រដែលសរសេរដោយកូនក្ដីរបស់ខ្ញុំ ឬក៏ផ្ញើជូនទៅឰរបស់គាត់ហ្នឹង ឬក៏ថានិយាយអំពីទំនាក់ទំនងរវាងគាត់ និងកូនក្ដីរបស់ខ្ញុំ។ តើក្នុងពេល ក្នុងករណីនេះ តើមេធាវីការពារក្ដីអាចសួរទៅគាត់បានទេពេលក្រោយមក ឬក៏ថាយើងអាចមានសិទ្ធិសួរថា បើពេលដែលគាត់ឆ្លើយចប់ហើយហ្នឹង មានចំណុចមួយចំនួនពាក់ព័ន្ធ យើងសួរទៅគាត់បន្ថែម។

[១៥:១២:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

យើងមិនដែលជំទាស់បដិសេធសិទ្ធិនេះសួរនេះទេ គឺថាដើម្បីជារកការពិតឃើញនោះ ថាសំណួរទាំងអស់នេះ យើងអនុញ្ញាតឲ្យសួរ មិនមានបញ្ហាអ្វីទេដើម្បីរកការពិតឃើញ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ដូច្នេះខ្ញុំសូមទទួលបានលទ្ធភាពសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទាក់ទងនឹងអ្វីដែលគាត់បានលើកឡើងជាក់លាក់តែម្ដង គឺទាក់ទងទៅនឹងលិខិតដែលគាត់ទទួល គាត់លើកឡើងអម្បាញ់មិញនេះទាក់ទងនឹងកូនក្ដីរបស់ខ្ញុំ។

[១៥:១២:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១២:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះមិនបន្តលើករណីនេះទៀតទេ។ ទី១ អង្គជំនុំជម្រះបានឲ្យដើមបណ្ដឹងរដ្ឋប្បវេណីវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់រួចហើយ។ បញ្ហាទី២ គឺជនជាប់ចោទបានបង្ហាញជំហរច្បាស់លាស់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបរួចហើយ។ ច្បាស់លាស់ហើយ។

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ឃើញថាដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។

សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី០៤ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃអង្គារ ទី០៤ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹង

រដ្ឋប្បវេណីដែលមានរហស្សនាម TCCP-188 ដែលនឹងផ្តើមសួរដេញដោលដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុននឹងភាគីឯទៀតនៃរឿងក្តី។ សូមភាគី និងសាធារណជនជ្រាប។

[១៥:១៣:៥៥]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ និងឲ្យនាំខ្លួនគាត់ទាំងពីរនាក់មកកាន់បន្ទប់សវនាការនេះវិញនៅថ្ងៃអង្គារ ទី០៤ ធ្នូ ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:១៤ នាទី)*